ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- យុត្តិធម៌មិនមែនឥតប្រយោជន៍ទេ
- ទស្សនកិច្ចសិក្សាអំពីសន្តិភាពនិងសិទ្ធិមនុស្សរបស់សិស្សានុសិស្សវិទ្យាល័យក្នុងខេត្តបាត់ដំបងទៅកាន់តំបន់អន្លង់វែង
- សិក្ខាសាលាអប់រំ «ស្ដីអំពីការទប់ស្កាត់អំពើឧក្រិដ្ឋកម្មឃោរឃៅនៅក្នុងតំបន់អាស៊ីអាគ្នេយ៍»

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៦៤ ខែធ្នូ ឆ្នាំ២០២១

# ស្វែងរកការពិត

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៦៤ ខែធ្នូ ឆ្នាំ២០២១

## មាតិកា

**សំបុត្រ**

◆ យុត្តិធម៌មិនមែនឥតប្រយោជន៍ទេ ..........១

◆ ជូនចំពោះអ្នកស្ម័គ្រចិត្ត..................... ៣

**ផ្នែកឯកសារ**

◆ វរសេនាតូច ៤០៥ ការពារព្រំដែន......... ៥

**ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ**

◆ រឿងរ៉ាវរបស់ អ៊ុង សេង ...................១០

◆ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង...........១២

◆ មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង.........១៩

◆ មជ្ឈមណ្ឌលឯកសារខេត្តតាកែវ......... ៣២

◆ អ្នកស្ម័គ្រចិត្តកម្ពុជា នាំយកកញ្ចប់......... ៤០

**ផ្នែកច្បាប់**

◆ សាលក្រមសំណុំរឿង០០២/០២ .........៤៣

**ផ្នែកវេទិកាសាធារណៈ**

◆ ទស្សនកិច្ចសិក្សាអំពីសន្តិភាពនិង សិទ្ធិមនុស្ស.............................. ៤៩

◆ សិក្ខាសាលាអប់រំ «ស្តីអំពីការទប់ស្កាត់ អំពើឧក្រិដ្ឋកម្មឃោរឃៅ..................៥៤

**ផ្នែកស្រាវជ្រាវរកគ្រួសារ**

◆ «ធ្ងួលពិឃាដ»

៣. វិញ្ញាណព្រលឹងក្រមាប៉ាក់ដាយ ........... ៥៧

ទូលស្លាំងខាបព្រលឹង..................... ៥៨

ព្រលឹងទឹកភ្នែកពូឡឿន និងកូនស្រី .......៦០

៤. ព្យុះជីវិតក្រោយមេឃបាត់ដួងចន្ទ្រ...... ៦១

អ្នកទោសកុមារបដិវត្តន៍ .................. ៦១



កងកុមារលើកភ្លឺស្រែនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៩៧)។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥ព.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ ៖** ឆាំង យុ, ដារ៉ាវដ្ឋ មេត្តា, ងីម ស៊ីហន, សួត វិចិត្រ, មេក វិន, ហ៊ាន ពិសី, ដេង ពង្សរ៉ាស៊ី, ភា រស្មី, សូ ហាន់, ថុន ស្រីពេជ្រ, កាន់ សុភាព, សៀង កញ្ញា, មឿន ហាច, ផាន់ វិន, ជីម សុខគា, សុខ ចន្ទ្រា និង ឡុង វង្សសមិទ្ធ
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ដាត ចាន់សុនិតា **អ្នកបកប្រែ៖** លីម អ៊ុភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដារ៉ាវដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង
Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# យុត្តិធម៌មិនមែនឥតប្រយោជន៍ទេ

**ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា**




ផ្ទាំងរូបភាពរបស់គម្រោង ការលើកកម្ពស់សិទ្ធិ និងធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលជួយដល់អ្នករស់រានមានជីវិតទាំងនេះទៅពិនិត្យសុខភាពនៅតាមមន្ទីសម្រាកព្យាបាលឯកជនដោយឥតគិតថ្លៃ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១ អង្គជំនុំជម្រះតុលាការកំពូល បានចេញសេចក្តីសម្រេចរបស់ខ្លួនលើសំណុំរឿងប្រឆាំងនឹង មាស មុត។ សេចក្តីសម្រេចនេះបានបញ្ចប់នូវវាល់ទិកាសក្នុងការជំនុំជម្រះអំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ការសម្រេចរបស់អង្គជំនុំជម្រះ តុលាការកំពូលនេះ ធ្វើឲ្យមានការលើកឡើងពីគ្រួសាររបស់ មាស មុត ថាមិនសមស្រប និងមិនត្រឹមត្រូវ។

ដោយគ្មានមន្ទិល អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដំណើរការទៅយឺតយ៉ាវ និងអប្រសិទ្ធភាព ដែលបង្កជាការឈឺចាប់ដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងក្រុមគ្រួសារ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនបានបំពេញស្របទៅតាមការរំពឹងទុក ដែលបានធ្វើឲ្យអាប់ឱនដល់កេរដំណែលរបស់ស្ថាប័ននេះ ព្រមទាំងចោទជាសំណួរអំពីផលប៉ះពាល់នៃអង្គជំនុំជម្រះនេះចំពោះបច្ចុប្បន្ន និងអនាគត។ ការរិះគន់ខាងលើ និងមតិដទៃទៀត គឺពិតជាសមហេតុសមផល។

ប៉ុន្តែនាពេលថ្មីៗនេះ គ្រួសាររបស់ មាស មុត បានលើកឡើងថា "[ការបន្ត] សំណុំរឿង [ប្រឆាំងនឹងជនជាប់ចោទ] គឺឥតប្រយោជន៍ទេ [. . .] ការនាំខ្លួនអ្នកទាំងនេះមកកាត់ទោសគឺឥតប្រយោជន៍ ពីព្រោះថា [ជនជាប់ចោទទាំងឡាយ] មានវ័យចំណាស់ ហើយខ្លះបានបាត់បង់ជីវិតទៅហើយ។

យុត្តិធម៌មិនមែនឥតប្រយោជន៍ទេ។ កាលពី៤០ឆ្នាំ




ទង់ជាតិប្រទេសកម្ពុជាៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទង់ជាតិ អង្គការសហប្រជាជាតិ ៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កន្លងទៅជនរងគ្រោះកម្ពុជាប្រមាណជាងពីរលាននាក់បានបាត់បង់សិទ្ធិការពារខ្លួនឬសូម្បីតែសិទ្ធិរៀបរាប់រឿងរ៉ាវរបស់ខ្លួនៗ ប្រជាជនកម្ពុជាប្រមាណជាងពីរលាននាក់បានបាត់បង់សិទ្ធិក្នុងការប្តឹងតបតចំពោះការកាត់ទោសប្រហារជីវិតរបស់ខ្លួន ភាពអត់ឃ្លាន ការធ្វើការហួសកម្លាំង និងជំងឺ ដែលបង្កឡើងដោយសារតែការគ្រប់គ្រងនៃរបបខ្មែរក្រហម ឬការចាប់ខ្លួន ការធ្វើទារុណកម្ម និងការប្រហារជីវិតដែលបញ្ជាដោយរបបខ្មែរក្រហមនេះផ្ទាល់ៗ ពុំមានវត្តមាននៃអង្គជំនុំជម្រះតុលាការកំពូល អង្គជំនុំជម្រះសាលាដំបូង ឬមេធាវីការពារក្តី ដើម្បីការពារសិទ្ធិរបស់ជនរងគ្រោះដែលបានស្លាប់ភាគច្រើនដោយឯកោ ដោយសារការកម្ទេច និងការបំផ្លិចបំផ្លាញដ៏ឃោរឃៅរបស់ខ្មែរក្រហមៗ ខ្មែរក្រហមគ្មានការអាណិតអាសូរចំពោះមនុស្សគ្រប់វ័យ ជនពិការ ឬ លក្ខណៈវិនិច្ឆ័យផ្សេងទៀតដែលលើកឡើងដោយគ្រូសាររបស់ មាស មុតៗ មាស មុត ក៏ដូចជាជនជាប់ចោទទាំងអស់ដែរ បានទទួលសិទ្ធិច្រើនលើសពីជនរងគ្រោះក្នុងរបបខ្មែរក្រហមៗ ពិតជាមានការពិបាកក្នុងការកំណត់ថា បុគ្គលម្នាក់ស្លូតស្លុំគ្មានទោស ដោយមិនឆ្លងកាត់ដំណើរការផ្លូវច្បាប់ ដែលជាសិទ្ធិជនជាប់ចោទត្រូវទទួលបាន ហើយយើងក៏មិនអាចមិនរវីរវល់នឹងជនរងគ្រោះនៃបទឧក្រិដ្ឋដែលចោទលើបុគ្គលរូបនោះៗ ការមានទោស ឬភាពស្លូតស្លុំរបស់ជនជាប់ចោទនឹងមិនសាបរលាបទៅតាមអាយុទេ ហើយយុត្តិធម៌ក៏មិនបាត់បង់សារសំខាន់របស់ខ្លួនទៅតាមសេចក្តីស្លាប់ដែរៗ

អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមានវ័យចំណាស់ដូចជនជាប់ចោទដែរៗ សព្វថ្ងៃនេះ នៅមានអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមប្រមាណជាង ៥ លាននាក់ ដែលជាសាក្សីរស់នៃអ្វីដែលបានកើតឡើងក្នុងរបបខ្មែរក្រហមៗ ភាគច្រើននៃអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងនោះ គឺជាសាក្សីនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង និងឧក្រិដ្ឋកម្មដែលចោទទៅលើជនជាប់ចោទៗ អ្នករស់រានមានជីវិតជាច្រើន ទន្ទឹងចង់បាននូវយុត្តិធម៌ ដែលពួកគេមិនអាចទទួលបានតាមដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាៗ អ្នករស់រានមានជីវិតមួយភាគធំបានបោះបង់ក្តីសង្ឃឹមរបស់ខ្លួនតាំងពីយូរលង់ណាស់ទៅហើយៗ

អ្នករស់រានមានជីវិតមួយចំនួនធំទៀតបានលើកលែងទោសដល់ឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមដែរៗ ការលើកលែងទោសដ៏លើសលប់ (អាចនិយាយបានថាលើសលប់ជ្រុល) ត្រូវបានផ្តល់រួចហើយ ដូច្នេះសូមកុំបង្ខំឲ្យអ្នករស់រានមានជីវិតទាំងអស់បន្តលើកលែងទោសទៀតៗ រឿងរ៉ាវរបស់អ្នកទាំងនេះ (មិនមែនតាមរយៈការរៀបរាប់របស់ មាស មុត តែងមានភាពលម្អៀងជាមូលដ្ឋាន ហើយកត្តានេះគឺជាការបំអកដ៏ធ្ងន់ធ្ងរ) ត្រូវទទួលស្គាល់ដោយមនុស្សជំនាន់ក្រោយ ដែលជាអ្នកទទួលខុសត្រូវក្នុងការធានាថាប្រវត្តិសាស្ត្រនេះនឹងមិនត្រូវបានបំភ្លេចចោលជារៀងរហូតៗ

លោក ឆាំង យុ គឺជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាអ្នករស់រានមានជីវិតម្នាក់ពីវាលពិឃាដខ្មែរក្រហមៗ មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាស្ថាប័នស្រាវជ្រាវឯករាជ្យរបស់កម្ពុជា ដែលតម្កល់ទុកបណ្ណសារបន្សល់ពីរបបកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) ធំបំផុតនៅលើពិភពលោកៗ អ៊ីមែល៖ dccam@online.com.kh

# ជូនចំពោះអ្នកស្ម័គ្រចិត្ត

**ឆាំង យុ**





អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី១ ទាំង៤៦២រូប នៅតាមតំបន់ដាច់ស្រយាលទូទាំងប្រទេសកម្ពុជា ដែលបានចូលរួមការងារស្ម័គ្រចិត្តគាំពារ និងទំនុកបម្រុងដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ក្នុងរយៈពេល៥ខែកន្លងមក គឺចាប់តាំងពីថ្ងៃទី១ ខែសីហា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។ (អ្នកស្ម័គ្រចិត្តកម្ពុជា/មជ្ឈមណ្ឌលឯកសារកម្ពុជា)




មជ្ឈមណ្ឌលឯកសារកម្ពុជា សូមថ្លែងអំណរគុណដល់អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី១ ទាំង៤៦២រូប ដែលបានចូលរួមការងារស្ម័គ្រចិត្ត គាំពារ និងទំនុកបម្រុងដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ក្នុងរយៈពេល៥ខែកន្លងមក គឺចាប់តាំងពីថ្ងៃទី១ ខែសីហា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។ សូមប្រកបដោយសំណាងល្អនៅក្នុងឆ្នាំ២០២២ខាងមុខ។ ការងាររបស់ប្អូនៗ ពិតជាមានសារៈសំខាន់ណាស់ ក្នុងការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងសហគមន៍របស់ប្អូនៗ។ ក្នុងអំឡុងពេលនៃការបំពេញការងារស្ម័គ្រចិត្តរបស់ប្អូនៗ ប្អូនបានជួបសម្ភាសជាមួយនឹងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងភូមិឋានរបស់ខ្លួន ដែលក្នុងនោះរួមបញ្ចូលការប្រមែប្រមូលព័ត៌មានចាំបាច់នានាអំពីស្ថានភាពសុខភាព និងបញ្ហាប្រឈមរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ក៏ដូចជាបទពិសោធន៍ផ្ទាល់របស់គាត់នៅក្រោមរបបខ្មែរក្រហមថែមទៀតផង។ ប្អូនៗក៏បានជួយសម្រួលឲ្យអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងនេះ ទទួលសេវាថែទាំ ព្រមទាំងជួយបង្កើនការយល់ដឹងរបស់គាត់ស្តីពីការថែទាំសុខភាព

របស់ខ្លួនឲ្យបានត្រឹមត្រូវ។ កិច្ចខិតខំប្រឹងប្រែងដោយមិននឿយណាយរបស់ប្អូនៗ ក្នុងនាមជាអ្នកស្ម័គ្រចិត្តនៃគម្រោងនេះ បានចូលរួមចំណែកដល់ការធ្វើឲ្យប្រសើរឡើងនូវសុខភាពនិងសុខុមាលភាព របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ក្នុងគ្រាដ៏លំបាកលំបិន ដែលរួមបញ្ចូលទាំងការរាតត្បាតជាសាកលនៃជំងឺកូវីដ-១៩។ សកម្មភាពស្ម័គ្រចិត្តរបស់ប្អូនៗ ឆ្លុះបញ្ចាំងអំពីគុណតម្លៃដ៏ប្រសើរសម្រាប់ខ្លួនឯង សហគមន៍ និងប្រជាជនកម្ពុជាជារួម។ មជ្ឈមណ្ឌលឯកសារកម្ពុជា សូមប្រគល់ជូនប្អូនៗនូវលិខិតសរសើរ ដែលចុះហត្ថលេខាដោយប្រធានទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិប្រចាំនៅកម្ពុជា លោកស្រី ណែនស៊ី អ៊ីសស្លីក ។





អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី១ ទាំង៤៦៧រូប នៅតាមតំបន់ដាច់ស្រយាលទូទាំងប្រទេសកម្ពុជា ដែលបានចូលរួមការងារស្ម័គ្រចិត្តគាំពារនិងទំនុកបម្រុងដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ក្នុងរយៈពេល៥ខែកន្លងមក គឺចាប់តាំងពីថ្ងៃទី១ ខែសីហា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។ (អ្នកស្ម័គ្រចិត្តកម្ពុជា/មជ្ឈមណ្ឌលឯកសារកម្ពុជា)




លិខិតសរសើរដែលចុះហត្ថលេខាដោយប្រធានទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិប្រចាំនៅកម្ពុជា លោកស្រី Nancy J. Eslick ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# វរសេនាតូច ៤០៥ ការពារព្រំដែន ស្រុកកោះញែក តំបន់១០៥

**ជាវ៉ារដ្ឋ មេត្តា**



កងទ័ពបដិវត្តន៍ខ្មែរក្រហម កំពុងដាក់មីនបិទផ្លូវនៅព្រំដែនវៀតណាមៗ (បណ្ណសារ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ភូ កាដាំ ហៅ ឡា អាយុ២៧ (ឆ្នាំ១៩៧៨)ៗ ខ្ញុំមានតួនាទីជាលេខាកងធំ នៅវរសេនាតូច៤០៥ៗ ខ្ញុំមានស្រុកកំណើតនៅភូមិពាមជីមាត ឃុំពាមជីមាត ស្រុកកោះញែក តំបន់១០៥ ខេត្តមណ្ឌលគិរីៗ ខ្ញុំរៀនសាលាពាមជីមាតពីថ្នាក់ទី១២ រហូតដល់ថ្នាក់ទី៧ (ពីសង្គមចាស់)ៗ នៅឆ្នាំ១៩៦៦ ខ្ញុំបានទៅប្រឡងដើម្បីចូលរៀនថ្នាក់ទី៦ នៅទីរួមខេត្តមណ្ឌលគិរី ប៉ុន្តែខ្ញុំប្រឡងមិនជាប់ក៏ត្រឡប់មកជួយធ្វើស្រែឪពុកម្ដាយវិញៗ នៅពាក់កណ្ដាលឆ្នាំ១៩៦៦ ខ្ញុំចូលបដិវត្តន៍តាមរយៈឈ្មោះ ធាៗ នៅពេលដែលខ្ញុំចូលបដិវត្តន៍ដំបូង ខ្ញុំមិនទាន់មានតួនាទីអ្វីទេ ខ្ញុំគ្រាន់តែមានឈ្មោះនៅក្នុងបដិវត្តន៍តែប៉ុណ្ណោះៗ

នៅក្នុងឆ្នាំ១៩៦៧ ខ្ញុំចូលរួមធ្វើបាតុកម្មប្រឆាំងជាមួយប៉ូលិសនៅពាមជីមាតៗ ក្រោយពីខ្ញុំចូលធ្វើបាតុកម្មបានចំនួនមួយថ្ងៃ ប៉ូលិសនៅប៉ុស្តិ៍ពាមជីមាតឈ្មោះ ម៉ន បានស្គាល់ខ្ញុំ បន្ទាប់មកហៅខ្ញុំនិងមនុស្ស៣នាក់ទៀតឲ្យទៅជួបៗ អ្នកទៅជួបប៉ូលិស ម៉ន មានឈ្មោះ យ៉ា គឺជាជំនួយការស្រុកកោះញែក តំបន់

១០៥, វិន គឺជាអនុលេខាកងតូចនៅវរសេនាតូច៤០៥ យោធាតំបន់១០៥ និង ដូ ហៅ ទឹម គឺជាអនុលេខាកងតូច នៅវរសេនាតូច៤០៥។ នៅពេលដែលខ្ញុំទៅជួបជាមួយ ម៉ន សួរខ្ញុំថា «ប្អូនធ្វើជាខ្មែរក្រហមឬបានជាប្អូនប្រឆាំងជាមួយជាតិឯង?» យើងខ្ញុំទាំងបួននាក់ឆ្លើយប្រាប់ប៉ូលីស ម៉ន ថា «ពួកខ្ញុំធ្វើខ្មែរក្រហមមែន»។ ម៉ន ប្រាប់ខ្ញុំថា «ប្អូនជាទាហានខ្មែរក្រហមមិនឈ្នះទាហានសម្តេច សីហនុ ទេព្រោះទាហានសម្តេចសីហនុមានកាំភ្លើង ហើយចុះទាហានខ្មែរក្រហមមានអ្វី? ហូបតែស្លឹកឈើ ស្លាប់ពេញតែព្រៃ»។ ម៉ន ស្នើឲ្យខ្ញុំធ្វើជាគិញឲ្យគាត់។

ក្រោយពីខ្ញុំបានសម្រេចចិត្តធ្វើជាគិញ ស៊ើបរកខ្មែរក្រហម ខ្ញុំ, យ៉ា, ទឹម និង វិន បានរាយការណ៍ទៅឲ្យប៉ូលីស ម៉ន ថាយើងមានតាធ្វើខ្មែរក្រហម ហើយត្រូវរបួសបែកមុខនៅពេលដែលគាត់ចូលរួមធ្វើបាតុកម្ម។ ឥឡូវទៅលាក់ខ្លួននៅស្រែលំម៉ាន់។ ម៉ន បាននាំប៉ូលីសមួយចំនួនទៅចាប់បានតាជិន, តាចែម, តានូ និង តាណា យកទៅដាក់នៅបន្ទាយពាមជីមាត។ ប្រជាជនទាំងអស់នៅក្នុងឃុំពាមជីមាត បានរត់ចូលព្រៃអូរឡៅ ហើយពួកខ្ញុំទាំងបួននាក់ទៅជាមួយដែរ។ ចាប់តាំងពីពេលនោះមកខ្ញុំបានដាច់ការទាក់ទងជាមួយប៉ូលីស ម៉ន ម្យ៉ាងដោយផ្លូវធ្វើដំណើរចេញចូលឆ្ងាយ ។ ខ្ញុំនៅតែរក្សាទំនាក់ទំនងជាមួយឈ្មោះ វិន, ទឹម និង យ៉ា។ ខ្ញុំធ្វើការនៅក្នុងព្រៃបានរយៈពេល២ទៅ៣ថ្ងៃ ឡាំង ចុះមកទទួលប្រជាជនហើយពេលជួបខ្ញុំ ឡាំង យកខ្ញុំទៅនៅជាមួយគាត់នៅមន្ទីរ៦០។

នៅឆ្នាំ១៩៦៨ បង ឡេង (នៅក្នុងឆ្នាំ១៩៧៨ លេខាវរសេនាតូចរបស់តំបន់១០៥) បានចេញពីធ្វើយោធាបដិវត្តន៍ដែលគ្រប់គ្រងដោយយួន ហើយបង ឡេង មកធ្វើជាប្រធានក្រុមឈ្លបនៅ អូរឡៅ។ នៅដើមឆ្នាំ១៩៧០ ឡាំង ចាត់តាំងឲ្យខ្ញុំមកធ្វើជាយោធានៅតំបន់១០៥វិញ។

នៅឆ្នាំ១៩៧១ អង្គការបានដកអង្គភាពរបស់ខ្ញុំឲ្យទៅធ្វើការនៅឃុំស្រែជិះ។ មុនពេលទៅ បង ឡេង បានហៅខ្ញុំទៅប្រជុំនៅភូមិប្រង់ រួមមានឈ្មោះ យ៉ា, ស៊ិន ដៃ គឺជាអនុសេនាធំ នៅវរជាមួយបង ឡេង យោធាតំបន់១០៥, ចាម គឺជាអនុសេនាធំ នៅជាមួយបង ឡេង យោធាតំបន់១០៥, វិន, ទឹម និង សុត គឺជាប្រធានកម្មករជួសជុល ឡាន។ បង ឡេង ឲ្យយើងដាក់ផែនការថ្មីដើម្បីធ្វើសកម្មភាព។ ទោះបីយើងត្រូវបែងចែកឲ្យទៅធ្វើការងារនៅតាមតំបន់រៀងខ្លួនក្តី គឺយើងនៅតែធ្វើសកម្មភាពបំផ្លាញកន្លែងយើងធ្វើការ។ ក្រោយមក ខ្ញុំអប់រំកម្លាំងបាន៧ នាក់មានឈ្មោះ ធុន, ស្រាំ, វែង, ឈឹម, ស៊ាន, ក្លេះ និង អន្សា។ ពេលខ្ញុំកំពុងច្រូតស្រូវ ខ្ញុំបានហៅអ្នកទាំង៧ នាក់ខាងលើមកប្រជុំឲ្យធ្វើសកម្មភាពប្រឆាំងបដិវត្តន៍ មិនឲ្យកងទ័ពនេះនៅបានស្រួលឡើយ។ នៅពេលយាមយប់ មានអ្នកលួចទៅគោះត្រដោកទាំងយប់បណ្តាលឲ្យមានការភ្ញាក់ផ្អើលពេញមន្ទីរ។



ទន្លេនៅក្នុងឃុំស្រែហ៊ុយ ស្រុកកោះញែក ខេត្តមណ្ឌលគិរី។ (អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តមណ្ឌលគិរី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅខែធ្នូ ឆ្នាំ១៩៧២ អង្គការដកយោធាតំបន់១០៥ ទាំងអស់មករៀនរយោបាយនៅមន្ទីរក-១៧ មានបង ឡាំង គឺជាអ្នកបង្រៀន។ ខ្ញុំបានទៅរៀនដែរ ហើយបានជួប បង ឡេង និងខ្សែរយៈរបស់ខ្ញុំទាំងអស់នៅក្នុងយោធាតំបន់។ ទៅរៀនបានរយៈពេល៥ថ្ងៃ ខ្ញុំ, ឡេង, ដៃ បានជួបពិភាក្សាជាមួយគ្នា។ យើងចង់



សម្រេចផែនការថ្មី ទី១ គឺកម្ទេចកម្លាំងកម្មាភិបាលយោធាមួយចំនួន។ នៅម៉ោង៩យប់ យើងបាននាំគ្នាមកប្រជុំនៅមាត់អូរប្បារ ដែលមានអ្នកចូលរួមគឺ ១) បងឡេង លេខាវរសេនាតូច របស់តំបន់១០៥ ២) ស៊ិន ឆៃ អនុលេខាកងធំ នៅក្នុងវររបស់ បងឡេង ៣) ចាម អនុលេខាកងធំ នៅក្នុងវររបស់ បងឡេង ៤) សុត ពីមុននៅតំបន់១០៥ក្រោយមកមានតួនាទីជាអ្នកមើលការខុសត្រូវខាងកម្មករជួសជុលឡាន តំបន់១០៥។ បងឡេងនិយាយថា «ខ្ញុំមានផែនការថ្មីសម្រាប់ធ្វើសកម្មភាពកម្ទេចលេខាតំបន់ គឺបង ឡាំង និងកម្មាភិបាលមួយចំនួនទៀតដែលមិនដើរតាមយើង»។ មិត្តត្រូវចុះទៅកសាងកម្លាំងជាមុនសិន។

ក្រោយការប្រជុំខ្ញុំកសាងបានកម្លាំងបានចំនួន ២នាក់មានឈ្មោះ រ៉ាមី និង ឈ្មោះ លី។ ពេលរៀនបានរយៈពេល៧ថ្ងៃ អង្គការឲ្យសម្រាក១ថ្ងៃ។ នៅថ្ងៃសម្រាក បងឡេង បបួលខ្ញុំឲ្យទាក់ទងជាមួយយួន កុក វៀត។ បងឡេង នាំខ្ញុំនិងមិត្តដៃ ទៅជួបយួន កុក វៀត នៅឃុំអ.៤ព្រោះកាលនោះវៀតកុងមកនៅក្នុងទឹកដីកម្ពុជាហើយ។ បងឡេង និយាយភាសាយួនជាមួយយួន កុក វៀត ប្រហែលជាកន្លះម៉ោង ទើបបងឡេងបកប្រែជាភាសាឡាវឲ្យខ្ញុំស្តាប់។ យួន យល់ព្រមជួយយើងឲ្យតែយើងហ៊ានធ្វើសកម្មភាព ទោះជោគជ័យ ឬបរាជ័យយួននៅតែឲ្យយើងរត់ទៅប្រទេសយួន។ ផែនការនេះមិនទាន់បានធ្វើផងក៏បែកការណ៍ ហើយអង្គការចាប់ខ្លួនរ៉ាមី និង លី។ ខ្ញុំចេញពីសាលាបាន ២ថ្ងៃ អង្គការមានផែនការដេញយួនឲ្យចេញពីស្រុកខ្មែរ។ អង្គការតំបន់ចាត់តាំងខ្ញុំ និងមិត្តយើងមួយចំនួនឲ្យទៅការពារសកម្មភាពយួននៅតាមព្រំដែនស្រុកកោះញែក។ ពេលដើរដល់ភូមិកងឡែ យើងបានទៅជួបជាមួយមិត្តឡេង និងបងដៃ។ បងឡេងប្រាប់ខ្ញុំថា ឥឡូវសភាពការណ៍យួនត្រូវអង្គការដេញឲ្យទៅដីយួនវិញ ធ្វើឲ្យការទាក់ទងជាមួយកុក វៀត មានការលំបាក។

ខ្ញុំត្រឡប់មកអង្គភាពវិញបាន៧ថ្ងៃ អង្គការឲ្យខ្ញុំទៅយាមទៀតគឺយាមចាប់ពីខ្ចប់ទៅដល់ភូមិកងឡែ។ ពេលដល់ភូមិកងឡែ ខ្ញុំបានទៅជួបជាមួយបងឡេង និងមិត្តដៃ។ បងឡេងបានទៅជួបជាមួយកុក វៀត នៅឃុំអ.៤លើ ពេលដែលវៀតកុងរៀបសម្ភារចេញពីស្រុកខ្មែរ។ កុក វៀត ប្រាប់ថា ថ្ងៃក្រោយបើមានធ្វើសកម្មភាពអីគឺត្រូវទៅទាក់ទងគាត់នៅភ្នំបូកោ ឬភ្នំណុះទ្រោក ក្នុងទឹកដីយួនម្តុំភូមិក្រាក់ និងដីខ្មែរខាងដាក់ដាំ។

នៅខែមករា ឆ្នាំ១៩៧៣ អង្គការចាត់តាំងខ្ញុំឲ្យទៅយកថ្នាំពេទ្យនៅមន្ទីរពេទ្យយោធាតំបន់នៅភូមិស្រែហ៊ុយ ហើយខ្ញុំបានជួបឈ្មោះ ទង គឺជាប្រធានផ្សំថ្នាំពេទ្យនោះទីនោះ។ ក្រោយពីកើតមានការបាញ់មន្ទីរយោធាតំបន់ អង្គការចាប់អារម្មណ៍ថា យួនចូលធ្វើសកម្មភាព ហើយអង្គការចាត់តាំងឲ្យសមាជិកអង្គភាពរបស់ខ្ញុំមួយចំនួន រួមជាមួយអង្គភាពបងឡេង ទៅយាមការពារនៅព្រំដែនខ្មែរ-យួន ចាប់តាំងពីដាក់ដាំរហូតដល់ទន្លេស្រែពក។

នៅខែមិថុនា ឆ្នាំ១៩៧៣ អង្គការឲ្យខ្ញុំទៅរៀននយោបាយនៅភូមិភាគឧត្តរចាស់ រហូតដល់ខែកញ្ញា ទើបអង្គការឲ្យត្រឡប់មកវិញ។

នៅខែមករា ឆ្នាំ១៩៧៤ អង្គការបានដកអង្គភាពរបស់ខ្ញុំ និងអង្គភាពបងឡេងឲ្យទៅនៅភូមិស្រែហ៊ុយ ស្រុកកោះញែក ជាមួយគ្នា។ នៅខែឧសភា ឆ្នាំ១៩៧៤ ដដែល មានការប្រជុំនៅក្នុងមន្ទីរបងឡេង មានខ្ញុំ, មិត្តដៃ, មិត្តចាម, វិន និង ទឹម។ បងឡេង លើកឡើងថា អង្គការឲ្យលើកទំនប់មួយប្រើរយៈពេល១ខែឲ្យរួចរាល់។ នៅខែធ្នូ ឆ្នាំ១៩៧៤ ខ្ញុំចុះទៅណែនាំមិត្ត សួន និង មិត្តខាំ ធ្វើខាងពាណិជ្ជកម្មឲ្យត្រៀមខ្លួនធ្វើសកម្មភាពថ្មីៗ

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ អង្គការឲ្យបងឡេង ទៅរៀននយោបាយនៅមន្ទីរ ក-១៧ រយៈពេល១ខែ ទើបបងឡេង ត្រឡប់មកអង្គភាពវិញ។ នៅពេលល្ងាច ខ្ញុំបានទៅជួបបងឡេង នៅមន្ទីររបស់គាត់។ យើងបានពិភាក្សាថាឥឡូវនេះអង្គការឲ្យយើងទៅល្បាតតាមព្រំដែន ដូច្នេះយើងប្រាកដជាបានជួបជាមួយ កុក វៀត ហើយនេះគឺជាការសម្រេចពីបងមុី (អនុលេខាតំបន់១០៥)។ ក្រោយមកបាន១ថ្ងៃ អង្គការបានចាត់តាំងអង្គភាពរបស់ខ្ញុំ និងអង្គភាពបងឡេង ទៅយាមល្បាតនៅដាក់ដាំ ស្រុកអូររាំង និងដើរស៊ើបការណ៍នៅភ្នំណុះទ្រោក។ ក្រោយមកបងឡេង បានប្រមូលកម្លាំងរបស់ខ្ញុំទាំងអស់ មានឈ្មោះ សំបុក្រ, សិន ដៃ និង ទឹម ត្រៀមខ្លួនទៅ ទាក់ទងយួន។ យើងបានចូលទៅភ្នំណុះទ្រោកដើរតម្រង់ទៅ ទីកន្លែងដែលយើងធ្លាប់បានទាក់ទងគ្នាតាំងពីឆ្នាំ១៩៧៣ ដែលមានចម្ងាយពីព្រំដែនខ្មែរ៥០០ម៉ែត្រ ក្នុងខេត្ត ឡុកនិញ។ ទៅដល់ជិតមន្ទីរ កុក វៀត ឃើញយោធាយួនដើរពេញព្រៃ។ ខ្ញុំនាំគ្នាលីកាំភ្លើងឡើងលើធ្វើជាសញ្ញាហើយដាក់មកលើស្មាលីវិញ។ កងទ័ពយួនឃើញខ្ញុំប្រុងខ្លួនគ្រប់គ្នា បន្ទាប់មកមានយួនម្នាក់មកសួរខ្ញុំទៅណា? បងឡេង ប្រាប់ថា មកធ្វើការជាមួយបង កុក វៀត។ យួនម្នាក់បានសួរថា ឈ្មោះអ្វីបានសួររក កុក វៀត ហើយក្រោយមក កុក វៀត ក៏ដើរចេញមក។ បងឡេង បានរាយការណ៍អំពីផែនការ បងមុី ដាក់មកនៅក្នុងឆ្នាំ១៩៧៥ បងមុី ចង់ឲ្យកងទ័ពបង កុក វៀត ចូលទៅបោះទីតាំងនៅក្នុងទឹកដីប្រទេសកម្ពុជា នៅទីតាំងដូចជា ភ្នំណុះទ្រោកស្ថិតភាគខាងជើងប្រទេសកម្ពុជា អូរហ៊ុច អូរតាង និងទូយោសាំង។ ទីតាំងដែលយើងឲ្យបងដាក់ទីតាំងកងទ័ពនេះអំណោយផលខ្លាំងណាស់ កន្លែងដែលគ្មានកម្លាំងទ័ព ទីតាំងងាយស្រួលវាយចូលប្រទេសកម្ពុជា និងវាយយកខេត្តមណ្ឌលគិរី។ កុក វៀត បានសួរអំពីចំនួនកម្លាំងតំបន់ដែលមាន និងចំនួនកម្លាំងកងពលមុនពេលសម្រេចចិត្តយល់ព្រមបោះទីតាំងក្នុងទឹកដីកម្ពុជា។ យើងបានប្រាប់កម្លាំងយោធាតំបន់របស់យើងទៅ កុក វៀត មាន២កន្លែងនៅភូមិក្រុងតស់ និង ស្រែអំពូម ហើយកម្លាំងកងពលបានដាក់ឈរជើងចាប់ពីទន្លេស្រែពកដល់ស្រុកកែវសីម៉ាហើយកម្លាំងទាំងនោះយើងបានដាក់ជុំៗទេ។

នៅខែមករា ឆ្នាំ១៩៧៦ អង្គការបានឲ្យខ្ញុំរៀនបច្ចេកទេស ដើម្បីចូលសមរភូមិវាយយួន។ ខ្ញុំរៀនចប់រយៈពេល១ខែ អង្គការប្រកាសលើកផែនការវាយយួនដែលបោះទីតាំងនៅ ទូយោសាំង ក្នុងទឹកដីខ្មែរ។ មុនលើកផែនការវាយយួនបងឡេងឲ្យខ្ញុំ មិត្តទឹម មិត្តវិន បងដៃ និងមិត្តចាម ទៅប្រជុំ ហើយបងឡេង ប្រាប់ថា ឥឡូវនេះអង្គការឲ្យយើងទៅវាយយួនហើយ។ នៅខែកុម្ភៈ ឆ្នាំ១៩៧៦ អង្គការបានឲ្យខ្ញុំ មិត្តសំបុក្រ និងមិត្តវិន ចូលសមរភូមិទូយោសាំងជាមួយគ្នា ឯ ដៃ និង មិត្តចាម ទៅសមរភូមិភ្នំណុះ ជាមួយបងឡេង។ ពេលដល់សមរភូមិទូយោសាំង អង្គការបានឲ្យខ្ញុំសម្រុកប្រយុទ្ធ ចំណែក សំបុក្រ និង វិន គឺនៅកាន់កាំភ្លើងធំ។ នៅពេលប្រយុទ្ធនោះខ្ញុំត្រូវរបួសដោយយួនបានបាញ់បេ៤០ មកត្រូវជើងនិងដៃរបស់ខ្ញុំ។ អង្គការបញ្ជូនខ្ញុំទៅសម្រាកនៅមន្ទីរពេទ្យ។ ខ្ញុំដេកពេទ្យរយៈពេល១ឆ្នាំទើបដៃជើងជាសះស្បើយ អាចដើរបានប៉ុន្តែមិនបានឆ្ងាយ។

នៅខែមករា ឆ្នាំ១៩៧៧ បងបាំង បានយកខ្ញុំទៅព្យាបាលនៅមន្ទីរពេទ្យយោធាតំបន់ព្រោះជើងរបស់ខ្ញុំដាច់សរសៃ។ នៅខែកក្កដា ឆ្នាំ១៩៧៧ ដដែល ខ្ញុំបានទៅជួបបងឡេង នៅមន្ទីរភ្នំក្រោល បន្ទាប់ពីដាច់

ការទាក់ទងជាមួយគាត់យូរៗ បងឡេង ប្រាប់ខ្ញុំពីសភាពការណ៍កន្លងមក បងម៉ី ត្រូវអង្គការចាប់ខ្លួន ហើយអ្វីដែលបានរម្ពនោះបើ បងម៉ី ឆ្លើយដាក់យើង ប្រាកដជាមិនរស់ទេ។ យើងមានអ្នកដឹកនាំបន្តគឺ បងខាំភូន គឺជាអនុលេខាតំបន់១០៥។

នៅខែធ្នូ ឆ្នាំ១៩៧៧ បងឡេងបានស្កាត់មកជួបខ្ញុំនៅមន្ទីរ១០៦ នៅពេលអង្គការឃាត់ខ្លួនខ្ញុំដើម្បីតាមដាន។ ពេលជួបគ្នា បងឡេង ប្រាប់ខ្ញុំថា យួនចូលវាយដល់ដាក់ដាំហើយផ្លូវមិត្តចូលទៅរៀបចំកម្លាំងរបស់យើងឲ្យរួចរាល់។ ខ្ញុំបានឆ្លើយប្រាប់គាត់ថា ខ្ញុំអស់ទ័ពកាន់ទៀតហើយផ្លូវទៅណាមិនរួចទេព្រោះអង្គការតាមដាន។ បងឡេង ប្រាប់ខ្ញុំកុំឲ្យព្រួយដោយផ្លូវនេះមានកម្លាំងយួនវាយមកដល់គ្រប់កន្លែង ខាងយើងក៏វាយ ហើយ ខាងបូព៌ាក៏វាយទៀត ហើយដោយខ្លាចបែកការណ៍បងឡេង ប្រញាប់ទៅវិញ។ មកដល់ថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៨ អង្គការបានចាប់ខ្លួនខ្ញុំមកទីនេះតែម្តង។

**កំណត់ចំណាំ ៖** អត្ថបទនេះ ដកស្រង់ចេញពីចម្លើយសារភាពឯកសារJ00090។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះ យើងមិនអាចសន្និដ្ឋានបានថា ចម្លើយសារភាពរបស់ ភូ កាដាំ ហៅ ឡា ពិតប៉ុយ៉ាងណានោះទេ?



ផ្លូវទៅស្រុកកោះញ៉ែក ខេត្តមណ្ឌលគិរី។
(ឈឹម ពៅ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# រឿងរ៉ាវរបស់ អ៊ុង សេង

***ទីម ស៊ីហាន***



អ៊ុក សេង អាយុ៦៣ឆ្នាំ រស់នៅឃុំអូរក្រៀល ស្រុកកំពង់ត្រាច ខេត្តកំពត។ (អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តកំពត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

អ៊ុក សេង មានអាយុ៦៣ឆ្នាំ និងជាកូនច្បង ក្នុងចំណោមបងប្អូនទាំង៧ នាក់។ សេង មានស្រុកកំណើតនៅឃុំអូរក្រៀល ស្រុកកំពង់ត្រាច ខេត្តកំពត។ សេងបានរៀបរាប់ថា ខ្ញុំរៀនសូត្រត្រឹមថ្នាក់ទី២ ដោយសារខ្ញុំត្រូវនៅមើលថែរក្សាម្តាយដែលមានជំងឺ ហើយម្យ៉ាងទៀតជីវភាពគ្រួសាររបស់ខ្ញុំខ្វះខាត។ នៅក្នុងអំឡុងឆ្នាំ ១៩៦៨ ខ្ញុំជាមួយម្តាយខ្ញុំបានទៅរកស៊ីលក់ផ្លែឈើ នៅខេត្តព្រះសីហនុ។ មិនយូរប៉ុន្មានក៏មានការធ្វើរដ្ឋប្រហារទម្លាក់ សម្តេច ព្រះនរោត្តម សីហនុ ហើយសម្តេច ព្រះនរោត្តម សីហនុ ក៏បានធ្វើសេចក្តីអំពាវនាវឲ្យកូនចៅចូលព្រៃតស៊ូ ទាមទារអំណាចឲ្យព្រះអង្គវិញ។ នៅពេលនោះ សង្គ្រាមរវាងទាហានខ្មែរក្រហម និងលន់ នល់ ក៏បានកើតឡើង។

នៅពេលមានការវាយប្រហារគ្នា ខ្ញុំនិងគ្រួសារបានរត់ភៀសខ្លួនទៅខេត្តកំពតវិញ។ នៅកំពត ឪពុកម្តាយខ្ញុំបន្តរកស៊ីលក់ផ្លែឈើនៅផ្សារកំពត។ ខ្ញុំរស់នៅនោះបានរយៈពេល ២ខែ យោធាខ្មែរក្រហមបានវាយចូលមកកៀកក្រុងកំពត ធ្វើឲ្យគ្រួសារខ្ញុំកាន់តែមានភាពភ័យខ្លាចនិងព្រួយបារម្ភស្របពេលដែលទាហានលន់ នល់ បាក់ទ័ពដកថយចូលក្នុងក្រុងកំពតវិញ។

ដោយសារសភាពការចលាចលខ្លាំងឪពុកម្ដាយខ្ញុំបានសម្រេចចិត្តរៀបចំអីវ៉ាន់ ហើយនាំកូនៗទៅនៅក្រុងព្រះសីហនុវិញ ដោយយើងត្រូវជិះរ៉ឺម៉កពីខេត្តកំពតទៅកាន់ខេត្តព្រះសីហនុ។ នៅពេលដែលទៅដល់ទីនោះយើងមិនមានកន្លែងស្នាក់នៅទេ ព្រោះយើងមិនមានផ្ទះសម្បែង ថែមទាំងមិនមានអង្ករសម្រាប់ដាំបាយហូបទៀត។ ឪពុកម្ដាយខ្ញុំសម្រេចធ្វើខ្ទមតូចល្មមស្នាក់នៅជាបណ្ដោះអាសន្ន។ ឪពុកខ្ញុំមានមងនេសាទត្រីនៅសមុទ្រ ហើយបានត្រីខ្លះយកទៅដូរស្រូវអង្ករហូប និងយកទៅលក់បានប្រាក់បន្តិចបន្តួច។ នៅទីនោះបានប្រហែលជា ៣សប្ដាហ៍ ម្ដាយរបស់ខ្ញុំចាប់ផ្ដើមប្រកបរបរកស៊ីលក់អីវ៉ាន់ និងផ្លែឈើនៅខេត្តព្រះសីហនុដូចកាលពីមុនៗ ឪពុកម្ដាយខ្ញុំរកស៊ីបានមួយរយៈខ្វីកងទ័ព លន់ នល់ ក៏បាក់ទ័ព ហើយយោធាខ្មែរក្រហមក៏ចូលមកកៀរប្រជាជនឲ្យទៅរស់នៅក្នុងស្រុកភូមិស្រុករៀងៗខ្លួនវិញ។ គ្រួសាររបស់ខ្ញុំបានធ្វើដំណើរមកដល់ស្រុកព្រៃនប់ យោធាខ្មែរក្រហមក៏ឃាត់ខ្លួន ហើយបានសួរឪពុកខ្ញុំអំពីប្រវត្តិរូប ដែលមានសំណួរដូចជា តើពីមុនមិត្តធ្វើការងារអ្វី? តើមានបងប្អូនធ្លាប់ធ្វើជាមន្ត្រីរាជការឬទេ? តើអ្នកគឺគ្រូបង្រៀន គ្រូពេទ្យ ឬ និស្សិត? ឪពុករបស់ខ្ញុំបានប្រាប់យោធាខ្មែរក្រហមទាំងនោះថា ខ្ញុំមិនមានបងប្អូនធ្វើមន្ត្រីរាជការទេគឺបងប្អូនរបស់ខ្ញុំធ្វើតែស្រែប៉ុណ្ណោះ។ បន្ទាប់មក ខ្មែរក្រហមឲ្យគ្រួសាររបស់ខ្ញុំធ្វើដំណើរមកកាន់ភូមិមួយ។ យើងទទួលបានរបបអង្ករពីអង្គការក្នុងមួយថ្ងៃចំនួន១កំប៉ុងក្នុង១គ្រួសារ។ ខ្ញុំរស់នៅបានរយៈពេលប្រហែលជា ៣ថ្ងៃ ខ្មែរក្រហមក៏រឹតបណ្ដឹងនិងលែងឲ្យប្រជាជនហូបបាយឯកជនទៀត គឺត្រូវប្រមូលផ្ដុំគ្នាជាសហករណ៍។ គ្រួសាររបស់ខ្ញុំរស់នៅរួមគ្នានិងធ្វើការងាររួមគ្នា។ ខ្ញុំត្រូវបានគណៈកងចាត់តាំងឲ្យធ្វើការងារនៅក្នុងកងចល័ត។ ខ្ញុំរែកដីលើកទំនប់រនេសរយៈពេល ៣ខែ ដោយខិតខំប្រឹងធ្វើការដោយមិនហ៊ានឈប់សម្រាកឡើយ។ បន្ទាប់មក ប្រធានកងបានបញ្ជូនខ្ញុំឲ្យទៅនៅកោះស្លា ដោយធ្វើដំណើរដោយថ្មើរជើងរយៈពេល១ថ្ងៃ។ ខ្ញុំចេញដំណើរនៅវេលាម៉ោង៩ទៀបភ្លឺ ដោយមានសំបុត្របញ្ជាក់ពីគណៈឃុំឈ្មោះ តាម៉ៅ ថាខ្ញុំមកជួយរែកដីទប់ទំនប់នៅកោះស្លា។

ខ្ញុំបានសម្រាកនៅកោះស្លាមួយយប់ លុះព្រឹកឡើងប្រធានកងបានហៅខ្ញុំឲ្យឡើងទៅ រែកដី។ ខ្ញុំលើកទំនប់កោះស្លាបានមួយរយៈ ប្រធានកងបានបញ្ជូនខ្ញុំឲ្យទៅភូមិគងលាន់ និងព្រៃម៉ាឡេ ស្ថិតនៅជិតព្រំដែនប្រទេសវៀតណាម។ ខ្ញុំបានធ្វើការងារដកស្ទូងនៅទីនោះ ហើយទទួលបានរបប បបរ លាយជាមួយ ព្រលិត ក្រកួន ដើមចេក និងគល់ល្ហុង។

បន្ទាប់ពីដកស្ទូងរួច ប្រធានកងបានបញ្ជូនខ្ញុំឲ្យមកធ្វើការនៅភូមិរនេសវិញ។ ខ្ញុំធ្វើការនៅទីនោះបានប្រហែល៣ខែ កងទ័ពវៀតណាមបានវាយចូលមក។



អ៊ុក សេង អាយុ៦៣ឆ្នាំ រស់នៅឃុំអូរគ្រៀល ស្រុកកំពង់ត្រាច ខេត្តកំពត។ (អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តកំពត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

## ស្លុត វិចិត្រ, រមែក ទិន និង ហ៊ាន ពិសី

### ជួន សារិន

ជួន សារិន ភេទស្រី អាយុ៧៦ឆ្នាំ មានស្រុកកំណើតនៅភូមិត្រពាំងក្រសាំង ឃុំត្រពាំង ធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ។ សារិន សព្វថ្ងៃរស់នៅក្នុងភូមិអូរស្រម៉ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ សារិន បាននិយាយរៀបរាប់អំពីដំណើរនៃការតស៊ូរបស់ ខ្លួនថា ខ្ញុំគឺជាកូនស្រីពៅក្នុងចំណោមបងប្អូន១១នាក់នៅក្នុងគ្រួសារ។ ខ្ញុំបានរស់នៅជាមួយ ឪពុកម្ដាយក្នុងស្រុកកំណើតដោយប្រកបមុខរបរធ្វើស្រែ។

រហូតដល់ឆ្នាំ១៩៦៥ ខ្ញុំបានរៀបការ។ ខ្ញុំរស់នៅជាមួយប្ដីខ្ញុំ រហូតដល់ឆ្នាំ១៩៧២ ខ្មែរក្រហមចាប់ផ្ដើមប្រមូលប្រជាជននៅក្នុងស្រុកត្រាំកក់ចូលជាសហករណ៍ហូបបាយរួម និងធ្វើការងាររួម។ នៅក្នុងឆ្នាំ១៩៧២ ដដែលប្ដីរបស់ខ្ញុំបានចូលធ្វើជាកងទ័ពខ្មែរក្រហម។ កាលណោះប្ដីរបស់ខ្ញុំត្រូវបានបញ្ជូនទៅវាយនៅសមរភូមិ ដូច្នេះខ្ញុំក៏បែកពីប្ដីចាប់តាំងពីពេលនោះមក។ ខ្ញុំធ្វើស្រែនៅក្នុងសហករណ៍ និងដាំដំណាំផ្គត់ផ្គង់ឲ្យចុងភៅនៅក្នុងសហករណ៍។ បន្ទាប់មក ឪពុកក្មេករបស់ខ្ញុំបានមកយកខ្ញុំ និងកូនទៅនៅឃុំកំណប ស្រុកគិរីវង់ ដែលជាស្រុកកំណើតខាងប្ដីរបស់ខ្ញុំវិញ។

កាលណោះនៅភូមិស្រុកប្ដីខ្ញុំមិនទាន់ចូលជាសហករណ៍ទេ។ ខ្ញុំទៅនៅទីនោះបានរយៈពេល៥ខែ ខ្មែរក្រហមចាប់ផ្ដើមប្រមូលប្រជាជនក្នុងឃុំកំណប់ឲ្យចូលជាសហករណ៍។ នៅក្នុងឆ្នាំ១៩៧៦ ខ្ញុំបានទទួលដំណឹងថាប្ដីរបស់ខ្ញុំបានស្លាប់នៅសមរភូមិ។



ជួន សារិន អាយុ៧៦ឆ្នាំ ស្រុកកំណើតនៅភូមិត្រពាំងក្រសាំង ឃុំត្រពាំង ធំខាងជើង ស្រុកត្រាំកក់ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារ)

ចំណែកឯខ្ញុំបន្តរស់នៅជាមួយកូនៗក្នុងសហករណ៍។ កាលណោះ ខ្ញុំឃើញមានប្រជាជនថ្មី ដូចជា ជនជាតិចិនទាំងគ្រួសារៗ មានកូនមានប្ដីដែលជម្លៀសមកពីទីក្រុងភ្នំពេញ។ បន្ទាប់មកប្រធានសហករណ៍ឲ្យខ្ញុំនៅគ្រប់គ្រងជនជាតិចិន និងជួយបង្រៀនជនជាតិចិនទាំងនោះឲ្យចេះ ស្ទូង ដកសំណាប ច្រូត និងបង្រៀនភ្ជួរស្រែដល់ពួក។ ក្រុមគ្រួសារចិនដែលជម្លៀសមកពីភ្នំពេញ មានចំនួន១០គ្រួសារដែលខ្ញុំត្រូវមើលការខុសត្រូវ។

បន្ទាប់ពីខ្ញុំបង្រៀនក្រុមគ្រួសារចិនទាំងនោះឲ្យចេះធ្វើការហើយ ជនជាតិចិនទាំងនោះ ស្រឡាញ់ចូលចិត្តខ្ញុំគ្រប់ៗគ្នា។ នៅថ្ងៃមួយ នាពេលយប់ម៉ោង ១ កន្លះយប់ កងឈ្លបមកចាប់ខ្ញុំ យកទៅបម្រុងសម្លាប់ចោល ដោយចោទខ្ញុំថាចូលដៃ ចូលជើងជាមួយចិនដែលមកពីភ្នំពេញ។ ប្រហែលជា៣ម៉ោង ខ្ញុំបាននិយាយ

ប្រាប់ឈ្លបថា បើអង្គការឲ្យខ្ញុំទៅនៅគ្រប់គ្រងចិនហើយ បើមិនឲ្យខ្ញុំត្រូវជាមួយចិន តើឲ្យខ្ញុំរស់នៅជាមួយគ្នាយ៉ាងម៉េចកើតលុះត្រាតែអង្គការឈប់ឲ្យខ្ញុំនៅជាមួយចិនទើបខ្ញុំលែងបាននៅជិតចិនទៀត។ បន្ទាប់មកខ្ញុំបន្តថា បើមិត្តចង់សម្លាប់ខ្ញុំក៏ សម្លាប់ចុះព្រោះខ្ញុំគ្មានសល់អីទៀតទេ ប្តីទៅសមរភូមិត្រូវស្លាប់ចោល ហើយឥឡូវនេះបើយកខ្ញុំមកសម្លាប់មួយទៀតក៏ស្លាប់ទៅចុះ។ ប្រសិនបើមិត្តមិនសម្លាប់ខ្ញុំទេ សូមឲ្យខ្ញុំត្រឡប់ទៅផ្ទះវិញ ព្រោះកូនរបស់ខ្ញុំនៅតូចណាស់ វាច្បាស់ជាយំរកខ្ញុំមិនខានទេ។ បន្ទាប់ពីពាក្យនេះ កងឈ្លបដែលចាប់ខ្ញុំយកទៅ ក៏ឲ្យខ្ញុំត្រឡប់មកផ្ទះវិញមើលកូនវិញ។

## ទិត នឿង

វិត នឿង ភេទស្រី អាយុ៥៧ឆ្នាំ មានស្រុកកំណើតនៅក្នុងភូមិត្រពាំងក្រសាំង ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ។ នឿង សព្វថ្ងៃរស់នៅក្នុងភូមិភូមិអូរស្រម៉ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ នឿង បាននិយាយរៀបរាប់ពីដំណើរការតស៊ូរបស់ខ្លួនក្នុងរបបខ្មែរក្រហមថា ខ្ញុំកំព្រាឪពុកតាំងពីតូចៗ។ ឪពុករបស់ខ្ញុំបានស្លាប់នៅសមរភូមិក្នុងឆ្នាំ១៩៧៦។ ចំណែកឯម្តាយខ្ញុំត្រូវក្លាយជាស្ត្រីមេម៉ាយរស់នៅក្នុងសហករណ៍ធ្វើស្រែលើកទំនប់ និងជីកប្រឡាយយ៉ាងលំបាក។

នៅចុងឆ្នាំ១៩៧៦ ខ្មែរក្រហមបញ្ជូនខ្ញុំទៅនៅកងកុមារនិងរស់នៅបែកចេញពីម្តាយ។ ការងារដែលខ្ញុំធ្វើជាប្រចាំនៅទីនោះ គឺកាប់ទន្ទ្រានខែត្រ ដីកដីដំបូក ដើម្បីយកមកលាយធ្វើជីដាក់ស្រែ។ ចំពោះការហូបចុកខ្ញុំទទួលរបបមិនបានគ្រប់គ្រាន់ទេ គឺក្នុងមួយថ្ងៃខ្ញុំហូបបបរ២ដង គឺពេលថ្ងៃត្រង់ម្តង និងពេលល្ងាចម្តងទៀត។ នៅក្នុងសហករណ៍ដែលខ្ញុំរស់នៅ ខ្ញុំតែងតែឮដំណឹងថាបាត់មនុស្សរហូត ដោយអ្នកខ្លះនិយាយថាខ្មែរក្រហមយកទៅសម្លាប់ចោល ឯអ្នកខ្លះទៀតនិយាយថាខ្មែរក្រហមយកទៅរៀនសូត្រ។ ជិនាន់នោះការរៀបការ គឺខ្មែរក្រហមរៀបការជាគូៗ ដោយរៀបការម្តងៗមាន៧គូទៅ១០គូ។ កាលណោះអង្គការរៀបចំពិធីរៀបការនៅក្នុងមន្ទីរឃុំត្រពាំងធំខាងជើង។ អ្នកខ្លះបានរៀបជាមួយប្រជាជនថ្មី ឯខ្លះទៀតបានរៀបជាមួយប្រជាជនចាស់ដូចគ្នា។ ខ្ញុំរស់នៅក្នុងកងកុមាររហូតដល់វៀតណាមវាយចូលមកនៅឆ្នាំ១៩៧៩។ បន្ទាប់ពីវៀតណាមបានវាយចូលមកខ្ញុំបានទៅរកម្តាយ និងបានជួបជុំជាមួយប្អូនៗរបស់ខ្ញុំនៅឯស្រុកកំណើតវិញ។



វិត នឿង អាយុ៥៧ឆ្នាំ មានស្រុកកំណើតនៅក្នុងភូមិត្រពាំងក្រសាំង ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ។ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា )

## លេង ឌីវើន

លេង ឌីវើន ភេទស្រី អាយុ៦១ឆ្នាំ មានស្រុកកំណើតនៅក្នុងស្រុកស្នួល ខេត្តក្រចេះ។ វើន សព្វថ្ងៃរស់នៅក្នុងភូមិអូរតាម៉ឹង ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ វើន បាននិយាយរៀបរាប់អំពីបទពិសោធន៍របស់ខ្លួនថា ខ្ញុំកំព្រាឪពុកម្តាយតាំងតែពីតូច គឺខ្ញុំរស់នៅជាមួយបងស្រីរបស់ខ្ញុំ។ ខ្ញុំមានបងប្អូនបង្កើតចំនួន៦នាក់ ប៉ុន្តែសព្វថ្ងៃនេះនៅសល់តែ៣នាក់ប៉ុណ្ណោះ។ ខ្ញុំបានរស់នៅជាមួយបងស្រីរបស់ដល់ខ្ញុំមានអាយុ១៣ឆ្នាំ។ នៅក្នុងសម័យខ្មែរក្រហម ខ្ញុំចូលទៅធ្វើការនៅក្នុងកងកុមារ។ នៅទីនោះប្រធានកងកុមារបានប្រើខ្ញុំឲ្យរើសអាចម៍គោ និងកាប់ដើម



លេង ឌីវើន អាយុ៦១ឆ្នាំ មានស្រុកកំណើតនៅក្នុងស្រុកស្នួល ខេត្តក្រចេះ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារ)

ទន្ទ្រានខែត្រដើម្បីធ្វើជីដាក់ស្រែ។ ខ្ញុំនៅក្នុងកងកុមារបានមួយរយៈ មិត្តនារី អេន ក៏យកខ្ញុំទៅធ្វើជានីរសាររបស់គាត់។ កាលណោះខ្ញុំនៅតូចណាស់ ខ្ញុំមិនទាន់ដឹងអ្វីច្រើនទេ។ ខ្មែរក្រហមឲ្យខ្ញុំស្ពាយកាំភ្លើងអូសដី។ នៅពេលមានប្រជុំ មិត្តនារី អេន ធ្វើដំណើរដោយជិះដីរី និងបាននាំខ្ញុំទៅជាមួយគាត់ដែរ។ មិត្តនារី អេន មិនទាន់មានគ្រួសារទេ គឺគាត់ជាក្រមុំសៅកែ (ក្រមុំចាស់)។ នៅពេលខ្ញុំធ្វើដំណើរទៅដល់កន្លែងប្រជុំ មិត្តនារី អេនឲ្យខ្ញុំនៅចាំគាត់នៅរោងចុងភៅ និងមានផ្ទះមួយខ្ទង់សម្រាប់ស្នាក់នៅ។ ខ្ញុំបានបោកសម្លៀកបំពាក់ និងរៀបចំបាយសម្ល ទុកឲ្យគាត់ពេលចេញពីប្រជុំវិញ។ ពេលខ្លះ មេខ្មែរក្រហមធំៗ មកហូបបាយជាមួយ មិត្តនារី អេន នៅកន្លែងស្នាក់នៅដែរ។ ខ្ញុំទទួលបានបាយ និងម្ហូបគ្រប់គ្រាន់។ ចំណែកប្រជាជននៅក្នុងសហករណ៍ហូបមិនគ្រប់គ្រាន់ទេ។

## ឌុច សារិទ្ធ

ឌុច សារិទ្ធ ភេទប្រុស អាយុ៦៨ មានទីកន្លែងកំណើតនៅភូមិព្រៃកវាំង ឃុំទឹកហូត ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។ សារិទ្ធ បច្ចុប្បន្នរស់នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ សារិទ្ធបាននិយាយថា «កាលពីកុមារខ្ញុំមានបងប្អូន១១នាក់ ប៉ុន្តែស្លាប់អស់៦នាក់ នៅសល់តែ៥នាក់ប៉ុណ្ណោះ។ នៅឆ្នាំ១៩៧០ ខ្ញុំបានបែកពីនៅឪពុកម្តាយ ក្រោយពេលដែលលន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ។ កាលណោះរបស់ភូមិខ្ញុំស្ថិតនៅក្នុងតំបន់រំដោះខ្មែរក្រហម។ ដូច្នេះរាល់ការចេញចូល ឬ ទៅរកស៊ីឆ្ងាយជិត គឺត្រូវធ្វើលិខិតអនុញ្ញាត ប្រសិនបើមិនធ្វើលិខិតយើងមិនអាចធ្វើដំណើរបានឡើយ។ ក្រោយមកនៅឆ្នាំ១៩៧៣ ខ្ញុំត្រូវបានខ្មែរក្រហមជ្រើសរើសឲ្យចូលធ្វើជាកងឈ្លបស្រុក។ តួនាទីរបស់ឈ្លបស្រុកកាលណោះ គឺដើរត្រួតពិនិត្យការពារនៅតាមភូមិ។

លុះដល់ឆ្នាំ១៩៧៥ ពេលដែលខ្មែរក្រហមវាយរំដោះបានទីក្រុងភ្នំពេញ ខ្មែរក្រហមបញ្ជូនខ្ញុំទៅភូមិភាគឦសានរួមមាន ខេត្តស្ទឹងត្រែង, រតនគិរី និងមណ្ឌលគិរី។ កាលណោះខ្ញុំនៅក្រោមការគ្រប់គ្រងរបស់កងវរសេនាធំ៨២ កងពល៨០១ ដែលមានតាសារឿន (ហៅតា០៥) គឺជាប្រធានកងពល។ ខ្ញុំបានដើរល្បាតនៅតាមព្រំដែនខ្មែរ- ឡាវ ក្នុងស្រុកសៀមប៉ាង។ គោលបំណងដែលខ្មែរក្រហមបញ្ជូនកម្លាំងមកការពារតាមព្រំដែន ឡាវ គឺការពារកុំឲ្យជនជាតិ ឡាវលួចចូលមកបាញ់សត្វព្រៃនៅដីខ្មែរ និងការពារសុវត្ថិភាពនៅតាមព្រំដែន។ កាលនោះក៏មានបងប្អូនជនជាតិរស់នៅទីនោះដែរ ប៉ុន្តែប្រជាជនទាំងនោះគឺរស់នៅដាច់ដោយឡែកពីកងទ័ព។ ជនជាតិភាគតិចនៅទីនោះ មានដូចជា ស្លួយ និង ជង។



ឌុច សារិទ្ធ អាយុ៦៨ បច្ចុប្បន្នរស់នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារ)

នៅពេលដែលខ្ញុំធ្វើជាកងទ័ព ខ្ញុំមិនសូវបានចូលប្រយុទ្ធក្នុងសមរភូមិទេ។ អង្គភាពបានបញ្ជូនខ្ញុំឲ្យទប់ទល់ជាមួយវៀតណាមម្តងម្កាល ហើយពេលចប់ប្រយុទ្ធក៏ត្រឡប់មកអង្គភាពវិញ។ ខ្ញុំនៅព្រំដែនឡាវរហូតដល់ឆ្នាំ១៩៨០ ទើបខ្មែរក្រហមបញ្ជូនខ្ញុំឲ្យមកនៅឈរជើងនៅមុំបីបានមួយសប្តាហ៍ ក៏ផ្លាស់មកនៅខាងស្រុកជាំក្សាន្ត ខេត្តព្រះវិហារវិញ។ នៅឆ្នាំ១៩៨៣ ខ្មែរក្រហមបញ្ជូនខ្ញុំឲ្យមកខាងជាំស្មា និងបានបំបែកទៅជាកងពលថ្មី គឺកងពល៧៨៥ ក្រោមការគ្រប់គ្រងរបស់ តាតេម។ ជារឿយៗអង្គភាពបានបញ្ជូនខ្ញុំឲ្យទៅឈរជើងនៅមុខកំពូលដែរ ដោយត្រូវធ្វើដំណើរដោយថ្មើរជើង។ នៅមុខកំពូលកងទ័ពយើងគឺមានស្បៀងអាហារ និងពេលខ្លះមានទំនាក់ទំនងទិញពីប្រជាជន និងប្រជាជនជួយឧត្ថម្ភ។



គុយ ភាន់ អាយុ៨៣ឆ្នាំ សព្វថ្ងៃរស់នៅក្នុងភូមិយាងត្បូង ឃុំអន្លង់វែង ស្រុកអន្លង់វែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារ)

## គុយ ភាន់

គុយ ភាន់ភេទស្រី អាយុ៨៣ឆ្នាំ មានស្រុកកំណើតនៅក្នុងស្រុកអូររាំងឪ ខេត្តកំពង់ចាម។ សព្វថ្ងៃ ភាន់ រស់នៅក្នុងភូមិយាងត្បូង ឃុំអន្លង់វែង ស្រុកអន្លង់វែង។ ភាន់ បាននិយាយរៀបរាប់ពីការតស៊ូរបស់ខ្លួនក្នុងសម័យខ្មែរក្រហមថា ខ្ញុំគឺជាកូនកំព្រាឪពុកម្តាយតាំងពីតូចដោយបានម្តាយមីងយកមកចិញ្ចឹម។ ខ្ញុំរស់នៅជាមួយម្តាយមីងរហូតដល់ធំដឹងក្តី គាត់ក៏យកខ្ញុំទៅនៅវត្តដើម្បីឲ្យបានរៀនសូត្រ។ ខ្ញុំបួសរៀនបានរយៈពេល ២វស្សា ក៏សុំលោកគ្រូសង្ឃរាជសឹក។ បន្ទាប់ពីសឹកហើយខ្ញុំក៏ត្រឡប់មករស់នៅផ្ទះជាមួយម្តាយមីងវិញ។ ខ្ញុំនៅជាមួយម្តាយមីងបានមួយរយៈ គាត់ក៏ទៅដណ្តឹងប្រពន្ធឲ្យខ្ញុំ។ ក្រោយពីខ្ញុំរៀបការហើយ ខ្ញុំនិងប្រពន្ធបានទៅធ្វើការស៊ីឈ្នួលជៀរជ័រកៅស៊ូឲ្យបារាំង។ ជំនាន់នោះក្នុងមួយថ្ងៃខ្ញុំទទួលបានប្រាក់តែ២៥រៀលតែប៉ុណ្ណោះ។ ចូលដល់ឆ្នាំ១៩៧០ សភាពការត្រូវបានផ្លាស់ប្តូរទាំងស្រុងដោយ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ពីតំណែង។ តាំងពីកើតមានព្រឹត្តិការណ៍រដ្ឋប្រហារមកប្រទេសជាតិចាប់ផ្តើមកើតសង្គ្រាម។ បន្ទាប់មកខ្ញុំក៏ចូលធ្វើកងទ័ពខ្មែរក្រហម។ ខ្ញុំត្រូវបានបញ្ជូនទៅហាត់រៀនយុទ្ធសាស្ត្រធ្វើសង្គ្រាមនៅខាងខេត្តព្រៃវែង។ កាលណោះខ្ញុំនៅកងពលលេខ៨៩។ នៅចន្លោះឆ្នាំ១៩៧៣ និងឆ្នាំ១៩៧៤ ខ្ញុំរួមទាំងកងកម្លាំងជាច្រើននាក់ទៀតបានចេញទៅឈរជើងនៅខាងព្រែកតាមាក់។ ខ្ញុំឈរជើងនៅទីនោះរហូតដល់ឆ្នាំ១៩៧៥ ខ្មែរក្រហមក៏ទទួលបានជ័យជម្នះ។

បន្ទាប់ខ្មែរក្រហមទទួលបានជ័យជម្នះហើយ ខ្ញុំក៏ត្រឡប់មករកប្រពន្ធកូននៅឯស្រុកកំណើតវិញ។ ខ្ញុំបានធ្វើដំណើរមកដល់ផ្ទះជួបជុំគ្រួសាររស់នៅជាមួយគ្នាមិនបានយូរប៉ុន្មានផងខ្មែរក្រហមចាប់ផ្តើមប្រមែប្រមូលប្រជាជនចូលជាសហករណ៍ ហើយខ្ញុំត្រូវបានបញ្ជូនឲ្យទៅខាងភ្ជួររាស់ដីស្រែវិញ។ ចំណែកឯប្រពន្ធខ្ញុំនៅធ្វើការនៅក្នុងសហករណ៍ ហើយកូនៗដាក់នៅក្នុងកងកុមារ។ នៅឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមវាយចូលមក ខ្ញុំបានរត់ទៅរកប្រពន្ធកូនដើម្បីធ្វើដំណើរត្រឡប់ទៅស្រុកកំណើតវិញ។



តាក គង់ អាយុ៧៣ឆ្នាំ សព្វថ្ងៃរស់នៅក្នុងភូមិយាងត្បូង ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្ដរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## តាក គង់

តាក គង់ ភេទស្រី អាយុ៧៣ឆ្នាំ មានស្រុកកំណើតនៅភូមិតាអូរ ឃុំតាអូរ ស្រុកគិរីវង្ស ខេត្តតាកែវ។ សព្វថ្ងៃ គង់ រស់នៅក្នុងភូមិយាងត្បូង ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្ដរមានជ័យ។ គង់ បានបន្តរៀបរាប់ពីប្រវត្តិតស៊ូរបស់ខ្លួនក្នុងរបបខ្មែរក្រហមថា ខ្ញុំគឺជាកូនស្រីទោលនៅក្នុងគ្រួសារមួយដែលមានជីវភាពមធ្យម។ ឪពុកម្ដាយរបស់ខ្ញុំប្រកបមុខធ្វើស្រែចម្ការដើម្បីទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃ។

កាលខ្ញុំនៅពីកុមារ ខ្ញុំរៀនសូត្របានបន្តិចបន្តួចប៉ុណ្ណោះ។ ខ្ញុំរស់នៅជាមួយឪពុកម្ដាយរហូតដល់ឆ្នាំ១៩៦៥ ម្ដាយរបស់ខ្ញុំក៏ឲ្យខ្ញុំរៀបការ។ នៅក្នុងឆ្នាំ១៩៧០ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះនរោត្តម សីហនុ ពីតំណែង។ បន្ទាប់មកប្ដីរបស់ខ្ញុំក៏ចូលធ្វើជាកងទ័ព លន់ នល់។ ចាប់ពីពេលនោះមកនៅក្នុងស្រុកភូមិរបស់ខ្ញុំចាប់ផ្ដើមមានការទម្លាក់គ្រាប់បែក។ នៅឆ្នាំ១៩៧៣ ខ្ញុំបានភៀសទៅនៅភ្នំពេញដោយជិះកាណូត។ ខ្ញុំរស់នៅភ្នំពេញរហូតដល់ឆ្នាំ១៩៧៥។ ពេលខ្មែរក្រហមទទួលបានជ័យជម្នះ ខ្មែរក្រហមបានចាប់ប្ដីខ្ញុំយកទៅសម្លាប់ចោល។ ចំណែកខ្ញុំត្រឡប់មករស់នៅជាម្ដាយឪពុកនៅស្រុកកំណើតវិញ។

នៅចន្លោះឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៧ ខ្មែរក្រហមជម្លៀសខ្ញុំឲ្យទៅនៅសហករណ៍ស្រុកត្រាំកក់ ខេត្តតាកែវ។ ការងារដែលខ្ញុំធ្វើជាប្រចាំនៅទីនោះគឺលើកទំនប់ ជីកប្រឡាយ និងធ្វើស្រែ។ ចំពោះការហូបចុក ខ្ញុំមានការខ្វះខាតយ៉ាងខ្លាំងដោយមួយថ្ងៃខ្ញុំហូបបានតែបបរពីរពេលតែប៉ុណ្ណោះ។ ការរស់នៅក្នុងសហករណ៍មានការលំបាកណាស់ គឺខ្ញុំហូបមិនគ្រប់គ្រាន់ និងមិនសូវមានពេលសម្រាកទេ។ ខ្ញុំបន្តរស់នៅសហករណ៍រហូតដល់ឆ្នាំ១៩៧៩ កងទ័ពវៀតណាមក៏វាយចូលមក ហើយខ្ញុំក៏ត្រឡប់ទៅស្រុកកំណើតវិញ។

## នៅ រិន

នៅ រិន ភេទស្រី អាយុ៦០ឆ្នាំ មានស្រុកកំណើតនៅក្នុងភូមិកកោះ ឃុំអង្គប្រាសាទ ស្រុកគិរីវង់ ខេត្តតាកែវ។ សព្វថ្ងៃ រិន រស់នៅក្នុងភូមិទួលសាលា ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្ដរមានជ័យ។ រិន បាននិយាយរៀបរាប់អំពីបទពិសោធន៍របស់ខ្លួនក្នុងរបបខ្មែរក្រហមថា ខ្ញុំកំព្រាម្ដាយតាំងពីតូច។ គ្រួសាររបស់ខ្ញុំគឺជាគ្រួសារកសិករ។ ខ្ញុំ ត្រូវរ៉ាប់រងការងារស្រាលធ្ងន់ទាំងអស់នៅក្នុងគ្រួសារ។



នៅ រិន អាយុ៦០ឆ្នាំ សព្វថ្ងៃរស់នៅក្នុងភូមិទួលសាលា ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្ដរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



នៅ រិន អាយុ៦០ឆ្នាំ សព្វថ្ងៃរស់នៅក្នុងភូមិទួលសាលា ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងឆ្នាំ១៩៧០ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីតំណែង។ បន្ទាប់មកស្រុកទេសក៏ចាប់ផ្តើមមានសង្គ្រាម។ មិនត្រឹមតែប៉ុណ្ណោះនៅក្នុងភូមិរបស់ខ្ញុំក៏មានការទម្លាក់គ្រាប់បែកយ៉ាងសន្ធោសន្ធៅបង្កឲ្យខូចខាតទ្រព្យសម្បត្តិប្រជាជនអស់ជាច្រើន។ នៅចន្លោះឆ្នាំ១៩៧៣និងឆ្នាំ១៩៧៤ កងទ័ពរំដោះខ្មែរក្រហមបានចូលមកជម្លៀសប្រជាជនចេញស្រុកកំណើត។ កាលណោះខ្មែរក្រហមបានជម្លៀសគ្រួសារខ្ញុំ និងប្រជាជនទៅនៅស្រុកត្រាំកក់ ខេត្តតាកែវ។ នៅក្នុងឆ្នាំ១៩៧៥ ខ្ញុំបានទទួលដំណឹងថាខ្មែរក្រហមទទួលបានជ័យជម្នះ។ បន្ទាប់ពីទទួលបានជ័យជម្នះខ្មែរក្រហមចាប់ផ្តើមប្រមូលប្រជាជនចូលជាសហករណ៍។ ខ្ញុំត្រូវបានបញ្ចូលទៅនៅក្នុងកងចល័តយុវជនយុវនារី។ ចំណែកឯឪពុករបស់ខ្ញុំត្រូវបានបញ្ជូនទៅនៅកន្លែងផ្សេង។ ការងារដែលខ្ញុំត្រូវធ្វើនៅក្នុងកងចល័តយុវជនយុវនារីគឺ លើកភ្លឺស្រែ លើកទំនប់ និងជម្រះស្មៅនៅក្នុងបឹងដើម្បីរានដីធ្វើស្រែប្រាំង។ កាលណោះយើងធ្វើការបែកជាក្រុម ដោយក្នុងមួយក្រុមមានសមាជិកចំនួន១២នាក់។ នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបញ្ជូនខ្ញុំមកស្រុកព្រះនេត្រព្រះ ក្នុងខេត្តបន្ទាយមានជ័យ។ កាលណោះស្រុកព្រះនេត្រព្រះស្ថិតនៅក្រោមការគ្រប់គ្រងរបស់យាយ ចែម។ ខ្ញុំរស់នៅស្រុកព្រះនេត្រព្រះអស់រយៈពេល២ឆ្នាំ កងទ័ពវៀតណាមបានវាយចូលមកដល់ខេត្តបាត់ដំបង។ ខ្ញុំសម្រេចចិត្តរត់តាមបងៗនៅក្នុងកងចល័តចូលព្រៃឆ្ពោះទៅព្រំដែនថៃ។ ខ្ញុំធ្វើដំណើរអស់រយៈពេលជាច្រើនខែជាមួយប្រជាជនទៅដល់ស្រុកបន្ទាយអំពិល ក្នុងខេត្តឧត្តរមានជ័យ។ ខ្ញុំរស់នៅទីនោះដល់ឆ្នាំ១៩៨២ និងមានគ្រួសារ។ បន្ទាប់ពីរស់នៅជាមួយប្តីបានមួយឆ្នាំខ្ញុំក៏ បែកគ្នាដោយសារវៀតណាមវាយចូលមកដល់។ ខ្ញុំបានឡើងជិះឡានថៃទាំងយប់ដើម្បីធ្វើដំណើរឆ្ពោះទៅជំរំថៃ ឯប្តីរបស់ខ្ញុំត្រូវចុះទៅដឹកជញ្ជូនសម្ភារទៅឲ្យកងទ័ពនៅសមរភូមិ។ តាំងពីកើតមានព្រឹត្តិការណ៍នោះមក ខ្ញុំក្លាយជាស្ត្រីមេម៉ាយរហូតមកដល់បច្ចុប្បន្ន។

## គ្រួច វន

គ្រួច វន ភេទស្រី អាយុ៦១ឆ្នាំ មានទីកន្លែងកំណើតនៅភូមិត្បែង ឃុំព្រះដាក់ ស្រុកបន្ទាយស្រី ខេត្តសៀមរាប។ បច្ចុប្បន្នវនរស់នៅឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ វនបាននិយាយរៀបរាប់ថា កាលពីកុមារខ្ញុំមិនបានរៀនសូត្រទេ ដោយសារតែប្រទេសកើតមានសង្គ្រាម។

ខ្ញុំចងចាំថា នៅក្នុងភូមិរបស់ខ្ញុំមានការជ្រើសរើសយុវជនយកទៅធ្វើការនៅតាមសហករណ៍ហើយក្នុងចំណោមនោះក៏មានខ្ញុំម្នាក់ដែរ។ កិច្ចការងារដែលខ្មែរក្រហមដាក់ឲ្យខ្ញុំធ្វើរួមមាន ដកស្ទូងស្រូវលើកទំនប់ និងជីកប្រឡាយ។ កាលណោះ ខ្មែរក្រហមមិនបានបញ្ជូនខ្ញុំទៅស្រុកឆ្ងាយទេ។ ខ្ញុំនៅធ្វើការងារនៅក្នុងកងចល័តនៅជុំវិញភូមិ។ ចំពោះការហូបចុកនៅជំនាន់នោះខ្ញុំមិនសូវខ្វះខាតទេ ក្នុងសហករណ៍ខ្ញុំហូបបាយគ្រប់គ្រាន់។ ក្នុងមួយសប្តាហ៍ខ្ញុំទទួលបានបង្អែមម្តងគឺបបរល្ពៅ និងសណ្តែកខៀវ។ ចំណែកសម្ភារធ្វើស្រែ

សម័យនោះគ្មានអ្វីក្រៅពី ចប បង្គី និង នង្គ័ល ទេ។ សម្រាប់កន្លែងស្នាក់នៅគឺ មនុស្សស្រី និងមនុស្សប្រុស រស់នៅផ្សេងៗពីគ្នា។ នារីៗដេកនៅក្នុងរោងមួយ ចំណែកបុរសៗរោងមួយផ្សេងទៀត។ កាលណោះខ្ញុំចាំមិនថាខ្ញុំធ្វើការនៅក្នុងសហករណ៍ដល់ត្រឹមឆ្នាំណាទេ គឺខ្ញុំគ្រាន់តែដឹងថានៅរដូវប្រូតកាត់ ខ្មែរក្រហមបានបញ្ជូនខ្ញុំឲ្យមកខាងឧត្តរមានជ័យ។ រថយន្តដឹកខ្ញុំមកដាក់នៅវត្តសំរោង ហើយខ្ញុំបានស្នាក់នៅទីនោះបានប្រហែលបីយប់។

បន្ទាប់មកទៀតខ្មែរក្រហមបញ្ជូនខ្ញុំឲ្យទៅនៅតាមព្រំដែនថៃ។ ខ្ញុំបន្តរស់នៅក្នុងព្រៃ ដោយយើងទទួលបានរបបហូបគ្រប់គ្រាន់។ ខ្ញុំរស់នៅក្នុងព្រៃតាមព្រំដែនខ្មែរ-ថៃ រហូតខ្ញុំរៀបការ។ លុះពេលយោធាខ្មែរក្រហមនៅអន្លង់វែងធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាល ខ្ញុំនិងគ្រួសារផ្លាស់មករស់នៅភូមិទួលសាលា រហូតដល់ពេលបច្ចុប្បន្ន។

## ជិន តឿ

ជិន តឿ ភេទប្រុស អាយុ៦២ឆ្នាំ មានស្រុកកំណើតនៅស្រុកមេសាង ខេត្តព្រៃវែង។ សព្វថ្ងៃ តឿ រស់នៅក្នុងភូមិយាងត្បូង ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ តឿ បាននិយាយរៀបរាប់ពីការតស៊ូរបស់ខ្លួនក្នុងជំនាន់ខ្មែរក្រហមថា កាលនៅពីក្មេងខ្ញុំរៀនសូត្របានតិចតួចណាស់ដោយសារតែជីវភាពគ្រួសារក្រីក្រ។

នៅក្នុងឆ្នាំ១៩៧៣ ភូមិរបស់ខ្ញុំចាប់ផ្តើមមានការទម្លាក់គ្រាប់ដោយ ទាហាន លន់ នល់។ បន្ទាប់មកគ្រួសារខ្ញុំរួមទាំងប្រជាជនត្រូវបានខ្មែរក្រហមជម្លៀសចេញពីភូមិឋាន។ នៅឆ្នាំ១៩៧៥ ខ្មែរក្រហមទទួលបានជ័យជម្នះ។ បន្ទាប់មកខ្មែរក្រហមចាប់ផ្តើមបង្កើតជាសហករណ៍ហូបរួម និងធ្វើការងាររួម។ នៅក្នុងឆ្នាំ១៩៧៥ ដដែល ខ្មែរក្រហមបញ្ជូនខ្ញុំទៅដាក់នៅក្នុងកងកុមារ។ ការងារដែលខ្ញុំធ្វើនៅពេលនោះគឺរើសអាចម៍គោ ចំណែកអាហារហូបចុកខ្ញុំទទួលបានបបរពីរពេលក្នុងមួយថ្ងៃ។ កុមារណាដែលទៅធ្វើការមិនទាន់ពេលត្រូវប្រធានដាក់ទោសដោយបង្អត់អាហារ។

នៅក្នុងឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានវាយចូលមកដល់ ខ្ញុំនិងប្រជាជនដទៃទៀតបានរត់ចូលព្រៃ។ ការធ្វើដំណើរតាមផ្លូវខ្ញុំជួបឧបសគ្គយ៉ាងច្រើន ថ្ងៃខ្លះខ្ញុំជួបកងទ័ពវៀតណាម ថ្ងៃខ្លះទៀតក៏អត់អាហារហូប។ នៅក្នុងឆ្នាំ១៩៨០ ខ្ញុំរួមទាំងប្រជាជនជាច្រើននាក់ទៀតបានធ្វើដំណើរត្រឡប់ទៅស្រុកកំណើតវិញ។ ពេលធ្វើដំណើរទៅដល់ក្នុងស្រុកមេសាងខ្ញុំឃើញកងទ័ពវៀតណាមច្រើនណាស់ ប៉ុន្តែកងទ័ពវៀតណាមមិនបានធ្វើបាបប្រជាជនទេ។ ខ្ញុំបានរស់នៅក្នុងស្រុកកំណើតរហូតដល់ឆ្នាំ១៩៨៤ ក៏រៀបការ។ បន្ទាប់ពីរៀបការរួច ខ្ញុំប្រកបរបរធ្វើស្រែចម្ការ និងចិញ្ចឹមសត្វ ទុកសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ។ នៅក្នុងឆ្នាំ១៩៩៨ ខ្ញុំបាននាំប្រពន្ធមកដងជ័រនៅព្រៃស្អាក ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ បន្ទាប់ពីខ្ញុំរស់នៅព្រៃស្អាករយៈពេល៥ឆ្នាំ ខ្ញុំក៏ផ្លាស់មករស់នៅក្នុងភូមិយាងត្បូងនេះរហូតមកដល់សព្វថ្ងៃ។



ជិន តឿ អាយុ៦២ឆ្នាំ សព្វថ្ងៃ តឿ រស់នៅក្នុងភូមិយាងត្បូង ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង

ផេង ពង្សរ៉ាស៊ី, គា រស្មី, សូ ហាន់ និង ផុន ស្រីពេជ្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តព្រៃវែងបានរៀបចំធ្វើវេទិកាប្រវត្តិសាស្ត្រគ្រួសារពីថ្ងៃទី ២៣ ដល់២៧ ខែវិច្ឆិកា ឆ្នាំ២០២១ ជាមួយអ្នករស់រានមានជីវិតក្រោយរបបខ្មែរក្រហមចំនួន១០នាក់ រស់នៅក្នុងភូមិក្រូចភូមិព្រៃក្រាំង ភូមិអន្លុង ភូមិពញាកើត ក្នុងឃុំជាងដែក និងឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ វេទិកានេះ បានធ្វើឡើងរយៈពេល ៥ថ្ងៃ តាមកម្មវិធីដែលបានគ្រោងទុក និងមានការព្រមព្រៀងគ្នាជាមុនជាមួយអ្នករស់រានមានជីវិតទាំង១០នាក់។ ជាកិច្ចចាប់ផ្តើមបុគ្គលិកជួបសម្ភាស និងស្តាប់រឿងរ៉ាវជីវិតរបស់គាត់ និងបន្ទាប់ក្រុមការងារប្រើប្រាស់តារាងសំណួរស្ទាបស្ទង់មតិដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីពិភាក្សាពីបញ្ហាសុខភាពរបស់គាត់ក្នុងគោលបំណងធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតក្រោយរបបខ្មែរក្រហម។ បន្ទាប់មក អ្នករស់រានមានជីវិតម្នាក់ៗ ទទួលបានប្រអប់កាដូអនុស្សាវរីយ៍ម្នាក់មួយប្រអប់។ ដំណើរការនេះប្រព្រឹត្តទៅដោយមានការឯកភាពពីអ្នករស់រានមានជីវិតទាំងអស់ក្នុងការជួបជុំ ការស្នើសុំថតសំឡេងក្នុងពេលសម្ភាស និងការថតរូប។ ខាងក្រោមនេះ ជាសេចក្តីសង្ខេបពីបទពិសោធន៍របស់អ្នករស់រានមានជីវិតទាំង១០នាក់ ដែលក្នុងចំណោមអ្នកទាំង១០នាក់ អ្នករស់រានមានជីវិតម្នាក់ឈ្មោះ ភោគ តាំង គឺជាអតីតគណៈឃុំក្នុងរបបខ្មែរក្រហម៖

## អេង ថូ

អេង ថូ ភេទប្រុស អាយុ៧១ឆ្នាំ រស់នៅភូមិព្រៃក្រាំង ឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ អេង ថូ កើតនៅឆ្នាំ១៩៤៦ ក្នុងគ្រួសារមានជីវភាពធូរធារមួយ។ គាត់មានបងប្អូនបង្កើត ៨ នាក់ ស្រី ៣ នាក់។ នៅអាយុ១០ឆ្នាំ ថូបានចូលរៀននៅវត្តពេជ្ជរតន៍ ដែលមានព្រះសង្ឃជាគ្រូបង្រៀន។ ពីរឆ្នាំក្រោយមក ថូបានបន្តការសិក្សានៅសាលាបឋមសិក្សាពេជ្ជរតន៍ ហើយគាត់បានបន្តការសិក្សារបស់គាត់នៅអនុវិទ្យាល័យកំពង់ត្របែក នៅឆ្នាំ១៩៦៣។ ថូបានបញ្ចប់ការសិក្សារបស់ខ្លួនត្រឹមថ្នាក់ទី៣ចាស់។ ក្នុងឆ្នាំ១៩៧០ បន្ទាប់ពីមានរដ្ឋប្រហារទម្លាក់សម្តេចសីហនុ ថូ រួមជាមួយយុវជនជាច្រើននាក់ទៀតនៅក្នុងភូមិបាននាំគ្នាចូលរួមក្នុងចលនាបដិវត្តន៍នៅក្នុងវត្តពពេល។ អំឡុងពេល



អេង ថូ អាយុ៧១ឆ្នាំ រស់នៅភូមិព្រៃក្រាំង ឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ។ (ផេង ពង្សរ៉ាស៊ី/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

វិកហាត់ក្បួនធ្វើសង្គ្រាម ទាហាន ធីវគី បានយករថក្រោះមកកម្ទេចក្រុមបដិវត្តន៍ ដែលជាហេតុធ្វើឲ្យ ជូ សម្រេចចិត្តត្រឡប់មកភូមិកំណើតវិញ។ ក្នុងឆ្នាំ១៩៧២ ប្រធានសហករណ៍ បានប្រាប់ឲ្យប្រជាជនទាំងអស់ធ្វើស្រែសាមគ្គី ហើយប្រជាជនអាចជ្រើសរើសក្រុមដោយខ្លួនឯងរួមទាំងគ្រួសាររបស់ ជូ។ នៅក្នុងឆ្នាំ១៩៧៣ ជូ បានរៀបការជាមួយកូនក្រមុំក្នុងភូមិម្នាក់ដែលមានឈ្មោះថា នួន សុផល ។ ពិធីរៀបការដែលប្រព្រឹត្តទៅនៅផ្ទះខាងស្រី គឺមានរយៈពេលមួយព្រឹក ហើយដំណើរការនៃកម្មវិធី គឺសុទ្ធតែមានប្រធានភូមិចូលរួម។ ជូ និងកូនក្រមុំ គឺតម្រូវឲ្យឡើងប្តេជ្ញាចិត្តក្នុងការចូលរួមកសាងបដិវត្តន៍។ ចាប់ពីឆ្នាំ១៩៧៣ ប្រជាជននៅក្នុងភូមិព្រៃក្រាំង បានចាប់ផ្តើមស្លៀកសម្លៀកបំពាក់ខ្មៅ ហើយស្រីៗតម្រូវឲ្យកាត់សក់ខ្លី។ ពិធីរៀបការរបស់ ជូ ក៏ស្លៀកតែសម្លៀកបំពាក់ខ្មៅដូចគ្នាដែរ។ ចាប់តាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៨ ជូ ត្រូវអង្គការប្រើឲ្យអារឈើ (ធ្វើរោងបាយ តុ កៅអី ជង្រុកស្រូវ និងគ្រឿងផ្សេងៗសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ) ប្រមូលដីលេខ១តាមផ្ទះយកទៅដាក់ក្នុង ឡ និងជីកសន្តូរនៅព្រៃគួច។ នៅថ្ងៃទី៣០ ខែ១២ ឆ្នាំ១៩៧៨ ប្រធានសហករណ៍ ឈ្មោះ ក្រូច សាភឿន បានប្រាប់ឲ្យប្រជាជនទាំងអស់រួមទាំងគ្រួសារ ជូ ជម្លៀសខ្លួនចេញពីភូមិ។ នៅថ្ងៃទី៤ ខែមករា ឆ្នាំ១៩៧៩ គ្រួសាររបស់ ជូ ត្រូវកងទ័ពវៀតណាមប្រាប់ឲ្យត្រឡប់មកកាន់ផ្ទះសម្បែងវិញ បន្ទាប់ពីបានធ្វើដំណើរទៅជិតដល់ស្រុកពាមជរ។ នៅខែ២ ឆ្នាំ១៩៧៩ ជូ ត្រូវបានចាត់តាំងឲ្យធ្វើជាអនុប្រធានភូមិព្រៃក្រាំង ទទួលបន្ទុកសេដ្ឋកិច្ច។ នៅខែកក្កដា ឆ្នាំ១៩៧៩ ជូ បានសម្រេចចិត្តចូលធ្វើជាគ្រូបង្រៀន ដែលមានការកិច្ចបង្រៀនចាស់ៗក្នុងភូមិឲ្យចេះអាន និងសរសេរខ្លះៗ។ ចាប់ពីឆ្នាំ១៩៩០មក ជូ ត្រូវបានតែងតាំងឲ្យធ្វើជានាយកសាលាបឋមសិក្សា បេងបុរី។ នៅឆ្នាំ២០០៦ ជូ បានចូលនិវត្តន៍ ហើយសព្វថ្ងៃគាត់ប្រកបរបរកសិកម្មបន្តិចបន្តួចនៅជុំវិញផ្ទះ។

## ភោគ តាំង

ភោគ តាំង អាយុ៨២ឆ្នាំ រស់នៅភូមិពញាកើត ឃុំជាងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ភោគ តាំង មានវ័យចំណាស់ណាស់ទៅហើយនាពេលបច្ចុប្បន្ននេះ។ គាត់រៀបការជាមួយប្រពន្ធទីពីររបស់គាត់ឈ្មោះ ប៉ែនរី នៅក្នុងឆ្នាំ១៩៧៦ ហើយបច្ចុប្បន្នរស់នៅក្នុងភូមិពញាកើត ឃុំជាងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ចំណែកប្រពន្ធទី១របស់គាត់បានស្លាប់ក្នុងឆ្នាំ១៩៧២ ដោយសារជំងឺ។ កូនៗភាគច្រើនរបស់គាត់ គឺជាកងទ័ពបម្រើការនៅក្នុងស្រុកអន្លង់វែងខេត្តឧត្តរមានជ័យ នៅខេត្តប៉ៃលិន និងស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។ តាំង គឺជាអតីតកម្មាភិបាលខ្មែរក្រហមមានមុខងារជាគណៈឃុំ គណៈសហករណ៍ និងកម្មាភិបាលថ្នាក់ស្រុកកំពង់ត្របែក។ ក្រោយខែមករា ឆ្នាំ១៩៧៩ តាំង មិនបានរត់គេចចេញពីស្រុកកំណើតឡើយ ទោះបីជាគាត់ត្រូវបានស្នើឲ្យសារភាពពីកិច្ចការដែលគាត់បានធ្វើក្នុងពេលដែលគាត់ជាកម្មាភិបាលខ្មែរក្រហម នៅចំពោះមុខប្រជាជនជាច្រើននាក់នៅក្នុងឃុំជាងដែក ភ្លាមៗក្រោយពេលរំដោះក៏ដោយ។ តាំង គឺជាមនុស្សម្នាក់ដែលមានការចងចាំល្អ។ គាត់បានរៀបរាប់ប្រាប់យើងយ៉ាងលម្អិតពីព្រឹត្តិការណ៍ដែលបានកើតឡើង និងបទពិសោធន៍



ភោគ តាំង អាយុ៨២ឆ្នាំ រស់នៅភូមិពញាកើត ឃុំជាងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ភោគ តាំង កំពុងផ្តល់បទសម្ភាសន៍ដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា។
(ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

របស់គាត់ក្នុងពេលអតីតកាល។ ក្នុងជំនួបជិតពីរម៉ោងជាមួយបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា តាំង បានបង្ហាញឲ្យឃើញពី ភាពរួសរាយរាក់ទាក់ ទឹកមុខញញឹមញញែម និងមិនលាក់លៀមពីអ្វី ដែលគាត់បានជួបប្រទះក្នុងជីវិតរបស់គាត់។ ខាងក្រោមនេះ ជាសម្តីរៀបរាប់សង្ខេបពីបទពិសោធន៍ជីវិតរបស់ ភោគ តាំង៖

ខ្ញុំកើតនៅឆ្នាំ១៩៤០ នៅភូមិពញាកើត ឃុំដាងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ នៅពេលដែលខ្ញុំមានអាយុ៧ឆ្នាំ ខ្ញុំបានចូលរៀនជាមួយព្រះសង្ឃនៅវត្តពញាកើត។ លុះដល់ខ្ញុំមានអាយុ១៥ឆ្នាំ ខ្ញុំបានបួសជាសង្ឃនៅវត្តនេះដដែល តាមសំណើរសុំរបស់យាយខ្ញុំឈ្មោះ ហៀក។ ខ្ញុំបួសបានរយៈពេល៤ឆ្នាំប៉ុណ្ណោះ ក៏សម្រេចចិត្តសឹកយកប្រពន្ធ។ ខ្ញុំរៀបការនៅឆ្នាំ១៩៥៩ ជាមួយប្រពន្ធរបស់ខ្ញុំឈ្មោះ ព្រំ សុគន្ធ។ តាំងពីរៀបការរួច ខ្ញុំធ្វើការងារ ធ្វើស្រែចម្ការផង និងប្រកបរបររកស៊ីនៅឆ្ងាយៗពីផ្ទះសម្បែងផង។ ប្រហែលកន្លះខែក្រោយថ្ងៃ១៨ មីនា ១៩៧០ ដែលជាថ្ងៃរដ្ឋប្រហារទម្លាក់សម្តេចឪ ខ្ញុំបានចូលរួមក្នុងចលនាបដិវត្តន៍តាមរយៈការអំពាវនាវរបស់សម្តេចឪឲ្យចូលព្រៃម៉ាគី។ ខ្ញុំចូលបដិវត្តន៍តាមរយៈឈ្មោះ ទោង គឺជាមេស្រុកកំពង់ត្របែក និងឈ្មោះ ភ័ណ្ឌ គឺជាបងថ្លៃរបស់ខ្ញុំ ដើម្បីចូលរួមរំដោះប្រទេសជាតិ និងដើម្បីយាងសម្តេចឪមកកាន់មាតុប្រទេសវិញ។ ប្រុសៗដែលមានអាយុស្រករខ្ញុំនិងរស់នៅក្នុងភូមិខ្ញុំទាំងអស់ បាននាំគ្នាចូលបម្រើបដិវត្តន៍ ហើយយើងត្រូវបានបញ្ជូនឲ្យទៅហាត់រៀនក្បួនយុទ្ធសាស្ត្រនៅក្នុងព្រៃស្ថិតនៅខាងត្បូងវត្តបេង។ ខ្ញុំខំប្រឹងរហ័សមកលេងផ្ទះ ដើម្បីមកយកស្បៀងអាហារទៅទុកហូបនៅអំឡុងពេលហាត់រៀន។

នៅឆ្នាំ១៩៧២ ប្រពន្ធរបស់ខ្ញុំបានស្លាប់ដោយសារទាស់ ក្នុងពេលដែលខ្ញុំកំពុងហ្វឹកហាត់នៅក្នុងព្រៃ។ ពួកយើងមានកូន៥នាក់។ ខ្ញុំត្រូវមើលកូនផង និងបម្រើជាតិផង។ នៅឆ្នាំ១៩៧៣ ខ្ញុំនិងអ្នកឯទៀតត្រូវបានបញ្ជូនទៅកាន់ទីតាំងសមរភូមិជាច្រើនកន្លែងនៅក្នុងស្រុកកំពង់ត្របែក ដើម្បីត្រៀមជាជំនួយដល់សមរភូមិមុខដែលកំពុងប្រយុទ្ធជាមួយសត្រូវ។ នៅក្នុងសមរភូមិភូមិក្រូច ខ្ញុំឃើញមានយន្តហោះមួយគ្រឿងជារបស់កងកម្លាំងធីវគីបានធ្លាក់ ហើយខ្ញុំបានទៅមើលកន្លែងយន្តហោះធ្លាក់នេះ។ ខ្ញុំឃើញមានសាកសពអ្នកបើកយន្តហោះម្នាក់ស្លាប់នៅទីនោះ។

នៅឆ្នាំ១៩៧៤ ខ្ញុំត្រូវបានចាត់តាំងឲ្យទៅបម្រើការនៅក្នុងអង្គភាពសេដ្ឋកិច្ចស្រុកកំពង់ត្របែក ប្រចាំការនៅប្រកសេដ្ឋកិច្ចពាមមន្ទារ (ខាងលិចវត្តក្របាប់)។ នៅទីនោះ ខ្ញុំបានប្រមូលលុយពន្ធជាច្រើនពីការរកស៊ីចេញចូលពីវៀតណាមមកកម្ពុជា។ លុយដែលខ្ញុំប្រមូលបាន គឺយកទៅប្រគល់ឲ្យអង្គភាពទាំងអស់។

ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំត្រូវបានផ្លាស់ប្តូរភារកិច្ចមកបម្រើការជាអ្នកបើកអង្ករឲ្យអង្គភាពយោធា ក្នុងអង្គភាពសេដ្ឋកិច្ចដដែល។ ដ័យសារិនអនុគណៈស្រុកកំពង់ត្របែក គឺជាអ្នកគ្រប់គ្រងលើអង្គភាពសេដ្ឋកិច្ចស្រុក។ ពីរបីខែក្រោយមក ខ្ញុំត្រូវបានចាន់ឡឿន និងសួម វីរៈ ចាត់តាំងឲ្យទៅធ្វើជាប្រធានសហករណ៍ភូមិស្គារ ឃុំគោខ្ចក ស្រុកកំពង់ត្របែក និងបានឲ្យខ្ញុំធ្វើប្រវត្តិរូបដោយដាក់ឈ្មោះគាត់ គឺ ចាន់ឡឿន ជាអ្នកណែនាំ។ ក្នុងតួនាទីជាប្រធានសហករណ៍ ខ្ញុំត្រូវបានហៅឲ្យចូលរួមរៀនសូត្រវគ្គនយោបាយរយៈពេល១ខែ ដែលមានសមមិត្ត ទីវ អុល និង ហ៊ូ នឹម គឺជាគ្រូបង្រៀន។ ចំណែកសមមិត្ត ឈូក ប្រធានតំបន់២៤ គឺជាអ្នកថ្លែងការណ៍បើក និងបិទកម្មវិធីរៀនសូត្រ។

នៅខែកញ្ញា ឆ្នាំ១៩៧៥ សមមិត្ត ជ័យ សារិន បានស្នើខ្ញុំឲ្យទៅធ្វើការនៅក្នុងមន្ទីរសេចក្តីស្រុកកំពង់ត្របែកវិញ បន្ទាប់ពីមានការស្រាវជ្រាវតាមរកចាប់ខ្លួនកម្មាភិបាលក្បត់មួយចំនួននៅស្រុកកំពង់ត្របែក។ ខ្ញុំភ័យខ្លាំងណាស់ ព្រោះខ្លាចក្រែងជាប់ខ្សែរយៈក្បត់ជាមួយ ចាន់ ឡឿន។ ចាន់ ឡឿន ត្រូវបានចាប់ខ្លួននៅមុនពេលដែលខ្ញុំត្រូវកោះហៅឲ្យផ្លាស់ប្តូរការកិច្ច។ ក្រៅពី ចាន់ ឡឿន មានកម្មាភិបាលធំៗ មួយចំនួនទៀតក៏ត្រូវបានចាប់ខ្លួនដែរ ដូចជា សាវ៉ាន់ ប្រធានយោធាស្រុកកំពង់ត្របែក, កែវ នី សមាជិកស្រុក, អុល អាត សមាជិកសមាគមយុវជនស្រុកទទួលបន្ទុកកងចល័ត និង អ៊ី ខ្វាក់ភ្នែកម្ខាង គឺជាសមាជិកសមាគមយុវជនស្រុកទទួលបន្ទុកយោសនាការ។

ពេលខ្ញុំមកដល់មន្ទីរស្រុកកំពង់ត្របែក សមមិត្ត ជ័យ សារិន បានឲ្យខ្ញុំកែប្រវត្តិរូបរបស់ខ្ញុំ ដោយឲ្យប្តូរឈ្មោះអ្នកណែនាំពីឈ្មោះ ចាន់ ឡឿន មកឈ្មោះ ជ័យ សារិន វិញ។ នៅឆ្នាំ១៩៧៦ ជ័យ សារិន បានចាត់តាំងខ្ញុំឲ្យមកធ្វើជាគណៈឃុំព្រៃពោន។ នៅទីនោះ កែវ លុន ជាអនុគណៈឃុំព្រៃពោន មានការថ្នាំងថ្នាក់ជាមួយខ្ញុំ ព្រោះគាត់មិនបានធ្វើជាគណៈឃុំ។ ក្រោមការដឹកនាំក្នុងឃុំ ប្រជាជនច្រើនណាស់បានចូលចិត្តខ្ញុំ ព្រោះខ្ញុំមិនបានធ្វើឲ្យពួកគាត់ថ្នាំងថ្នាក់ឡើយ។ ខ្ញុំដឹកនាំការងារនៅឃុំព្រៃពោនរហូតដល់ចុងឆ្នាំ១៩៧៨។

នៅឆ្នាំ១៩៧៨ វគ្គរៀនសូត្រនយោបាយមួយត្រូវបានបង្កើតឡើង ហើយគណៈឃុំនិងកម្មាភិបាលជាច្រើននាក់មកពីឃុំទាំងអស់ក្នុងតំបន់២៤ ត្រូវកោះហៅឲ្យចូលរួមប្រជុំក្នុងរយៈពេលជាងមួយខែ ដើម្បីពិនិត្យ តាមដានសកម្មភាពការងាររបស់គណៈឃុំ និងចម្រាញ់សមាសភាពក្បត់បដិវត្តន៍ ដែលចេញពីឃុំនីមួយៗ។ គណៈអធិបតីនៅក្នុងវគ្គរៀនសូត្រនេះគឺ ចាន់ អនុប្រធានភូមិភាគបូព៌ា ហើយ ជ័យ និង សម្រេច គឺជាអ្នកសម្របសម្រួលនៅក្នុងវគ្គ។ ក្នុងពេលរៀនសូត្រ ជ័យ បានខ្សឹបប្រាប់ខ្ញុំថា សមាសភាពមួយចំនួនដែលបានចូលរួមក្នុងវគ្គរៀនសូត្រនេះ ត្រូវបានចាប់ខ្លួនជាបណ្តើរៗអស់ជាង២០នាក់ហើយ។ ខ្ញុំចាប់ផ្តើមភ័យខ្លួនម្តងទៀត ហើយខ្ញុំក៏មានការប្រុងប្រយ័ត្នខ្ពស់ដែរ។

ប្រហែលបួនប្រាំខែក្រោយមក ខ្ញុំត្រូវបានផ្លាស់ប្តូរមកស្នាក់នៅក្នុងសហករណ៍ឃុំជាំងដែក ដោយមូលហេតុខ្ញុំបានផ្តល់ឱកាសឲ្យប្រជាជនដែលមានឈ្មោះត្រូវជម្លៀសទៅកាន់ខេត្តពោធិ៍សាត់ ក្នុងការសម្រេចចិត្តដោយខ្លួនឯងក្នុងការចាកចេញទៅ។ ខ្ញុំបានធ្លាក់ខ្លួនឈឺ ហើយគាប់ជួនពេលនោះ កងទ័ពវៀតណាមបានវាយចូលមកដល់ទឹកដីឃុំជាំងដែក។

នៅខែមករា ឆ្នាំ១៩៧៩ ខ្ញុំត្រូវកងទ័ពវៀតណាមចាប់ខ្លួនពីផ្ទះរបស់ខ្ញុំនៅភូមិរោង យកទៅសួរចម្លើយពីការងារដែលខ្ញុំបានធ្វើក្នុងរបបខ្មែរក្រហម។ នៅមុខកងទ័ពវៀតណាម និងប្រជាជនជាច្រើន ខ្ញុំបានឆ្លើយសារភាពតាមការពិតជាក់ស្តែងដែលខ្ញុំបានធ្វើ។ បន្ទាប់មក កងទ័ពវៀតណាមបានប្រគល់ខ្ញុំទៅឲ្យសមមិត្ត ញ៉ែម គឺជាគណៈស្រុកកំពង់ត្របែកដែលឡើងតំណែងក្រោយ គឺជាអ្នកចាត់ចែង ហើយសមមិត្ត ញ៉ែម បានអនុញ្ញាតនិងផ្តល់ឱកាសឲ្យខ្ញុំបានធ្វើការងារបន្តទៀត។ ប៉ុន្តែខ្ញុំបានប្រកែកមិនព្រមធ្វើ។ ចាប់តាំងពីឆ្នាំ១៩៨២ រហូតមកដល់បច្ចុប្បន្ន ខ្ញុំបានស្ម័គ្រចិត្តធ្វើជាអាចារ្យវត្តពញាកើតដើម្បីពង្រឹងវិស័យសាសនាក្នុងភូមិឃុំរបស់ខ្ញុំ។

## ធន់ ភ្លាក

ធន់ ភ្លាក ភេទប្រុស អាយុ៧០ឆ្នាំ កើតនៅភូមិព្រៃសំរោង ឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ បច្ចុប្បន្ន ធន់ ភ្លាក រស់នៅភូមិក្រូច ឃុំជាំងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ កាលពីក្មេង ភ្លាក បានចូលរៀននៅសាលាបឋមសិក្សាបេងបុរីស្ថិតនៅក្នុងឃុំព្រៃពោន និងធ្លាប់បានបួសជាសង្ឃនៅវត្តអាគ្រាជ។ ភ្លាក លាចាកសិក្ខាបទ និងត្រឡប់មកកាន់ភូមិកំណើតវិញនៅក្រោយរដ្ឋប្រហារទម្លាក់សម្តេច ព្រះនរោត្តម សីហនុ។

នៅឆ្នាំ១៩៧៣ ភ្លាក បានរៀបការជាមួយនារី



ធន់ ភ្លាក អាយុ៧០ឆ្នាំ រស់នៅភូមិក្រូច ឃុំជាងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ម្នាក់ឈ្មោះ អ៊ុង អួន។ បន្ទាប់ពីរៀបការរួច ប្រធានកងឈ្លបឈ្មោះ កាន់បានមកចាប់ ភ្លាក យកទៅដាក់ឃុំឃាំងនៅវត្តបេង ក្រោមការចោទប្រកាន់ថា បានប្រព្រឹត្តបទល្មើសចោរកម្ម និងសន្តិសម្ព័ន្ធ។ ភ្លាក ត្រូវបានកាត់ទោសសម្លាប់ ប៉ុន្តែគាត់ត្រូវបានសង្គ្រោះដោយឈ្មោះ វៀ លាង គឺជាប្រធានកងនារី។ លាង បានប្រាប់ទៅកងសន្តិសុខថា គាត់ធ្វើការអប់រំកែប្រែ ភ្លាក ឲ្យបានល្អទៅថ្ងៃក្រោយ។

ចាប់តាំងពីខ្មែរក្រហម ទទួលបានជ័យជម្នះទាំងស្រុងនៅឆ្នាំ១៩៧៥មក ភ្លាក ត្រូវអង្គការប្រើឲ្យធ្វើការជាច្រើន ដូចជា លើកថ្នល់នៅផ្លូវជាតិលេខ១១ ដាំបន្លែ ភ្ជួររាស់ ដាំដំឡូង ជីកសន្ទូរទឹក និងសែងទាហានរបួស និងស្លាប់ក្នុងសមរភូមិ។ ភ្លាក បានបន្ថែមថា ក្រុមរបស់គាត់សែងអ្នករបួសពីឃុំក្រាំងលាវ យកទៅព្យាបាលនៅក្នុងវត្តប្រាសាទ និងសែងអ្នកស្លាប់យកទៅកប់នៅព្រៃស្នា វត្តថ្នាខាន់ ភូមិក្រូច និងកអណ្តើក ដែលជាវិទ្យាល័យកំពង់ត្របែកសព្វថ្ងៃ។ ក្រោយមកនៅឆ្នាំ១៩៧៨ ភ្លាក រួមជាមួយអ្នកភូមិផ្សេងទៀតត្រូវបានបង្ខំឲ្យជម្លៀសចេញទៅកាន់ភាគខាងលិចប្រទេសកម្ពុជា។ នៅពេលធ្វើដំណើរដល់អ្នកលឿង ភ្លាក និងអ្នកឯទៀត ត្រូវបានប្រាប់ឲ្យវិលត្រឡប់មកកាន់ស្រុកកំណើតវិញ។

សព្វថ្ងៃ ភ្លាក រស់នៅជាមួយកូនម្នាក់ ក្នុងចំណោមកូន១២នាក់ (ស្លាប់១នាក់) នៅក្នុងភូមិក្រូច ឃុំជាងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។

## ប៉ែន សាខុម

ប៉ែន សាខុម អាយុ៧២ឆ្នាំ រស់នៅភូមិក្រូច ឃុំជាងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ប៉ែន សាខុម បានចូលរៀននៅសាលាបឋមសិក្សាព្រៃដង្ក៉ូ នៅអាយុ៧ឆ្នាំ។ គ្រូបង្រៀនរបស់ សាខុម គឺ មាស យឹម, ភា, ស៊ឹម, យ៉ាវ និងគ្រូដទៃទៀតដែលគាត់មិនបានចាំឈ្មោះអស់។

ក្រោយថ្ងៃទី១៨ មីនា ឆ្នាំ១៩៧០ ភូមិកំណើតរបស់ សាខុម ទទួលរងនូវការទម្លាក់គ្រាប់បែកស្ទើររាល់ថ្ងៃ។ នៅឆ្នាំ១៩៧១ និង១៩៧៣ សាខុម តែងរត់ចូលពួនសំងំនៅក្នុងលេណដ្ឋានក្បែរផ្ទះ ដើម្បីគេចចេញពីគ្រាប់បែក។ នៅចុងឆ្នាំ១៩៧៤ ការទម្លាក់គ្រាប់បែកលែងមានតទៅទៀតហើយនៅក្នុងភូមិកំណើតរបស់ សាខុម។ ព្រឹត្តិការណ៍បង្កើតសហករណ៍ និងរោងបាយ បានចាប់ផ្តើមជាបណ្តើរៗ។ ក្រោយថ្ងៃ១៧ មេសា ១៩៧៥ ប្រជាជនថ្មីចំនួន១២គ្រួសារ បានមករស់នៅក្នុងភូមិក្រូច។



ប៉ែន សាខុម អាយុ៧២ឆ្នាំ រស់នៅភូមិក្រូច ឃុំជាងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅចុងឆ្នាំ១៩៧៦ សា ខុម ត្រូវអង្គការស្នើឲ្យរៀបការ។ ក្រោយរៀបការរួច សា ខុម មិនបានរស់នៅជាមួយប្រពន្ធឡើយ។ គាត់ត្រូវអង្គការចាត់តាំងឲ្យទៅធ្វើសន្ទូរនៅព្រៃក្តួច, ទៅធ្វើចម្ការនៅឃុំពាមមន្ទារ និងទៅលើកទំនប់រាំងកូនសត្វ។ សា ខុម បានលើកឡើងថា ការរស់នៅរបស់ប្រជាជនត្រូវស្ថិតក្រោមការតាមដានរបស់អង្គការគ្រប់ពេលវេលា។ សា ខុម បានឃើញកងឈ្លបបណ្តើរអ្នកទោសកាត់តាមមុខផ្ទះគាត់នៅឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ និងមានអ្នកទោសជាច្រើននាក់ត្រូវកម្មាភិបាលចង។ នៅឆ្នាំ១៩៧៨ សា ខុម ត្រូវបានជម្លៀសចេញពីភូមិកំណើតឆ្ពោះទៅកាន់អូរប្របួស ស្រុកព្រះស្តេច ខេត្តព្រៃវែង។

ក្រោយឆ្នាំ១៩៧៩ ការរស់នៅរបស់ សា ខុម មានការលំបាកព្រោះមិនមានរបស់របរប្រើប្រាស់ និងស្រូវអង្ករហូប។ ដូចនេះ សា ខុម និងប្រជាជនដទៃទៀត នាំគ្នាដើរទៅរកប្រូតស្រូវដែលនៅសេសសល់ខ្លះៗនៅតាមស្រែដើម្បីយកមកទុកធ្វើពូជ។ ចាប់តាំងពីឆ្នាំ១៩៨២មក ជីវភាពរស់នៅរបស់ សា ខុម បានប្រសើរឡើងបន្តិចៗ។ សា ខុម នៅតែចងចាំជានិច្ចនូវព្រឹត្តិការណ៍ពីរគឺៈ ១) ការរត់គេចខ្លួនពីការតាមចាប់របស់ខ្មែរក្រហម និង ២) ការសម្លាប់របស់ខ្មែរក្រហមមកលើប្អូនរបស់គាត់។ សា ខុម មិនចង់ឲ្យរបបខ្មែរក្រហមកើតឡើងជាលើកទី២ទៀតឡើយ។



ធន់ ភ្លាក អាយុ៧០ឆ្នាំ រស់នៅភូមិក្រូច ឃុំជាងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

## ហ៊ិន សាផាត

ហ៊ិន សាផាត រស់នៅភូមិក្រូច ឃុំជាងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ១៩៥២ គឺជាថ្ងៃដែល សាផាត ចាប់កំណើតនៅក្នុងគ្រួសារដែលមានជីវភាពធូរធាមួយក្នុងសម័យសង្គមរាស្ត្រនិយម។ នៅឆ្នាំ១៩៥៧ សាផាត បានចូលរៀននៅសាលាបឋមសិក្សា បេងបុរី រហូតដល់ចប់ថ្នាក់ទី៩ និងបានបន្តការសិក្សានៅសាលាបឋមសិក្សាព្រៃសង្គម ដែលស្ថិតនៅក្នុងឃុំជាងដែក រហូតដល់ចប់ថ្នាក់ទី៧។

ក្រោយមកទៀត ព្រឹត្តិការណ៍ទម្លាក់គ្រាប់បែកបានចាប់ផ្តើមកើតមាននៅក្នុងភូមិកំណើតរបស់ សាផាត ជាច្រើនលើកច្រើនសារ។ ដោយមូលហេតុនេះហើយ ទើប សាផាត សម្រេចចិត្តទៅរស់នៅជាមួយបងប្រុស ឈ្មោះ ហ៊ិន ថៅ គឺជាគ្រូបង្រៀននៅសាលាបឋមសិក្សាក្រុង ឯក្រុងព្រៃវែង និងបានចូលរៀននៅវិទ្យាល័យព្រះអង្គឌួងបន្តទៀត។ សាផាត បានប្រឡងជាប់ថ្នាក់ទី៣ និងបានបន្តរៀនរហូតដល់ថ្នាក់ទី១ ប៉ុន្តែដោយសារតែខ្មែរក្រហមយកឈ្នះ លន់ នល់ នៅអ្នកលឿង ទើប សាផាត ត្រឡប់មកស្រុកកំពង់ត្របែកវិញ និងបានមកស្នាក់នៅក្នុងភូមិពញាកើត។ សាផាត មិនបានត្រឡប់ទៅរស់នៅក្នុងភូមិព្រៃក្រាំងវិញទេ ព្រោះនៅមានការទម្លាក់គ្រាប់បែកនៅឡើយ។ ក្នុងភូមិពញាកើត សាផាត បានចូលរួមធ្វើស្រែសាមគ្គីជាមួយអ្នកភូមិឯទៀត។

រហូតដល់ចុងឆ្នាំ១៩៧៤ សាផាត ត្រូវកងកម្លាំងខ្មែររំដោះចាប់យកទៅដាក់ឃុំឃាំងនៅទួលម្រេញ ក្រោមការចោទប្រកាន់ថា ជាទាហានពាក់ស័ក្តិ៥ក្នុងពេលដែលគាត់មកស្នាក់នៅក្នុងក្រុងព្រៃវែង។ នៅក្នុងមន្ទីរសន្តិសុខទួលម្រេញ កោ ស៊ុម និង ម៉ែន ពុត បានសួរចម្លើយគាត់អំពីសកម្មភាពក្បត់បដិវត្តន៍។ សាផាត មិនបានឆ្លើយសារភាពតាមការចង់បានរបស់



ហ៊ិន សាផាត រស់នៅភូមិក្រូច ឃុំដាំងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

កងកម្លាំងឡើយ ប៉ុន្តែគាត់នៅតែអះអាងថា គាត់គ្រាន់តែជាសិស្សសិក្សានៅក្នុងវិទ្យាល័យប៉ុណ្ណោះ។ សាផាត ត្រូវកងសន្តិសុខទាំងពីរនាក់ធ្វើទារុណកម្មវាយនឹងក្តួរត្នោតក្រាម (ផ្កាត្នោតឈ្មោល)។ ក្រៅពីសួរចម្លើយ សាផាត ត្រូវបានប្រើឲ្យធ្វើការងារជាច្រើន ដូចជាធ្វើស្រែ គាស់គល់ឈើ និងស្ទូចាន។

នៅឆ្នាំ១៩៧៥ បន្ទាប់ពីថ្ងៃជ័យជម្នះរបស់ខ្មែរក្រហម សាផាត ត្រូវបានដោះលែងឲ្យត្រឡប់មកភូមិពញាកើតវិញ។ ប្រធានសហករណ៍ ឈ្មោះ ឈុំ បានប្រើ សាផាតឲ្យលើកភ្លឺស្រែ។ នៅឆ្នាំ១៩៧៦ សាផាត ត្រូវបានបញ្ជូនឲ្យទៅដាំដំណាំនៅ ខាងទួលកៅទៃ ស្រុកពាមជរ ខេត្តព្រៃវែង ចំនួន៣ខែ។ ក្នុងពេលបំពេញការងារនៅទួលកៅទៃ សាផាត ខំស្វាហ៍ត្រឡប់មកភូមិកំណើតដើម្បីមកយកស្បៀងអាហារ។ នៅឆ្នាំ១៩៧៧ សាផាតបានផ្លាស់ប្តូរការងារមកធ្វើការនៅក្នុងកងភ្ជួរ ដែលមានសមាជិកក្នុងក្រុម៤នាក់។

នៅឆ្នាំ១៩៧៨ សាកសពមនុស្សជាច្រើននាក់បានអណ្តែតលើផ្ទះបន្ទាប់ពីមានទឹកជំនន់ឡើងលិចវាលស្រែ និងទីទួលក្នុងភូមិរបស់ សាផាត។ គាត់បានប្រាប់ថា គាត់បានរុញសាកសពទាំងនោះឲ្យចេញពីរបងផ្ទះគាត់។ នៅឆ្នាំដដែល សាផាត និងក្រុមគ្រួសារត្រូវបានបង្ខំឲ្យជម្លៀសទៅខេត្តភាគខាងលិចប្រទេសកម្ពុជា។ គាត់បានធ្វើដំណើរទៅដល់អ្នកលឿង ក៏សម្រេចចិត្តវិលត្រឡប់មកវិញ ដោយមូលហេតុកងទ័ពវៀតណាមបានចូលមកជួយ និងប្រាប់ឲ្យវិលត្រឡប់មកកាន់ផ្ទះសម្បែងវិញ។

នៅក្នុងខែកក្កដា ឆ្នាំ១៩៧៩ សាផាតបានចូលបម្រើការជាគ្រូបង្រៀននៅក្នុងភូមិ និងនៅក្នុងសាលាបឋមសិក្សាព្រៃសន្តម។ នៅឆ្នាំ១៩៩៣ សាផាតបានក្លាយជានាយកនៅសាលាបឋមសិក្សាពញាកើតរហូតដល់ពេលចូលនិវត្តន៍នៅ អាយុ៦០ឆ្នាំ។ សព្វថ្ងៃ សាផាត រស់នៅជាមួយប្រពន្ធទី២របស់គាត់ ដែលបានរៀបការនៅឆ្នាំ២០០២ ហើយប្រពន្ធទី១របស់គាត់ដែលបានរៀបការក្នុងសម័យខ្មែរក្រហមឆ្នាំ១៩៧៥ បានស្លាប់ដោយសារជំងឺ បន្ទាប់ពីបែកបានប្រមាណ២ឆ្នាំ។ សាផាតមានកូនទាំងអស់៨នាក់ ស្រី៤នាក់ជាមួយប្រពន្ធទី១។ ជាចុងក្រោយ សាផាតបានសំណូមពរមកមជ្ឈមណ្ឌលឯកសារកម្ពុជាឲ្យបោះពុម្ពសៀវភៅគោល ដែលនិយាយអំពីប្រវត្តិសាស្ត្រខ្មែរក្រហមយកទៅបង្រៀនកូនក្មេងជំនាន់ក្រោយចាប់ពីថ្នាក់បឋមរហូតដល់វិទ្យាល័យ។

## ពុធ សារ៉ាន

ពុធ សារ៉ាន អាយុ៦២ឆ្នាំ រស់នៅភូមិពញាកើត ឃុំដាំងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ សារ៉ានបានរៀបរាប់ថា កាលពីកុមារភាពគាត់បានចូលរៀននៅឆ្នាំ១៩៧០ក្នុងសាលាបឋមសិក្សាថ្នាក់ទី១ បន្ទាប់ពីថ្ងៃធ្វើរដ្ឋប្រហារទម្លាក់សម្តេច នរោត្តម សីហនុ ដោយសេនាប្រមុខ លន់ នល់ មក សារ៉ានបានផ្អាកការសិក្សា ដោយសារតែសង្គ្រាមកើតមានជាហូរហែនៅក្នុងស្រុកកំណើតរបស់គាត់។ អ្នកភូមិម្នាក់ៗបានរត់គេចពីគ្រាប់ផ្លោង និងពុំសូវបានប្រកបរបរធ្វើស្រែ និងរកស៊ីឡើយ។

នៅឆ្នាំ១៩៧១ សារ៉ាន បានឃើញមានវត្តមានធីវគី ចូលមកក្នុងភូមិស្រុក និងបានធ្វើបាបកូនក្រមុំអ្នកស្រុក លួចយកទ្រព្យសម្បត្តិ និងចាប់សត្វពាហនៈធ្វើម្ហូបជាដើម។ នៅថ្ងៃ១៧ មេសា ១៩៧៥ សារ៉ានបានឃើញផ្ទាល់ភ្នែកនូវការរៀបចំពិធីអបអរសាទរ



ពុធ សារ៉ាន អាយុ៦៧ឆ្នាំ រស់នៅភូមិពញាកើត ឃុំជាងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ថ្ងៃជ័យជម្នះយ៉ាងគគ្រឹកគគ្រេង ហើយ សារ៉ាន ក៏ត្រូវអង្គការហៅឲ្យឡើងមានចំណាប់អារម្មណ៍ក្នុងកម្មវិធីនោះដែរ។

ចាប់តាំងថ្ងៃជ័យជម្នះមក សារ៉ាន ត្រូវបានចាត់តាំងឲ្យធ្វើគ្រូបង្រៀនក្មេងៗ និងត្រូវបានបញ្ជូនឲ្យទៅរៀនសូត្របន្ថែមពីរបៀបបង្រៀនសិស្ស នៅក្នុងវត្តបេងបូរី។ ការបង្រៀនលើកដំបូងរបស់ សារ៉ាន គឺស្ថិតនៅក្នុងឃុំព្រៃពោន ហើយបន្ទាប់មកទៀត នៅភូមិត្រពាំងក្រសាំង។ នៅឆ្នាំ១៩៧៧ សារ៉ាន ត្រូវអង្គការបង្គាប់ឲ្យរៀបការ។

សារ៉ាន បានប្រាប់ថា ពិធីរៀបការរបស់គាត់ គឺមានចាក់ភ្លេង មានខគ្សែ សនសព្ទ និងមានការចូលរួមពីឪពុកម្តាយ បងប្អូន និងអ្នកភូមិ។ ក្រោយរៀបការរួច សារ៉ាន និងប្តី មិនបានរស់នៅជុំគ្នាទេ ប្តីរបស់គាត់ត្រូវបានអង្គការឲ្យទៅធ្វើការនៅអង្គភាពដើមវិញ ហើយក្នុង១ខែ សារ៉ាន និងប្តីត្រូវបានអង្គការអនុញ្ញាតឲ្យមកជួបគ្នាម្តងដែលមានរយៈពេលយ៉ាងច្រើន២ថ្ងៃប៉ុណ្ណោះ។ សារ៉ាន បានបន្តទៀតថា ក្រៅពីការងារធ្វើជាគ្រូបង្រៀន គាត់ត្រូវបានអង្គការប្រើឲ្យធ្វើជីលេខ១ និងលើកប្រព័ន្ធភ្លឺស្រែ នៅគោកស្រុកដែរ។ សារ៉ាន បានអះអាងថា គាត់និងអ្នកឯទៀត ត្រូវអង្គការប្រើឲ្យជីករណ្តៅជាច្រើននៅក្នុងភូមិដូង នៅ ទួលតាអន និងទួលម្រេញ ដែលរណ្តៅទាំងនោះត្រូវបានជីកសម្រាប់កប់សាកសពដែលត្រូវបានសម្លាប់។ សារ៉ាន ត្រូវបានជម្លៀសទៅដល់ទន្លេតូច ក៏ត្រូវវិលត្រឡប់មកកាន់ភូមិកំណើតវិញ ដោយសារតែប្រទេសទាំងមូលត្រូវបានរំដោះដោយកងទ័ពស្ម័គ្រចិត្តវៀតណាម និងកងកម្លាំងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា។

## ប្រាក់ មឿន

ប្រាក់ មឿន អាយុ៦៨ឆ្នាំ រស់នៅភូមិក្រូច ឃុំជាងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ប្រាក់ មឿន បាននិយាយរៀបរាប់រឿងរ៉ាវរបស់គាត់ ប្រាប់មកកាន់ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តព្រៃវែង ដើម្បីការចងចាំ។ នៅឆ្នាំ២០២១ នេះ មឿន មានអាយុ៦៨ឆ្នាំហើយ។ គាត់មានបងប្អូន៥នាក់ ស្លាប់អស់២នាក់ ដោយម្នាក់បានស្លាប់ដោយសារការលេងគ្រាប់ដែលយៀកកុងបានផ្លោងមក នៅឆ្នាំ១៩៧១ ហើយផ្ទុះ។ រីឯម្នាក់ទៀត ទើបតែស្លាប់នាពេលថ្មីៗនេះដោយសារជំងឺ។ កាលពីនៅអាយុ៧ឆ្នាំ មឿនបានចូលរៀននៅសាលាបឋមសិក្សាព្រៃដង្កុំ ហើយគាត់បានឈប់រៀននៅថ្នាក់ទី៧ ក្នុងឆ្នាំ១៩៧០។ មូលហេតុនៃការឈប់រៀនរបស់គាត់ គឺដោយសារតែប្រទេសជាតិបានជួបនូវភាពវឹកវរ មានសង្គ្រាមកើតឡើងបន្ទាប់ពី លន់ នល់បានធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ មក។



ប្រាក់ មឿន អាយុ៦៨ឆ្នាំ រស់នៅភូមិក្រូច ឃុំជាងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រោយពីបានដឹងថា សម្តេចបានអំពាវនាវឲ្យប្រជាពលរដ្ឋរត់ចូលព្រៃម៉ាគី ហើយប្រឆាំងនឹងរបបលន់ នល់ ដើម្បីយកអំណាចមកថ្វាយព្រះអង្គវិញ ប្រជាជនជាច្រើនបាននាំគ្នារត់ចូលព្រៃម៉ាគីដើម្បីតស៊ូ ហើយ មឿន ដែលស្ថិតនៅក្នុងវ័យជាសិស្សសាលា និងមានអាយុ១៨ឆ្នាំ ក៏ត្រូវបាននាយកសាលាព្រៃដង្កុំឈ្មោះ ស៊ុម បញ្ជូនចូលទៅក្នុងព្រៃម៉ាគីជាមួយនឹងសិស្សសាលាជាច្រើននាក់ទៀតដែរ។ នៅក្នុងព្រៃតស៊ូ មឿន បានហាត់ក្បួនយុទ្ធសាស្ត្រ ហាត់ប្រយុទ្ធកាន់ដំបង និងហាត់លូនក្រាប។ ហាត់រៀនបានកន្លះខែ គាត់ក៏បានសុំប្រធានអង្គភាពមករៀនធម៌បួសវិញ។

នៅឆ្នាំ១៩៧២ ដោយសារនៅក្នុងភូមិដែល មឿន រស់នៅមានសភាពលំបាក មានការទម្លាក់គ្រាប់បែកមានរថក្រោះ មានទាហានធីវគី ទើប មឿន ពិភាក្សាជាមួយនឹងមិត្តរបស់គាត់ពីរនាក់ទៀតឈ្មោះ ប្រាក់ សាម៉េត និង ញិន សាម៉ន ដើម្បីបន្តការសិក្សាថ្នាក់ភាសាបាលី នៅឯរាជធានីភ្នំពេញ។ មឿន បានទៅគង់នៅវត្តស្វាយពពែ ហើយទៅរៀនភាសាបាលីថ្នាក់ទី១នៅវត្តថាន់ ថ្នាក់ទី២នៅវត្តពយូវង្ស និងទី៣នៅវត្តសុវាម្រឹត។

បីឆ្នាំក្រោយមក នៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចូលមកដល់ ហើយបានប្រកាសឲ្យប្រជាជនទាំងអស់ចេញពីរាជធានីភ្នំពេញ។ មឿន បានចាកចេញជាមួយនឹងហ្វូងមនុស្សជាច្រើននាក់ទៀតដើម្បីវិលត្រឡប់មកកាន់ស្រុកកំណើតវិញ។ ហ្វូងមនុស្សជាច្រើនបានចាកចេញស្របពេលជាមួយគ្នាធ្វើឲ្យភ្នំពេញមានសភាពកកស្ទះណែនណាន់តាន់តាប់។ ក្រោយពីប្រជ្រៀតគ្នាចេញពីភ្នំពេញ នៅតាមផ្លូវមកផ្ទះ មឿន បានឃើញសាកសពទាហាន លន់ នល់ ជាច្រើននាក់ស្លាប់គរ ស្អុយនៅទន្លេអ្នកលឿង។ បន្ទាប់មកទាហានខ្មែរក្រហមបង្ខំឲ្យគាត់បន្តដំណើររហូតដល់វត្តក្របាប់ និងបន្តហួសទៅដល់វត្តពេជ្ជរតន៍ក្នុងរយៈពេល១០ថ្ងៃ ហើយស្នាក់នៅទីនោះ។ នៅវត្តពេជ្ជរតន៍ ព្រះសង្ឃដែលគង់នៅទីនោះ ឈ្មោះ ឌាច បានប្រើ មឿន និងព្រះសង្ឃជាច្រើននាក់ទៀតដែលបានជម្លៀសមកអូសរទេះដឹកថ្មទប់ស្ពាន និងធ្វើស្ពានរយៈពេល២ខែរហូតហើយរួចរាល់។

បន្ទាប់ពីធ្វើការងាររួចរាល់ មឿន ត្រូវបានបញ្ជូនទៅកាន់វត្តព្រៃម្លូង និងត្រូវបានផ្សឹកនៅទីនោះនៅខែមិថុនា ឆ្នាំ១៩៧៥។ បន្ទាប់ពីសឹករួច គាត់បានវិលត្រឡប់មកផ្ទះវិញ ហើយប្រធានភូមិឈ្មោះ វីរ បានមកសួរនាំគាត់អំពីប្រវត្តិរបស់ ដូចជា ធ្លាប់ធ្វើការងារអ្វីខ្លះ? ពាក់ស័ក្តិប៉ុន្មាន? បើពាក់ស័ក្តិ ១ ខ្មែរក្រហមឲ្យឡើងស័ក្តិ១វិញ បើពាក់ផ្កាយ៥ ខ្មែរក្រហមឲ្យពាក់ផ្កាយ៥វិញ។ ប៉ុន្តែមិនមែនជាការពិតឡើយ គោលបំណងខ្មែរក្រហម អ្នកដែលធ្វើការងារនៅក្នុងរបបសាធារណ-រដ្ឋខ្មែរនឹងត្រូវយកទៅសម្លាប់ចោលទាំងអស់ ដូចជាគ្រូរបស់ មឿន ឈ្មោះ ស៊ុម, សោម សុវត្ថិ, និងគ្រូ៤ទៅ៥អង្គទៀត ត្រូវបានយកទៅទួលម្រេញ ទួលតាអន និងទួលជ័យ ដែលមានកម្មាភិបាលខ្មែរក្រហមឈ្មោះ និន និង ពុត គឺជាអ្នកវាយសម្លាប់ និងធ្វើទារុណកម្ម។ ប៉ុន្តែសំណាងល្អ មឿន បាននិយាយប្រាប់ប្រធានភូមិថាគាត់មិនបានធ្វើការងារអ្វីទាំងអស់។

នៅខែមករា ឆ្នាំ១៩៧៦ មឿន ត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅក្នុងក្រុមគ៣ ដែលមានប្រធានឈ្មោះ លន។ មឿន មានភារកិច្ចលើកប្រព័ន្ធភ្លឺស្រែ និងជីកប្រឡាយទឹកពីត្របែកទៅក្បាលថ្នល់ជម្រៅ២ម៉ែត្រ។ នៅរដូវវស្សា មឿន ត្រូវបានចាត់តាំងឲ្យទៅភ្ជួរស្រែ ហើយដល់ខែប្រមូលផលស្រូវ គាត់ត្រូវបានបញ្ជូនឲ្យទៅដឹកកណ្តាប់ស្រូវពីស្រែយកទៅទីលានស្រូវដើម្បីឲ្យអ្នកនៅទីនោះបោកបែន។ មឿន បានធ្វើការបែបនេះរហូតដល់ថ្ងៃរំដោះឆ្នាំ១៩៧៩។ រីឯអាហារហូបចុកវិញ គឺគាត់ហូបតែបបរតាំងពីឆ្នាំ១៩៧៦ មក។

នៅខែមីនា ឆ្នាំ១៩៧៨ មឿន បានរៀបការជាមួយនឹងភរិយារបស់គាត់ឈ្មោះ កែវ សយ។ ក្នុងពេលរៀបការ ខ្មែរក្រហមបានរៀបចំធ្វើពិធីរៀបការឲ្យអ្នកផ្សេងៗទៀតសរុបទាំងអស់មាន១៨គូ ក្នុងពេលតែមួយជាមួយ មឿន។ ខ្មែរក្រហមតម្រូវឲ្យយុវជននិងយុវនារី អង្គុយទល់មុខគ្នារួចប្រកាសជាគូស្រករ ហើយគូស្រករនីមួយៗត្រូវឡើងចាប់អារម្មណ៍

និងប្តេជ្ញាថាស្រឡាញ់គ្នាអស់មួយជីវិត។ បន្ទាប់ពីរៀបការបាន៧ខែ នៅក្នុងឆ្នាំ១៩៧៨ ដដែល មឿន និងប្រពន្ធ ត្រូវបានកត់ឈ្មោះទៅរស់នៅខេត្តពោធិ៍សាត់ ប៉ុន្តែដោយសារប្រពន្ធរបស់ មឿន បេះត្បាញក្រមា ទើបប្រធានភូមិទុក មឿន និងភរិយានៅភូមិសិន។ គាត់ទាំងពីរត្រូវបានផ្លាស់ប្តូរទីកន្លែងពីខាងត្បូងភូមិក្រូចឲ្យទៅរស់នៅក្នុងផ្ទះអ្នកដែលបានជម្លៀសទៅពោធិ៍សាត់។

ក្រោយមក មឿន និងភរិយា ត្រូវខ្មែរក្រហមផ្លាស់ឲ្យផ្លោះទៅកាន់ក្រចាប់។ នៅទីនោះ គាត់ឃើញមនុស្សជាច្រើននាក់ដែលខ្មែរក្រហមជម្លៀសមកពីស្រុកផ្សេងៗ កំពុងតែឆ្លងទូកហើយកម្លាំងរណសិរ្សរំដោះជាតិកម្ពុជាបានវាយចូលមកកាន់តែកៀក។ ក្នុងរយៈពេលមួយយប់ ប្រជាជនបានឆ្លងទូកទៅដល់ប្រាស្នា ដែលជាកន្លែងដែលខ្មែរក្រហមវាយសម្លាប់មនុស្ស។ កងទ័ពរណសិរ្សសង្គ្រោះជាតិកម្ពុជាមកដល់កំពង់សីង និង អ្នកលឿង បានបាញ់កាំភ្លើងឡើងលើធ្វើជាសញ្ញាឲ្យប្រជាជនត្រឡប់មកផ្ទះវិញ។ ប្រជាជន រួមជាមួយ មឿន សប្បាយចិត្តណាស់ រួចបររទេះដឹកប្រពន្ធវិលមកផ្ទះវិញ។ មឿនទៅប្រមូលស្រូវ អង្ករ អំបិល ប្រហុក ស្ករ ចែកគ្នា។

ពីរខែក្រោយមក នៅក្នុងភូមិរបស់ មឿន បានរៀបចំធ្វើពិធីកាត់ទោសកម្មាភិបាលខ្មែរក្រហមដែលបានប្រព្រឹត្តអំពើអាក្រក់មកលើប្រជាជន ដោយឲ្យកម្មាភិបាលខ្មែរក្រហមទាំងនោះឈរនៅចំពោះមុខប្រជាជន និងឲ្យនិយាយពាក្យសុំទោសទៅកាន់ប្រជាជន ព្រមទាំងនិយាយពីទោសកំហុសដែលខ្លួនបានប្រព្រឹត្តពីមុនមក និងសុំឲ្យប្រជាជនលើកលែងទោស។ ប្រជាជនខ្លះបានជេរ ប្រជាជនខ្លះមិនចង់ស្តាប់នូវពាក្យសុំទោសរបស់កម្មាភិបាលខ្មែរក្រហមនោះទេ និងចង់ចូលទៅវាយកម្មាភិបាលខ្មែរក្រហមនោះដើម្បីសងសឹង។ ប៉ុន្តែត្រូវបានហាមឃាត់ដោយមេភូមិ មេឃុំ ដែលទើបតែតែងតាំងថ្មីៗ។ រីឯ មឿន ក៏មានវត្តមាននៅកន្លែងកាត់ទោសដែរ។ ដំបូងគាត់ខឹងកម្មាភិបាលខ្មែរក្រហមនោះដែរ ប៉ុន្តែចុងក្រោយគាត់បែរជាអាណិត និងមិនចង់ធ្វើអ្នកទាំងនោះវិញ។ បន្ទាប់ពីកាត់ទោសហើយ ប្រជាជននាំគ្នាវិលត្រឡប់មកផ្ទះរៀងខ្លួនវិញ ប៉ុន្តែប្រជាជនខ្លះមានការមិនសុខចិត្តទេ ក៏កាន់កាំបិតទៅគំរាមអតីតកម្មាភិបាលឲ្យលត់ជង្គង់សូមអភ័យទោស។ កម្មាភិបាលខ្មែរក្រហមខ្លះនៅក្នុងភូមិដដែល ខ្លះក៏រត់ចេញពីភូមិ ព្រោះខ្លាចប្រជាពលរដ្ឋនៅក្នុងភូមិធ្វើបាប និងសម្លាប់ដើម្បីសងសឹក។ ក្រោយមក ប្រជាជនមានសិទ្ធិសេរីភាពឡើងវិញ ដោយអ្នកខ្លះប្រកបរបររកស៊ី អ្នកខ្លះធ្វើស្រែ ចំណែក មឿន ត្រូវបានរដ្ឋអំណាចលើកឲ្យធ្វើជាប្រធានភូមិតាំងពីឆ្នាំ១៩៧៩ មករហូតដល់ឆ្នាំ១៩៩៥ ទើបគាត់លាឈប់ពីការងារប្រធានភូមិ ហើយមកធ្វើជាអាចារ្យវត្តរហូតមកដល់បច្ចុប្បន្ន។

---

## សេក ឈន

សេក ឈន អាយុ៦៦ រស់នៅភូមិអង្គ ឃុំជាងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ នៅវ័យកុមារភាព ឈន ចូលសិក្សានៅសាលាបឋមសិក្សា ព្រៃម្លង។ គាត់បានរៀនសូត្រដល់ត្រឹមថ្នាក់ទី៨ចាស់ប៉ុណ្ណោះ នៅក្នុងស្រុកកំណើត ហើយបានបន្តការសិក្សានៅសាលាបឋមសិក្សាបឹងកេងកង ក្នុងក្រុងភ្នំពេញទៀត នៅឆ្នាំ១៩៧២។ គាត់បានរៀនដល់ថ្នាក់ទី៥ចាស់។ ក្រៅពីការសិក្សា ឈនបានប្រកបរបរធាក់ស៊ីក្លូដើម្បីរកចំណូលចិញ្ចឹមខ្លួនជីវិតក្នុងពេលរៀនសូត្រ។ ឈន បានប្រាប់ថា នៅទីក្រុងភ្នំពេញក៏មានការទម្លាក់គ្រាប់ដែរ។ ក្រោយថ្ងៃខ្មែរក្រហមទទួលជ័យជម្នះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ឈន ត្រូវបានបង្ខំឲ្យចាកចេញពីក្រុងភ្នំពេញ ត្រឡប់ទៅស្រុកកំណើតឯភូមិអង្គវិញ។ មកដល់វត្តក្រចាប់ ឈន ត្រូវអង្គការចាប់ និងឃុំខ្លួនអស់រយៈពេល៩ខែ ដោយសារតែក្រុមគ្រួសាររបស់គាត់មានជាប់ពាក់ព័ន្ធជាមួយរដ្ឋការ លន់ នល់។ កម្មាភិបាលខ្មែរក្រហមនៅក្នុងមន្ទីរសន្តិសុខបានប្រើឈនឲ្យសែងគ្រាប់ ដឹកសន្ទូរនៅព្រៃគួច ដឹករណ្តៅដាំដើមចេក លើកទំនប់រាំងកូនសត្វសម្រាប់ស្តុកទឹកធ្វើស្រែ ស្រោចដំណាំ និងច្រូតស្រូវ។



សេក ឈន អាយុ៦៦ រស់នៅភូមិអង្គ ឃុំជាងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។
(ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅខែធ្នូ ឆ្នាំ១៩៧៧ ឈន និងបុរសៗជាច្រើនទៀត ត្រូវបានអង្គការរៀបការឲ្យ ដែលកម្មវិធីនៃការរៀបការនេះត្រូវបានធ្វើឡើងនៅប៉ែកខាងក្រោយវត្តព្រៃម្លូង។ ក្រោយរៀបការ ឈន ត្រូវបានអនុញ្ញាតឲ្យរស់នៅជាមួយប្រពន្ធត្រឹមតែ៣ថ្ងៃ និងតម្រូវឲ្យត្រឡប់ទៅកាន់ការដ្ឋានការងារវិញ ដែលលើកនេះគាត់ត្រូវកម្មាភិបាលខ្មែរក្រហមប្រើឲ្យសែងយោធារបួសនៅឯសមរភូមិមុខ ដែលមានទីតាំងជាប់នឹងព្រំប្រទល់វៀតណាម។

នៅចុងឆ្នាំ១៩៧៨ ឈន ត្រូវបានបង្ខំឲ្យចាកចេញពីស្រុកកំណើត ទៅនៅត្រពាំងប្របូស ស្ថិតក្នុងស្រុកព្រះស្តេច ជាទីកន្លែងដែលគាត់បានឃើញវត្តមានរបស់កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពវៀតណាមនៅទីនោះ និងបានទទួលការណែនាំឲ្យវិលត្រឡប់មកកាន់ស្រុកកំណើតវិញ។ ឈន និងប្រជាជនដទៃទៀតបានធ្វើដំណើរវិលត្រឡប់មកកាន់ស្រុកកំណើតរៀងៗខ្លួនវិញ។ ក្នុងពេលជួបជាមួយក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ឈន បានរំឭកថា គាត់មានជំងឺប្រចាំកាយ (ជំងឺសន្លាក់) រហូតដល់សព្វថ្ងៃនេះ គឺបណ្តាលមកពីធ្វើការហួសកម្លាំងក្នុងរបបខ្មែរក្រហម។

## ទីក ហោ

ទីក ហោ អាយុ៧២ឆ្នាំ រស់នៅភូមិពញាកើត ឃុំជាងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ នៅពេលក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទៅដល់ផ្ទះរបស់ ហោ, ហោ បានចេញមកទទួលស្វាគមន៍ក្រុមការងារដោយទឹកមុខញញឹមញញែមនិងរួសរាយរាក់ទាក់។ ក្រុមគ្រួសាររបស់ ហោ និង ហោ បានអញ្ជើញក្រុមការងារឲ្យចូលទៅអង្គុយនៅក្នុងខ្ទមប្រក់ស្លឹកត្នោតមួយ ដែលស្ថិតនៅខាងមុខផ្ទះរបស់គាត់។ នៅខាងមុខខ្ទមរបស់ ហោ មានវាលស្រែ និងស្រូវទុំ លាតសន្ធឹងដាច់កន្ទុយភ្នែកលាយជាមួយនឹងខ្យល់បក់លើយៗចូលមកក្រោមខ្ទមដំបូលប្រក់ស្លឹកត្នោតផងនោះ ធ្វើឲ្យយើងទាំងអស់គ្នាមានអារម្មណ៍ស្រស់ស្រាយ និងរីករាយក្នុងការស្តាប់រឿងរ៉ាវក៏ដូចជាបទពិសោធន៍របស់គាត់ដែលបានជួបប្រទះនិងឆ្លងកាត់របបខ្មែរក្រហម។ ហោ និយាយរៀបរាប់ថា បច្ចុប្បន្នត្រចៀករបស់គាត់ស្តាប់មិនសូវឮទេក្នុងរយៈពេលមួយឆ្នាំចុងក្រោយនេះ។

ហោ បន្តថានៅក្នុងរបបខ្មែរក្រហមជារៀងរាល់ថ្ងៃ គាត់រស់ទាំងមានភាពភ័យខ្លាចព្រោះគាត់ជាប្រជាជនត្រៀម មិនដឹងថាថ្ងៃណាខ្មែរក្រហមយកគាត់ទៅសម្លាប់ទេ។ គាត់ស្ទើរតែបាត់បង់ស្មារតីនៅ



សេក ឈន អាយុ៦៦ រស់នៅភូមិអង្គ ឃុំជាងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង កំពុងផ្តល់បទសម្ភាសន៍ដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា។
(ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ពេលដែលគាត់បានឃើញផ្ទាល់នឹងភ្នែកនូវទិដ្ឋភាពខ្មែរក្រហមបណ្តើរមនុស្សជាច្រើននាក់យកទៅសម្លាប់នៅទួលតាអន។ គាត់មិនហ៊ានតត្អូញត្អែរជាមួយការងារដែលខ្មែរក្រហមដាក់ឲ្យធ្វើឡើយ។ គាត់ខំប្រឹងធ្វើការដើម្បីឲ្យតែបានរស់ជីវិត។ ហោ គឺជាកូនកសិករក្រីក្រម្នាក់ដែលមិនបានទទួលឱកាសសិក្សាទេ។ នៅឆ្នាំ១៩៧០ ដោយសារតែនៅបរិវេណផ្ទះរបស់ ហោ មានព្រៃស្ដុកច្រើន ទើបទាហានធីវគីចូលមកអុកឡុក ហើយម្យ៉ាងទៀតមិនអាចទ្រាំទ្រនូវការទម្លាក់គ្រាប់បែកនៅក្នុងភូមិបាន ហោ និងគ្រួសារបានសម្រេចចិត្តចាកចេញពីផ្ទះទៅរស់នៅក្នុងភូមិ ពញាកើត ឃុំជាងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែងវិញ។ មិនដូចការគិតឡើយ ការមករស់នៅក្នុងភូមិពញាកើតមិនសូវខុសប្លែកពីភូមិប្រប្រត់ទេ ការទម្លាក់គ្រាប់បែក និងវត្តមានទាហានធីវគីនៅតែមានស្ទើរតែពេញក្នុងភូមិពញាកើត។

គ្រាប់បែកដែលត្រូវបានទម្លាក់ដោយអាមេរិកធ្វើឲ្យ ហោ និងគ្រួសាររត់ភៀសខ្លួនទៅរកតំបន់សុវត្ថិភាពជាច្រើនកន្លែងទៀត។ មាន់ ទា ជ្រូក គោ ក្របី ដែល ហោ ខំចិញ្ចឹមត្រូវទាហានធីវគីចាប់យកទៅអស់។ ហោ ត្រឡប់មកនៅផ្ទះវិញ នៅឆ្នាំ១៩៧៤ នៅពេលកងទ័ពធីវគី និងយៀកកុង បានចាកចេញពីទឹកដីកម្ពុជាអស់។

នៅឆ្នាំ១៩៧៥ បន្ទាប់ពីខ្មែរក្រហមទទួលជ័យជម្នះទាំងស្រុង នៅក្នុងភូមិរបស់ ហោ បានចាប់ផ្ដើមរៀបចំរចនាសម្ព័ន្ធការងារសម្រាប់ប្រជាជនធ្វើ។ ការងារដំបូងសម្រាប់គាត់ គឺភ្ជួរស្រែ១ហិកតា ក្នុងមួយថ្ងៃ ប៉ុន្តែនៅពេលគាត់ធ្វើការងារលឿនជាងការកំណត់នោះគាត់នឹងត្រូវបានចាត់តាំងឲ្យទៅជួយដកស្ទូង លើកដី លើកភ្លឺស្រែ និងឃ្វាលគោក្របីនៅរដូវវស្សា។ រីឯរដូវប្រាំង ប្រធានសហករណ៍របស់ ហោ ឈ្មោះ ស្រី ឈុំ បានចាត់តាំងគាត់ឲ្យទៅស្តារត្រពាំងនៅជិតៗភូមិ។ នៅឆ្នាំ១៩៧៦ ហោ បានទៅដាំពោតនៅពាមជរ។ នៅទីនោះ ហោ បានទទួលការពិន័យម្ដង គឺឈរជើងមួយជាមួយនឹងមនុស្ស១១នាក់ទៀតតាំងពីល្ងាចរហូតដល់ម៉ោង១២យប់ ដោយសារគាត់ចាប់កន្ដែបអាំងហូបជាមួយនឹងមនុស្ស១១នាក់នោះ។ នៅឆ្នាំ១៩៧៧ នៅពេលដែលប្រមូលផលពោតរួចរាល់ ហោ បានត្រឡប់មកធ្វើស្រែនៅក្នុងភូមិវិញ។

នៅចុងឆ្នាំ១៩៧៨ ហោ បានរៀបការប្រពន្ធឈ្មោះ ព្រំ ខិន ដែលជាគ្រូបង្រៀនកុមារតាមការចាត់ចែងរបស់ខ្មែរក្រហម។ នៅដើមឆ្នាំ១៩៧៩ ពេលសភាពការណ៍កងទ័ពវៀតណាមវាយចូលមក ប្រធានសហករណ៍បានកៀរប្រជាជនរួមជាមួយនឹងគ្រួសាររបស់ ហោ ឲ្យទៅស្រុកព្រះស្ដេចដោយប្រាប់ហេតុផលថា ឥឡូវខ្មាំងបានចូលមកហើយ ដូច្នេះយើងត្រូវតែដកថយជាប្រញាប់ ទុកឲ្យកងទ័ពនៅតតាំងគ្នាទៅ។ ពេលទៅដល់ស្រុកព្រះស្ដេច ប្រជាជនបានស្រែកថាអាពតបែកហើយៗ ឮសូរដូច្នេះ ហោ មានការត្រេកអរណាស់ ហើយប្រញាប់ប្រញាល់ត្រឡប់មកស្រុកកំណើតវិញ។ ហោ ទៅប្រមូលស្រូវអង្ករចាននាំងយកទៅផ្ទះវិញ ។ ចាប់តាំងពីពេលនោះមកប្រជាជនមានសិទ្ធិសេរីភាពឡើងវិញ ហើយប្រកបរបររៀងៗខ្លួន ចំណែក ហោ បានធ្វើស្រែរហូតមកដល់បច្ចុប្បន្ន។

---

## **ទឹក រឹម**

រឹក រឹម ភេទប្រុស អាយុ៧០ឆ្នាំ រស់នៅភូមិពញាកើត ឃុំជាងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ នៅអាយុ៩ឆ្នាំ រឹម បានចូលរៀននៅសាលាបឋមសិក្សាពេជ្ឈរតន៍។ គាត់បានរៀនពីថ្នាក់ទី១២ ដល់ថ្នាក់ទី៩ ទើបឈប់ដោយសារតែមានសង្គ្រាមកើតឡើងច្រើនលើកច្រើនសារនៅក្នុងភូមិពេជ្ឈរតន៍ និងមានការទម្លាក់គ្រាប់បែកជាច្រើន។ នៅឆ្នាំ១៩៧១ រឹម បានរៀបការជាមួយនារីម្នាក់ឈ្មោះ ប្រាក់ អ៊ី រស់នៅក្នុងភូមិពញាកើត។ ប្រជាជននៅក្នុងភូមិ ក៏ដូចជាគ្រួសារ រឹម បានរត់ចេញពីផ្ទះរាល់ពេលដែលឃើញមានវត្តមានកងទ័ព ធីវគី ចូលមកម្ដងៗ។ ចាប់តាំងពីឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៨ រឹម ត្រូវអង្គការចាត់តាំងឲ្យភ្ជួរស្រែ, ឃ្វាលក្របី, ដកសំណាប សែង

កងទ័ពរបួស ឬស្លាប់នៅក្នុងសមរភូមិមុខ និងធ្វើចម្ការ។ នៅចុងឆ្នាំ១៩៧៨ រីម និងអ្នកឯទៀត ត្រូវអង្គការរៀបចំជម្លៀសទៅភាគខាងលិចប្រទេសកម្ពុជា ប៉ុន្តែបានបញ្ឈប់ដំណើរនៅពេលកងទ័ពស្ម័គ្រចិត្តវៀតណាមបានចូលមកដល់ពេលដែលគាត់និងប្រជាជនផ្សេងទៀតធ្វើដំណើរដល់អ្នកលឿង។ នៅឆ្នាំ១៩៩២ រីម ត្រូវបានជ្រើសរើសឲ្យធ្វើជាមេភូមិរយៈ១០ឆ្នាំ ទើបគាត់ឈប់។ សព្វថ្ងៃ រីម មានកូន១០នាក់ ស្រី៦នាក់ ហើយគាត់រស់នៅជាមួយកូនស្រីពៅរបស់គាត់។



វីក រីម អាយុ៧០ឆ្នាំ រស់នៅភូមិពញាកើត ឃុំជាងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)







រូបភាពនៅក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារខេត្តតាកែវ

*កាន់ សុភាព, សៀង កញ្ញា, មឿន ហាច, ចាន់ ទីន និង ឌីមសុខគា*

### ម៉ែន ខេម

ខ្ញុំឈ្មោះ ម៉ែន ខេម ភេទប្រុស អាយុ៥៩ឆ្នាំ។ ខ្ញុំមានឪពុកឈ្មោះ ម៉ែន ហ៊ឹម និង ម្ដាយឈ្មោះ តឹង ណែម។ ខ្ញុំមានបងប្អូនបង្កើតសរុប៨នាក់ ដែលក្នុងនោះមានស្រី៣នាក់ និងប្រុស៥នាក់។ ខ្ញុំមានស្រុកកំណើតនៅក្នុងភូមិមហាសេនា ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ។ នៅក្នុងឆ្នាំ១៩៨២ ខ្ញុំបានរៀបការជាមួយនារីម្នាក់ឈ្មោះ សោម សៀង ព្រមទាំងមានកូនចំនួន៣នាក់ ប្រុស១ និងកូនស្រី២នាក់។

នៅចន្លោះឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ប្រទេសយើងកំពុងស្ថិតនៅក្នុងភាពចលាចល និងមានការបាតុកម្មជាញឹកញាប់ ជាហេតុមិនអាចឲ្យសិស្សរៀនបានជាប់លាប់។ ប្រជាជនពិបាកក្នុងការប្រកបរបររកស៊ី។ ពេលនោះខ្ញុំនៅតូចនៅឡើយ ដូច្នេះខ្ញុំមិនសូវដឹងអំពីបាតុកម្មនោះប៉ុន្មានទេ។ ខ្ញុំបានត្រឹមតែដឹងថាប្រជាជនធ្វើបាតុកម្មនៅផ្សារអង្គតាសោម និងផ្សារតាកែវ ប៉ុន្តែមិនមានកាំភ្លើងឬអាវុធដែលបង្កជាគ្រោះថ្នាក់ធ្ងន់ធ្ងរទេ។ ប្រជាជនខ្លះទៀតដើរដោយថ្មើរជើងដើម្បីទៅចូលរួមធ្វើបាតុកម្ម។ ពេលនោះខ្ញុំនៅក្មេងមិនហ៊ានចេញទៅណាទេ គឺនៅសម្ងំតែក្នុងផ្ទះ។ ក្រោយមក មានការប្រយុទ្ធគ្នារវាងកងទ័ពរំដោះខ្មែរក្រហម និងកងទ័ព លន់ នល់ និងមានការបាញ់ផ្លោងដាក់គ្នាទៅវិញទៅមក ធ្វើឲ្យប្រជាជនជាច្រើនស្លាប់ និងរងរបួស។



ម៉ែន ខេម អាយុ៥៩ឆ្នាំ។ ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់មកកងទ័ពខ្មែរក្រហមបានទទួលជ័យជម្នះលើកងទ័ព លន់ នល់ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ខ្មែរក្រហមបានជម្លៀសប្រជាជនមកពីទីក្រុងភ្នំពេញឲ្យទៅរស់នៅតាមទីជនបទ។ ខ្មែរក្រហមបានបែងចែកប្រជាជនទៅតាមកងនីមួយៗ មានដូចជា កងនារី កងកុមារ កងពិសេស និងដើម្បីងាយស្រួលក្នុងការធ្វើការងារ។ ខ្មែរក្រហមឲ្យប្រជាជនហូបបាយរួមតាមកងរៀងៗខ្លួន។ មនុស្សភាគច្រើនត្រូវបានស្លាប់ដោយសារធ្វើការហួសកម្លាំង មិនមានពេលសម្រាក និងការសម្លាប់ដោយគ្មានការអាណិត

អាសូរពីយោធាខ្មែរក្រហម។ ចំណែកខ្ញុំ ត្រូវបានខ្មែរក្រហមចាត់ចូលទៅក្នុងកងកុមារ និងឲ្យខ្ញុំទៅរែកដីដំបូកយកទៅចាក់នៅក្នុងស្រែ។ ខ្មែរក្រហមប្រើខ្ញុំឲ្យធ្វើការច្រើនហួសកម្លាំង ចំណែកឯការហូបចុកខ្មែរក្រហមឲ្យហូបតែបបររាវជាមួយសម្លត្រកួន និងសម្លព្រលឹតតែប៉ុណ្ណោះ។ ខ្មែរក្រហមបានបំបែកឪពុកម្តាយបងប្អូនខ្ញុំមិនឲ្យរស់នៅជាមួយគ្នាទេ។ ខ្មែរក្រហមចាត់តាំងគ្រួសារខ្ញុំឲ្យទៅធ្វើការនៅតាមកងផ្សេងៗ។

នៅក្នុងឆ្នាំ១៩៧៧ មីងរបស់ខ្ញុំដែលមានប្តីធ្វើជាយោធាខ្មែរក្រហម បានបញ្ជូនខ្ញុំឲ្យទៅរស់នៅខេត្តស្វាយរៀង។ នៅទីនោះខ្ញុំអាចហូបចុកគ្រាប់គ្រាន់ ហើយការងារក៏មិនធ្ងន់ធ្ងរដែរ គឺខ្មែរក្រហមឲ្យខ្ញុំយាមឃ្លាំង។ រហូតដល់ឆ្នាំ១៩៧៩ មានព្រឹត្តិការណ៍ចលាចលកើតឡើង ដោយសារមានកងទ័ពវៀតណាមបានវាយចូលមកដើម្បីផ្តួលរបបខ្មែរក្រហម។ នៅពេលនោះមានការប្រយុទ្ធគ្នាទៅវិញទៅមករវាងកងទ័ពវៀតណាម និងកងទ័ពខ្មែរក្រហម ដែលបង្កឲ្យមានការស្លាប់ជាបន្តបន្ទាប់។

ជាចុងក្រោយរបបខ្មែរក្រហមត្រូវបានផ្តួលរលំ ហើយខ្ញុំក៏ត្រឡប់ពីស្វាយរៀងមករស់នៅស្រុកកំណើតនៅខេត្តតាកែវវិញ។ ជាសំណាង សមាជិកគ្រួសាររបស់ខ្ញុំមិនមានស្លាប់ឬក៏បាត់ខ្លួនឡើយ។ ខ្ញុំបានបន្តការសិក្សាដល់ថ្នាក់ទី៨ និងមានចំណេះដឹងរហូតមកដល់សព្វថ្ងៃ។

## សោម សៀង

ខ្ញុំឈ្មោះ សោម សៀង អាយុ៥៧ឆ្នាំ រស់នៅក្នុងភូមិមហាសេនា ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ។ ខ្ញុំបានបាត់បង់ឪពុក និងបងប្រុសបង្កើត២នាក់។ ការព្រាត់ប្រាស់នេះធ្វើឲ្យខ្ញុំចងចាំមិនភ្លេចទេ។ កងទ័ពខ្មែរក្រហមបានចាប់ឪពុកខ្ញុំ និងអ្នកពាក់ព័ន្ធផ្សេងទៀតដែលខ្មែរក្រហមចោទថាជាទាហានពីសម័យ លន់ នល់ ដើម្បីយកទៅសម្លាប់ចោល។ នៅក្នុងចំណោមអ្នកទាំងអស់នោះគឺខ្មែរក្រហមបានសម្លាប់ឪពុករបស់ខ្ញុំដែរ។ ចំណែកបងប្រុសខ្ញុំម្នាក់បានស្លាប់ដោយសាររថក្រោះកិន និងម្នាក់ទៀតបានបាត់ខ្លួន។ ម្តាយខ្ញុំនៅពេលនោះកំពុងតែពរពោះប្អូនខ្ញុំ ក្រោយពីដឹងថាប្តី និងកូនប្រុសត្រូវស្លាប់បែបនេះ គាត់ឈឺចាប់ និងពិបាកចិត្តយ៉ាងខ្លាំង។ ខ្មែរក្រហមបានចាត់ខ្ញុំឲ្យចូលធ្វើការនៅក្នុងកងកុមារ ហើយខ្ញុំត្រូវរស់នៅបែកពីម្តាយ និងប្អូន។ ខ្មែរក្រហមបានប្រើខ្ញុំឲ្យទៅរែកដី ខ្ញុំមានអារម្មណ៍ថាហត់ហេវអស់កម្លាំងយ៉ាងខ្លាំង។ មានថ្ងៃមួយដោយសារតែហេវខ្លាំងពេក ខ្ញុំទៅលួចបាយពីប្រជាជនហូប។ មិត្តភក្តិនៅក្នុងកងបាននិយាយថា ប្រយ័ត្នអង្គការឃើញ។ ខ្ញុំបានតបទៅអ្នកទាំងថា ឃើញក៏ឃើញទៅព្រោះអង្គការប្រើអញឲ្យធ្វើការងារច្រើន ប៉ុន្តែមិនឲ្យស៊ីបាយឆ្អែត។ ពេលនោះប្រធានក្រុមបានស្តាប់ឮ ក៏បម្រុងរាយការណ៍ទៅថ្នាក់លើ ឲ្យយកខ្ញុំទៅសម្លាប់ចោលហើយ ប៉ុន្តែសំណាងល្អអ៊ំប្រុសម្នាក់បានជួយនិយាយជាមួយប្រធានថា កុំទៅឲ្យវែងឆ្ងាយអីអាណិតគ្នា គឺគ្នានៅក្មេងនិយាយមិនចេះគិតចឹងហើយ។ ពេលនោះខ្ញុំត្រូវប្រធានកងលើកលែងឲ្យមានជីវិតរស់បន្តទៀតរហូតមកដល់សព្វថ្ងៃនេះឯង។



សោម សៀង (ខាងស្តាំ) អាយុ៥៧ឆ្នាំ រស់នៅក្នុងភូមិមហាសេនា ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារ)

## ស៊ិន លី

ស៊ិន លី រស់នៅភូមិអណ្តូងថ្ម ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ។ លី និយាយរៀបរាប់ពីជីវិតដែលបានឆ្លងកាត់របបខ្មែរក្រហមថា នៅពេលដែលប្រទេសស្ថិត



សោម សៀង (ខាងស្តាំ) អាយុ៥៧ឆ្នាំ រស់នៅក្នុងភូមិមហាសេនា ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រោមការគ្រប់គ្រងរបស់ ប៉ុល ពត ខ្ញុំត្រូវបានចាត់ឲ្យចូលក្នុងកងកុមារ។ មេកងកុមារប្រើខ្ញុំឲ្យរើសអាចម៍គោ និងទៅស្ទូងស្រូវ។ ខ្ញុំមិនចេះស្ទូងស្រូវឡើយដូច្នេះមេកងបានសែងខ្ញុំទម្លាក់ចូលក្នុងថ្លុកអាចម៍ក្របី ហើយវាយខ្ញុំថែមទៀត។ នៅរដូវស្រូវទុំ មេកងប្រើឲ្យខ្ញុំប្រូតពីព្រឹករហូតទល់យប់។ ពេលប្រូតស្រូវរួច មេកងបញ្ជូនឲ្យខ្ញុំដើរកាត់ជញ្រ្ជាំង និងកាត់ដើមកន្ទ្រានខែត្រ មកចិញ្រ្ចាំដាក់ចូលក្នុងស្រែធ្វើជី។ នៅពេលធំពេញវ័យមេកងខ្មែរក្រហមបានប្រើឲ្យខ្ញុំរែកដីដំបូក ប្រសិនបើរែកមិនបានតាមផែនការកំណត់ គឺមេកងមិនចែកបាយឲ្យហូបឡើយ។

ការហូបចុកវិញគឺមិនសាកសមទៅនឹងពលកម្មឡើយ។ ខ្ញុំហូបតែបបរលាយជាមួយសម្លព្រលិតដែលមិនបានបកសម្បកឡើយ។ ចុងភៅកាត់ដើមព្រលិតរួមទាំងស្លឹកស្លឹក ដាក់ចូលបបរឲ្យយើងហូបពីដងក្នុងមួយថ្ងៃ។ ចំណែកខោអាវ ខ្មែរក្រហមចែកឲ្យប្រជាជនម្នាក់តែ១សម្រាប់ប៉ុណ្ណោះ។ ពេលមកពីធ្វើការវិញ ខ្ញុំងូតទឹកនិងយកខោអាវដែលសើមទៅហាលថ្ងៃ។ បើខ្ញុំហាលមិនស្ងួត ពេលដេកខ្ញុំគ្មានខោអាវស្លៀកពាក់ឡើយ។ ពេលនោះខ្មែរក្រហមបែងចែកឲ្យកុមារា និងកុមារី ដេកនៅកន្លែងផ្សេងគ្នា។ ពេលរបបខ្មែរក្រហមជិតដួលរលំ អ្នកនៅក្នុងកងស្រែកប្រកាសថា ថ្ងៃនេះចុងភៅធ្វើគុយទាវឲ្យហូប ប៉ុន្តែមិនទាន់បានធ្វើផង ស្រាប់តែប្រជាជនផ្អើលរត់ឡោរត់ចេញអស់។ ខ្ញុំមិនដឹងថាមានមន្ទីរសន្តិសុខទេ ប៉ុន្តែខ្ញុំបានឃើញខ្មែរក្រហមយកមនុស្សទៅវាយចោល ហើយជារៀងរាល់ថ្ងៃវេលាម៉ោង៤ល្ងាច ខ្មែរក្រហមចាប់ផ្តើមចាក់មេក្រូដើម្បីកុំឲ្យប្រជាជនឮសម្រែករបស់អ្នកទោសពេលដែលខ្លួនវាយសម្លាប់ ឬធ្វើទារុណកម្ម។ មានថ្ងៃមួយនោះ ខ្ញុំបានប្រទះឃើញការវាយសម្លាប់មនុស្ស នៅពេលដែលខ្ញុំរត់ទៅលេងម្តាយនៅឯភូមិ។ ខ្ញុំបានឮសំឡេងសម្រែកក៏បានលបលួចមើល ហើយឃើញខ្មែរក្រហមសម្លាប់មនុស្សជាច្រើននាក់។ ដោយសេចក្តីភិតភ័យ ខ្ញុំបានទៅប្រាប់ឪពុករបស់ខ្ញុំ ពេលនោះ ឪពុករបស់ខ្ញុំបានយកដៃខ្ទប់មាត់ខ្ញុំ ហើយនិយាយប្រាប់ថាកូនឯងនៅតូចអត់ដឹងអីទេ។ ហេតុការណ៍ដែលខ្ញុំនៅចងចាំជាងគេ គឺខ្មែរក្រហមប្រើឲ្យស្ត្រីមានផ្ទៃពោះជិតសម្រាលកូនម្នាក់កាប់រណ្តៅ។ ខ្មែរក្រហមបញ្ជាឲ្យស្ត្រីនោះអង្គុយនៅមាត់រណ្តៅ បន្ទាប់មកបានវាយស្ត្រីចោល។ ដៃដន្យស្ត្រីនោះក៏សម្រាលកូន។ ខ្មែរក្រហមបានសម្លាប់ក្មេងនោះរួចធាក់ចូលក្នុងរណ្តៅស្លាប់ទាំងពីនាក់ម្តាយ និងកូន។

## ញិល សារី

ញិល សារី បច្ចុប្បន្នរស់នៅភូមិអណ្តូងថ្ម ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ បាននិយាយរៀបរាប់ថានៅពេលដែលខ្មែរក្រហមឡើងកាន់អំណាចថ្មីៗ ខ្មែរក្រហមបញ្ជូលខ្ញុំទៅក្នុងកងកុមារឈានមុខ។ មេកងកុមារប្រើខ្ញុំឲ្យរែកដីដំបូកមួយថ្ងៃ៣០០អំរែក និងរកទំពាំង។ រាល់ពេលចេញទៅរកទំពាំងម្តងៗ ខ្មែរក្រហមមានស្ពាយកាំភ្លើងអាកា បានជូនខ្ញុំទៅ ហើយត្រួតពិនិត្យតាមដានខ្ញុំគ្រប់ពេល រួមទាំង កាប់ទំពាំង បកសម្បកទំពាំង និងបន្ទោបង់។ ចំណែកផ្លូវទៅរកទំពាំងនោះទៀតសោតគឺលំបាកខ្លាំងណាស់។ ខ្ញុំដើរទៅរកទំពាំងតាមផ្លូវចិនយំ។ នៅពេល មេឃភ្លៀងរអិលខ្លាំងណាស់។ ថ្ងៃមួយខ្ញុំដើររអិលហៀបធ្លាក់ចូលទៅក្នុងជ្រោះ ប៉ុន្តែត្រូវបាន




ញិល សារី រស់នៅភូមិអណ្តូងថ្ម ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អ្នកនៅក្នុងកងចាប់ដៃទាញឡើងមកលើវិញ។ ខ្ញុំបន្តដំណើរទៅមុខ ប៉ុន្តែចៃដន្យជួបយាយរបស់ខ្ញុំ នៅតាមផ្លូវ។ យាយរបស់ខ្ញុំបានសុំទំពាំងខ្លះពីខ្ញុំ។ ខ្ញុំក៏យកទំពាំង៣ទៅ៤ដើមឲ្យទៅយាយ។ ពេលមកដល់កន្លែង មេកងបានចោទខ្ញុំថា សេ.អ៊ី. អា យកទំពាំងឲ្យខ្មាំង។ សំណាង អ្នកគ្រប់គ្រងម្នាក់ឈ្មោះ ជីង ជួយនិយាយដោះសារថា ទំពាំងជ្រុះព្រោះគាត់នៅក្មេងស្តាយទំពាំងច្រើនៗអញ្ចឹងពេលដើរជ្រុះមិនដឹងខ្លួនទេ មិនមែនខ្ញុំយកទំពាំងឲ្យទៅអ្នកផ្សេងទេ។ មេកង ឈប់សួរទៀត ទើបខ្ញុំបានរួចខ្លួន។

ក្រោយមកទៀតខ្ញុំមានអាការៈ ឈឺក្បាល និងអស់កម្លាំង។ ខ្ញុំទៅធ្វើការមិនរួចក៏សុំច្បាប់ប៉ុន្តែមេកងមិនអនុញ្ញាតទេ។ ខ្ញុំបានរត់ទៅពួន ដោយបានបងជីដូនមួយដែលជាមេកងជួយលាក់ការណ៍។ ខ្ញុំចូលពួនកន្ទេលរួចហើយបងជីដូនមួយ និងអ្នកផ្សេងទៀតអង្គុយពីលើ ទើបមេកងរបស់ខ្ញុំរកមិនឃើញ។ ខ្ញុំមិនដឹងថា ទំពាំងដែលរកខ្ញុំជីកបានទាំងប៉ុន្មាន ខ្មែរក្រហមយកទៅណាទេ ព្រោះខ្ញុំមិនដែលបានហូបទំពាំងនោះទេ។ ចុងភៅស្លតែសម្លត្រកួន ដែលមានទឹកសម្ពណ៌ខ្មៅ និងគ្មានសាច់ឡើយ។ នៅពេលដល់ម៉ោងហូបបាយ ប្រធានកងចាប់ផ្តើមវាយជួង ហើយពេលនោះយើងប្រញាប់រត់ចេញទៅ។ ប្រសិនបើយើងទៅមិនទាន់ យើងមិនបានបាយហូបទេ ព្រោះ១ខ្ទះចុងភៅដាក់អង្ករតែ៤កំប៉ុងប៉ុណ្ណោះ ហើយពេលបាយរួមនោះគឺនៅវត្តនិគ្រោធារាម។ នៅពេលនោះ សម្លៀកបំពាក់គឺខ្ញុំមានតែមួយសម្រាប់ប៉ុណ្ណោះ។ ខ្ញុំគ្មានស្បែកជើងទេ។ នៅពេលផុតទឹករួច គឺខ្ញុំដោះខោអាវហាលហើយចាំរហូតដល់ស្ងួតទើបយកមកស្លៀកពាក់។ ចង្កេះសំពត់របស់ខ្ញុំនៅពេលនោះគឺគ្រាស់ៗដូច្នេះហាលមិនដែលស្ងួតទេ។ ខ្ញុំស្លៀកសំពត់ទាំងសើម ហើយយូៗទៅក៏កើតមានចៃខាំរមាស់អេះគ្រប់ពេល។ ខ្ញុំនៅចាំថា ខ្មែរក្រហមយកប្រជាជនត្រៀមទៅឃុំនៅមន្ទីរក្រាំងតាចាន់ ហើយនៅទីនោះខ្មែរក្រហមតែងតែចាក់មេក្រូ។ នៅពេលខ្ញុំដើរទៅរែកដីដំបូកក្បែរនោះ ប្រធានកងស្រែកប្រាប់មកថា កុំដើរទៅក្បែរនោះ។ ឪពុករបស់ខ្ញុំត្រូវបានខ្មែរក្រហមយកទៅដាក់សម្លាប់នៅក្រាំងតាចាន់ ដោយខ្មែរក្រហមចោទប្រកាន់គាត់ថា ជាប់ខ្សែរយៈជាមួយ តាសាន់ គឺជាមនុស្សដែលខ្មែរក្រហមតាមចាប់។ ឪពុករបស់ខ្ញុំមិនបានឆ្លើយសារភាពតាមអ្វីដែលឆ្មាំចង់បានទេ ព្រោះគាត់មិនដឹងថាខ្លួនគាត់ខុសរឿងអ្វី។ ពេលដែលយោធាខ្មែរក្រហមមកចាប់ឪពុករបស់ខ្ញុំ បានប្រាប់ខ្ញុំឲ្យចាកចេញពីគាត់ ទៅយកសោផ្ទះពីម្តាយចុងរបស់ខ្ញុំដែលកំពុងស្ទូងនៅវាលស្រែថ្នុកតារដ្ឋដើម្បីចាក់សោយកក្រណាត់ទៅដណ្តប់។ គ្រាន់តែខ្ញុំចេញផុតពីឪពុក យោធាខ្មែរក្រហមចូលចាប់ចងដៃឪពុករបស់ខ្ញុំព័ទ្ធទៅក្រោយបណ្តើរយកទៅក្រាំងតាចាន់។ ពេលខ្ញុំត្រឡប់មកពីយកកូនសោវិញ ខ្ញុំក៏ទៅតាមមើលឪពុក ប៉ុន្តែត្រូវយោធាខ្មែរក្រហមបាញ់គម្រាម៣ទៅ៤គ្រាប់។ ខ្ញុំភ័យខ្លាចយ៉ាងខ្លាំងក៏រត់ត្រឡប់មកផ្ទះវិញ។ ពេលបងប្រុសរបស់ខ្ញុំវិលត្រឡប់មកពីឃ្វាលគោវិញ ខ្ញុំបានប្រាប់បងប្រុសថា ឪពុកត្រូវបានខ្មែរក្រហមចាប់យកទៅក្រាំងតាចាន់ហើយ។ ចាប់តាំងពីពេលនោះ បងប្អូនខ្ញុំបានរស់នៅបែកគ្នា។ ខ្ញុំទៅស្នាក់នៅជាមួយយាយ ចំណែកបងប្រុសទៅជាមួយម្តាយចុង។ នៅឆ្នាំ១៩៧៩ ខ្ញុំបានជួបបងប្រុសវិញ

ហើយបងប្រុសរបស់ខ្ញុំបានប្រាប់ខ្ញុំ ថាគាត់ចូលធ្វើជាទាហានហើយ។ តាំងពីពេលនោះមក ខ្ញុំនៅម្នាក់ឯង។ ក្រោយមកខ្ញុំបានរៀបការ និងខ្ញុំមានកូន៦នាក់ ប៉ុន្តែជាអកុសលប្តីរបស់ខ្ញុំបានស្លាប់ចោលទៅ។ ខ្ញុំនៅមើលថែកូនប៉ុន្តែកូនម្នាក់ឈឺធ្ងន់ក៏បានស្លាប់បាត់ទៅ។ ពេលនោះខ្ញុំក្រលំបាកខ្លាំងណាស់ ដោយសារខ្ញុំគឺជាស្ត្រីមេម៉ាយ និងគ្មានសម្ថភាពគ្រប់គ្រាន់ក្នុងការរកចំណូល។ បច្ចុប្បន្នខ្ញុំមានជីវភាពសមរម្យ ព្រោះកូនៗរបស់ខ្ញុំមានគ្រួសារ និងមានការងារធ្វើគ្រប់ៗគ្នា។

## គីម រី

ខ្ញុំឈ្មោះ គីម រី អាយុ៦៤ឆ្នាំ មានស្រុកកំណើតនៅភូមិកោះនរា ឃុំច្បារអំពៅ ស្រុកកៀនស្វាយ ខេត្តកណ្តាល។ បច្ចុប្បន្នខ្ញុំរស់នៅក្នុងភូមិត្រពាំងឈូក ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ និងមានមុខរបរជាកសិករ។ ឪពុករបស់ខ្ញុំឈ្មោះ គីម ស៊ុន (ស្លាប់) និងម្តាយឈ្មោះ ម៉ម ឆុន (ស្លាប់)។ ខ្ញុំមានបងប្អូនបង្កើតចំនួន៥នាក់ ប្រុស១នាក់ និងស្រី៤នាក់។ ខ្ញុំមានប្តីឈ្មោះ កៅ ញឿន បានស្លាប់ដោយសារជំងឺគ្រុនផ្តាសាយ និងទាចទឹក។ សព្វថ្ងៃខ្ញុំមានកូនចំនួន៥នាក់ ប្រុស៣នាក់ និងស្រី២នាក់។



ញិល សារី រស់នៅភូមិអណ្តូងថ្ម ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កាលពីអាយុ១១ឆ្នាំ បានចូលរៀនត្រឹមថ្នាក់ទី១០នៅសាលាវត្តបុស្សស្រី ស្រស់ ដែលស្ថិតនៅសង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។ សម័យនោះខ្ញុំរស់នៅសុខសប្បាយ និងមានវត្តអារាមធ្វើបុណ្យទាន មានសាលារៀន និងមានការប្រារព្ធពិធីបុណ្យភ្ជុំបិណ្ឌយ៉ាងរីករាយជាមួយយាយរបស់ខ្ញុំ។ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ខ្ញុំបានឮតាមវិទ្យុថាមានការធ្វើបាតុកម្មទម្លាក់សម្តេច នរោត្តម សីហនុ។

នៅចុងឆ្នាំ១៩៧៤ ខ្មែរក្រហមបានជម្លៀសក្រុមគ្រួសារ និងឪពុកម្តាយខ្ញុំឲ្យរស់នៅកំពង់សោម។ ខ្ញុំបានប្រកបរបរធ្វើជាកម្មកររោងចក្រស្រាបៀរ។ ខ្ញុំរៀបការនៅកំពង់សោមបានរយៈពេល២ខែមុនពេលរបបខ្មែរក្រហមចូលមក។ ពិធីរៀបការរបស់ខ្ញុំមិនធំដុំទេ និងប្រារព្ធរយៈពេលមួយថ្ងៃប៉ុណ្ណោះ ព្រោះក្នុងភូមិឃុំរបស់ខ្ញុំកំពុងមានការវាយប្រយុទ្ធគ្នាយ៉ាងខ្លាំង។ បន្ទាប់មកពីរៀបការ ខ្មែរក្រហមបានជម្លៀសគ្រួសាររបស់ខ្ញុំ និងឪពុកម្តាយពីក្រុងកំពង់សោម មកវាលរេញ។ ឪពុករបស់ខ្ញុំបានយកជ្រញ់ធ្វើជាកង់ និងស័ង្កសីបាំងធ្វើជាផ្ទះសម្រាប់ដាក់កន្ទេល មុងភួយ ចំណីអាហារ។ ឪពុកម្តាយខ្ញុំបានកាប់ជ្រូកមួយដែលក្រុមគ្រួសារខ្ញុំបានចិញ្ចឹមយកសាច់ប្រឡាក់ដាក់ក្នុងឆ្នាំង។ យើងដេកដាំបាយហូបនៅតាមផ្លូវ។ ខ្ញុំហើមជើងដោយសារ ដើរឆ្ងាយគឺរយៈពេល៨ថ្ងៃទើបមកដល់វាលរេញ។ ខ្មែរក្រហមបានប្រកាសរកអ្នកដែលចេះធ្វើស្រែ គឺខ្មែរក្រហមឲ្យទៅធ្វើស្រែ និងចេះធ្វើជាងឲ្យទៅធ្វើជាង។ បន្ទាប់មកគ្រួសារដែលជម្លៀសទាំងអស់ត្រូវកត់ឈ្មោះយកទៅឲ្យខ្មែរក្រហម។ ខ្មែរក្រហមបានប្រមូលគ្រួសារជម្លៀសទាំងអស់មករស់នៅក្នុងផ្ទះធំមួយ និងបានបែងចែកក្រុមគ្រួសាររបស់ខ្ញុំឲ្យរស់នៅជាមួយគ្រួសារដទៃទៀត។ ខ្មែរក្រហមបានដាក់ឈ្មោះប្រជាជនថ្មីបុអ្នក១៧ ថា ប្រជាជនត្រៀម បុប្រជាជនផ្ញើ។ ខ្ញុំធ្វើការបានមួយឆ្នាំ ទើបខ្មែរក្រហមស៊ើបប្រវត្តិរូបរកអ្នកណាដែលធ្វើទ័ពពីមុន និងបានស្រាវជ្រាវប៉ះចំប្តីរបស់ខ្ញុំ។ ខ្ញុំបានប្រាប់អ្នកស៊ើបនោះថាខ្ញុំ និងប្តីខ្ញុំបានធ្វើការក្នុង

រោងចក្រស្រាបៀរ។ ប្រសិនបើខ្ញុំប្រាប់ថាធ្វើទាហាន និងប៉ូលីសខ្មែរក្រហមនឹងយកទៅសម្លាប់ចោលមិនខាន។ ខ្មែរក្រហមបានចាត់ការងារឲ្យខ្ញុំធ្វើស្រែ ចំណែកប្ដីរបស់ខ្ញុំភ្ជួររាស់ និងឪពុករបស់ខ្ញុំធ្វើជាមេជាង។ ខ្មែរក្រហមបានចែកអង្ករ១កំប៉ុងកន្លះក្នុងមួយគ្រួសារ និងមួយថ្ងៃឲ្យហូបតែមួយពេលតែប៉ុណ្ណោះ។ អ្នកស្គាល់ប្ដីរបស់ខ្ញុំម្នាក់បានធានាឲ្យគ្រួសាររបស់ខ្ញុំត្រឡប់មកស្រុកកំណើតខាងប្ដីវិញ ប៉ុន្តែខ្ញុំត្រូវបែកពីឪពុកម្ដាយរបស់ខ្ញុំ។ ខ្ញុំធ្វើដំណើរ៣យប់៣ថ្ងៃទើបមកដល់ស្រុកកំណើតរបស់ប្ដី។ មុនពេលបែកឪពុករបស់ខ្ញុំបាននិយាយថាកូនអ្ហា! បែកគ្នាម្ដងនេះចាត់ទុកជាព្រាត់ស្លាប់មិនមែនព្រាត់រស់ទេ ហើយមិនដឹងថាយើងបានជួបគ្នាថ្ងៃណាទេ។ ក្រោយមក ខ្ញុំបានឮដំណឹងថា ឪពុកម្ដាយរបស់ខ្ញុំបានស្លាប់អស់ហើយ។ ខ្មែរក្រហមបានឲ្យខ្ញុំធ្វើការចាប់ពីព្រលឹមដល់ម៉ោង១១ និងពេលចូលធ្វើការនៅម៉ោង១ដល់ម៉ោង៧ ឬម៉ោង១១យប់។ កាលនោះខ្ញុំទើបអាយុ១៧ឆ្នាំ។ ខ្ញុំមានកម្លាំងធ្វើការដោយមិនឈឺថ្កាត់ឡើយ។ ខ្ញុំធ្វើការបណ្ដើរងោកបណ្ដើរ។ ដោយអស់កម្លាំងពេកខ្ញុំបានធ្វើពុតឈឺ។ ខ្មែរក្រហមបានសួរខ្ញុំថា ម្សិលមិញមិនឃើញមិត្តឯងមកធ្វើការ? ខ្ញុំឆ្លើយថា ខ្ញុំខ្យល់ណាបង។ ខ្មែរក្រហមបានតបមកវិញថា ខ្យល់ឌីល? ដែលមានន័យថាខ្ញុំខ្ជិល។ ខ្ញុំតបថា អត់ទេខ្ញុំខ្យល់មែនទែន។ ខ្មែរក្រហមសួរទៀតថា ឈឺអ៊ី? ខ្ញុំថាចុកពោះ។

បន្ទាប់ពីខ្ញុំបានមករស់នៅស្រុកកំណើតរបស់ប្ដីនៅដើមឆ្នាំ១៩៧៧ ខ្មែរក្រហមបានបែងចែកជាសហករណ៍ម្ដងទៀត។ ខ្ញុំត្រូវបានខ្មែរក្រហមឲ្យធ្វើស្រែរួមនៅភូមិត្រពាំងត្នោត។ នៅទីនោះមានការប្រជុំនិយាយអំពីការធ្វើការងារ និងលើកយកពាក្យស្លោកមួយឲ្យយើងនិយាយតាម ជ័យោ! បក្សកុម្មុយនីស្តដ៏មហិមាមហាអស្ចារ្យ ហើយប្រធានអង្គប្រជុំឲ្យខ្ញុំក្រោកឈរ និងលើកដៃប្ដេជ្ញា។ ខ្មែរក្រហមឲ្យសម្រាកពេលថ្ងៃត្រង់មួយម៉ោង គឺម៉ោង១១ដល់ម៉ោង១២ ដើម្បីហូបបាយ ហើយចូលវិញនៅវេលាម៉ោង១។ ការហូបចុកមិនបានគ្រប់គ្រាន់ទេគឺខ្ញុំហូបតែបបរ ដោយបែកគ្នាម្នាក់មួយចានៗ។ នៅពេលខាងចុងភៅមានអង្ករ គឺចុងភៅឲ្យបាយហូបឲ្យខ្ញុំដែរ។ ខ្ញុំ និងអ្នកធ្វើការនៅក្នុងកងមានកាតូម្នាក់មួយទៅបើករបប ប៉ុន្តែខ្ញុំមិនហូបទាំងអស់ទេ។ ខ្ញុំបានដាក់ក្នុងកាតូដើម្បីយកមកផ្ទះ។ ខ្ញុំយកត្រកួន និងក្ដាមស្ងោរហូបពីរនាក់ប្ដី។ ប្ដីរបស់ខ្ញុំបានឲ្យដំឡូងប៉ុនកំភួនជើងមកខ្ញុំ ហើយខ្ញុំបានជីកដីកប់ដំឡូងនៅកន្លែងដេករបស់ខ្ញុំ។ ខ្ញុំមិនហ៊ានស្ងោរហូបឲ្យឈ្លបឃើញទេ ហើយក៏មិនហ៊ានស្ងោរនៅពេលយប់ដែរ ព្រោះខ្ញុំឃើញដានជើងមនុស្សនៅជុំវិញរោងរបស់ខ្ញុំ។ ខ្មែរក្រហមពួននៅក្រោមដើមស្វាយមួយ ហើយដើរសសៀរចូលមកក្រោមផ្ទះដើម្បីចាប់យកប្រជាជនពីរគ្រួសារទៅវាយសម្លាប់ចោល។ គ្រួសារមួយមានប្ដីធ្វើជាអាចារ្យវត្ត និងគ្រួសារមួយទៀតមានប្ដីឈ្មោះ មែន ថន បានឈ្លោះប្រកែកគ្នាជាមួយប្រពន្ធ។ ប្រពន្ធបានយកចានបាយវាយក្បាលប្ដី ធ្វើឲ្យកំពប់បាយ។ នៅសម័យនោះ មានប្រធានភូមិខ្លះចិត្តល្អរក្សាប្រជាជនក្នុងភូមិរបស់គាត់ឲ្យមានជីវិត និងមិនបង្ខិតបង្ខំឲ្យធ្វើការ។ ប្រធានភូមិខ្លះចូលចិត្តអាក្រក់ចោទប្រជាជនថាខ្មាំងៗ សូម្បីធ្វើបាក់ស្លាបព្រា។ ខ្ញុំបានឃើញបុរស៣នាក់កំពុងបោកស្រូវយ៉ាងសប្បាយរីករាយ ស្រាប់តែក្រោយមកបាត់ខ្លួនមិនដឹងថាខ្មែរក្រហមយកទៅវាយចោល ឬយ៉ាងណាទេ។

នៅចុងឆ្នាំ១៩៧៨ ខ្មែរក្រហមបានជម្លៀសប្រជាជន និងគ្រួសារខ្ញុំឲ្យធ្វើដំណើរកាត់ព្រៃ កាត់ស្ទឹង ជ្រោះ និងឡើងភ្នំទាំងខ្ញុំមានផ្ទៃពោះ។ ខ្ញុំបានរែកអង្ករឆ្នាំងបាយជាមួយប្ដី។ នៅក្នុងអំឡុងពេលធ្វើដំណើរ ខ្ញុំបានប្រទះឃើញមនុស្សស្លាប់ជាច្រើននៅតាមផ្លូវ។ អ្នកទាំងនោះស្លាប់ដោយសារគ្មានថ្នាំព្យាបាល។ អ្នកបើកឡានម្នាក់បានហៅខ្ញុំឲ្យឡើងជិះឡាន ប៉ុន្តែខ្ញុំមិនហ៊ានជិះ ព្រោះខ្លាចវង្វេងជាមួយក្រុមគ្រួសារ។

បន្ទាប់ពីធ្វើដំណើរអស់រយៈពេល៧ខែ ដោយគ្មានគោលដៅក៏បានជួបទាហានវៀតណាម។ គ្រួសារខ្ញុំធ្វើដំណើរត្រឡប់មកផ្ទះវិញ ដោយដើរ២៧ថ្ងៃប៉ុណ្ណោះ។

ក្រោយឆ្នាំ១៩៧៩ ខ្ញុំឈឺញ័រដៃជើង ត្រជាក់

ចុងដៃចុងជើង និងហើម ដោយសារគ្មានអាហារហូបទេ។ មួយសន្ទុះក្រោយមក ប្ដីខ្ញុំបានយកដំឡូងស្ងោរឆ្អិន៣មើមមកឲ្យខ្ញុំ។ ខ្ញុំក៏ប្រថុយហូបដំឡូងទាំងសរសៃខ្ចី ហើយគិតថាបើស្លាប់ក៏ស្លាប់ទៅចុះ។ នៅព្រឹកឡើង មន្ត្រីឃុំបានចែកអង្ករម្នាក់១៥កំប៉ុងដល់ខ្ញុំ។ ខ្ញុំគិតថាហូបមិនគ្រប់គ្រាន់ក៏យកក្រណាត់២ដុំដូរបានអង្ករ១៥កំប៉ុងថែមទៀត។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំបាត់បង់សមាជិកចំនួន២នាក់គឺឈ្មោះ គឹម ចម្រើន និង គឹម សុខា។ ក្រោយមក ប្ដីរបស់ខ្ញុំបានស្លាប់ ហើយខ្ញុំបានរស់នៅ និងចិញ្ចឹមកូនស្រីអាយុ១១ឆ្នាំ។ មកដល់សព្វថ្ងៃនេះ ខ្ញុំបានចិញ្ចឹមកូនៗរស់ធំធាត់។ ខ្ញុំរស់ជាមួយកូនស្រីច្បង និងប្រកបរបរស្រែចម្ការដោយសេចក្ដីសុខ។

---

## ចាន់ វណ្ណារី

អ្នកគ្រូ ចាន់ វណ្ណារី មានអាយុ ៥៣ឆ្នាំ ខ្ញុំរស់នៅភូមិ ឡូរី សង្កាត់រការក្រៅ ក្រុងដូនកែវ ខេត្តតាកែវ។ វណ្ណារី រៀបរាប់ថា សព្វថ្ងៃខ្ញុំធ្វើជានាយិការរងនៅមជ្ឈមណ្ឌលគរុកោសល្យ ភូមិភាគ ខេត្តតាកែវ។ កាលនៅពីកុមារភាពខ្ញុំរស់នៅក្នុងភូមិឃុំដដែល ប៉ុន្តែចាប់ពីឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសខ្ញុំចេញពីស្រុកកំណើតដែលធ្លាប់រស់នៅឃុំស្រែនោង ស្រុកត្រាំកក់វិញ។ កាលសម័យនោះ ខ្ញុំទើបតែមានអាយុ៧ឆ្នាំប៉ុណ្ណោះ ខ្មែរក្រហមឲ្យខ្ញុំធ្វើការនៅក្នុងកងកុមារ ។ ខ្មែរក្រហមប្រើឲ្យខ្ញុំរើសអាចម៍គោ សែងដី កាត់ដើមកន្ទ្រានខែត្រ ក្រៅពីនោះខ្ញុំធ្វើការជាមួយកងមនុស្សចាស់ និងមនុស្សពេញវ័យដែរ ព្រោះខ្មែរក្រហមចាត់ទុកជាអ្នក១៧មេសា។

នៅទីតាំងដែលខ្ញុំធ្វើការមានបែងចែក កងកុមារ កងយុវជន និង កងផ្សេងៗទៀត។ ដោយសារខ្ញុំគឺជាអ្នក១៧មេសា ទើបខ្មែរក្រហមប្រើឲ្យធ្វើការងារធ្ងន់ធ្ងរជាងប្រជាជនមូលដ្ឋាន។ ពេលខ្ញុំបានឃើញការចាក់ផ្សាយឯកសារខ្មែរក្រហមនៅតាមកញ្ចក់ទូរស្សន៍ ដែលប្រើឲ្យកុមាររែកដីពេញៗបង្គីរ គឺធ្វើឲ្យខ្ញុំនឹកឃើញរឿងដែលខ្ញុំបានជួបផ្ទាល់។ ខ្មែរក្រហម ប្រើខ្ញុំធ្វើការងារគ្មានពេលសម្រាកគ្រប់គ្រាន់ និងក្រោកពេលព្រលឹមធ្វើការដោយគ្មានអាហារហូបរហូតដល់ម៉ោង១១ឬម៉ោង១២ទើបបានហូបបាយ។ ចំណែកសម្លៀកបំពាក់ ខ្មែរក្រហមបានចែកឲ្យខ្ញុំតែមួយកំផ្លេរប៉ុណ្ណោះ។ ពេលខ្ញុំងូតទឹកគឺត្រូវយកខោអាវទៅបោកហើយហាលស្ងួតទើបបានស្លៀកពាក់បន្តទៀត។ ខ្ញុំពិបាកគាំទ្រជាមួយការងារដែលខ្មែរក្រហមបានបញ្ជាឲ្យធ្វើ។ មានថ្ងៃមួយខ្ញុំបានលួចរត់ចេញពីការដ្ឋានដែលខ្ញុំបានធ្វើការ ទាំងយប់ដោយគ្មានការភ័យខ្លាចអ្វីទាំងអស់។ ខ្ញុំគិតក្នុងចិត្តថាទោះបីមានសត្វកាចសាហាវឬក៏ត្រូវខ្មែរក្រហមចាប់បានក៏ខ្ញុំសុខចិត្តរត់ដែរ ព្រោះគិតថាបើរស់នៅការដ្ឋានតទៀតក៏ស្លាប់ ប៉ុន្តែដោយសារគុណបុណ្យទឹកដោះម្ដាយថ្លៃ ខ្ញុំបានរួចពីសេចក្ដីស្លាប់។

ចំពោះរបបអាហារ ខ្ញុំមិនបានទទួលគ្រប់គ្រាន់ឡើយ។ ខ្មែរក្រហមឲ្យហូបតែបបរសជាមួយនឹងសម្លព្រលឹតនិងត្រកួន និងហូបបាយលាយជាមួយនឹងដំឡូង។ ប៉ុន្តែដោយសារ ខ្ញុំមិនចេះហូបនៅសម្លដែលអង្គការបានស្ងោរ ខ្ញុំក៏បានទៅលួចកាត់គល់ស្លឹកគ្រៃយកមកបុកលាយជាមួយនឹងអំបិលហូបជំនួសសម្លជាប្រចាំ។ ប្រសិនបើមាននរណាជ្រុះបាយ ឬម្ហូបក៏ខ្ញុំរើសមកហូបដែរ ដោយសារតែឃ្លាន។ ខ្ញុំគឺជាកុមារដែលធ្លាប់រស់នៅជាមួយឪពុកម្ដាយ និងមានការចិញ្ចឹមបីបាច់មើលថែ មានអាហារហូបឆ្អែតគ្រប់គ្រាន់ មានពេលសម្រាក និងមានការរៀនសូត្រ បែជាមកត្រូវធ្វើការងារធ្ងន់ធ្ងរ។

នៅក្នុងរបបខ្មែរក្រហម ខ្ញុំបានបាត់បង់ឪពុក និងម្ដាយជាទីស្រឡាញ់។ ខ្ញុំនៅចាំហេតុការណ៍ដែលខ្មែរក្រហមយកឪពុករបស់ខ្ញុំទៅសម្លាប់ នៅពេលដែលមានអ្នករាយការណ៍ថា ឪពុករបស់ខ្ញុំជាអ្នកធ្លាប់ធ្វើការជាមេទាហាននៅសម័យ លន់ នល់។ ពេលនោះឪពុករបស់ខ្ញុំបានបន្លំខ្លួនធ្វើជាអ្នករត់ស៊ីក្លូដោយពាក់អាវយឺត និង ស្លៀកកន្ទែង ហើយរែកអំរែកដែរ ប៉ុន្តែខ្មែរក្រហមបានដឹងនិងបានយកគាត់ទៅសម្លាប់។

ខ្ញុំឈឺចាប់យ៉ាងខ្លាំង ពេលដែលឃើញយោធា ប៉ុលពត ចងស្លាបសេកឪពុករបស់ខ្ញុំហើយបណ្តើរចេញទៅ។ ខ្ញុំមិនអាចជួយឪពុករបស់ខ្ញុំបានទេ ទោះបីដឹងថាខ្មែរក្រហមយកគាត់ទៅសម្លាប់ក៏ដោយ។

ខ្ញុំបាត់បង់ឪពុកជាទីស្រឡាញ់។ នៅក្នុងឆ្នាំ១៩៧៥ ដដែល ម្តាយរបស់ខ្ញុំសម្រាលកូនមួយទៀត បន្ទាប់មកម្តាយបានធ្លាក់ខ្លួនឈឺធ្ងន់ហើយបានស្លាប់ ដោយបន្សល់ទុកប្អូនប្រុសរបស់ខ្ញុំនិងខ្ញុំជាក្មេងកំព្រា។ ក្រោយម្តាយស្លាប់ទៅ ខ្ញុំត្រូវមើលប្អូនតូចផង និងត្រូវធ្វើការផង។ ខ្មែរក្រហមប្រើខ្ញុំធ្វើការគ្រប់បែបយ៉ាង។ ក្រោយពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ ខ្ញុំបានមករស់នៅជាមួយសាច់ញាតិវិញនៅក្នុងភូមិឡូរី សង្កាត់រការក្រៅ ក្រុងដូនកែវ ខេត្តតាកែវ។



អ្នកគ្រូ ចាន់ វណ្ណរី មានអាយុ ៥៣ឆ្នាំ ខ្ញុំរស់នៅភូមិ ឡូរី សង្កាត់រការក្រៅ ក្រុងដូនកែវ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




អ្នកស្ម័គ្រចិត្តកម្ពុជាខេត្តតាកែវ ជួបសម្ភាសន៍ជាមួយចាស់ទុំដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហមនៅតាមតំបន់ជនបទដាច់ស្រយាលក្នុងខេត្តតាកែវ។ (អ្នកស្ម័គ្រចិត្តកម្ពុជាខេត្តតាកែវ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# អ្នកស្ម័គ្រចិត្តកម្ពុជានាំយកកញ្ចប់អនុស្សាវរីយ៍ ១៧០ប្រអប់ ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅខេត្តស្វាយរៀង

*សុខ ចន្ទ្រា*





អ្នកស្ម័គ្រចិត្តកម្ពុជាខេត្តស្វាយរៀង កំពុងរៀបចំប្រអប់អនុស្សាវរីយ៍ យកទៅចែកជូនចែកជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅតាមមូលដ្ឋានដែលខ្លួនកំពុងរស់នៅ។ (អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តស្វាយរៀង/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅវេលាម៉ោង ២:០០ រសៀល ថ្ងៃពុធ ទី៨ ខែធ្នូ ឆ្នាំ២០២១ ក្រុមអ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តស្វាយរៀង ចំនួន១៤ នាក់ មកប្រជុំជាមួយលោក សោម ប៊ុនថន ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ស្ថិតនៅក្នុងភូមិព្រៃបាសាក់ ឃុំព្រៃបាសាក់ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។ ក្នុងឱកាសនោះ ក្រុមអ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តស្វាយរៀងបាននាំកម្រងសំណួរស្ទាបស្ទង់មតិទាក់ទងនឹងគម្រោងលើកកម្ពស់សិទ្ធ និងធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលខ្លួនបានបំពេញរួច និងបានពិភាក្សាលើបញ្ហាដែលខ្លួនបានចុះទៅសម្ភាសន៍ឪពុក, ម្ដាយ, យាយ, តា អ៊ំ, ពូ, មីង នៅក្នុងភូមិឃុំនាពេលកន្លងមក ព្រមទាំងចែករំលែកចំណេះដឹងទាក់ទងនឹងការងារក្នុងគម្រោង និងការពង្រឹងគុណភាពការងារ។ ក្នុងឱកាសនេះ សោម ប៊ុនថន បានផ្ដល់ជា ថង់យាម, អាវយឺត, កញ្ចប់អនុស្សាវរីយ៍ ចំនួន១៧០ ប្រអប់ ដែលរួមមាន ១) ព្រឹត្តិបត្រព័ត៌មានណែនាំអំពីសុខភាព, ២) ដែល, ៣) សាប៊ូលាងដៃ, ៤) ម៉ាស់, ៥) នំ, ៦) សៀវភៅណែនាំគ្រូបង្រៀនទាក់ទងនឹងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩), ៧) ឧបករណ៍សង្គ្រោះបឋម, ៨) សេវាកម្មពិនិត្យសុខភាពនៅតាមមន្ទីរពេទ្យឯកជនក្នុងសហគមន៍ដោយឥតគិតថ្លៃ, និង ៩) សម្ភារជំនួយដល់ជនពិការសម្រាប់ចែកជូនអ្នករស់







រានមានជីវិតពីរបបខ្មែរក្រហម ព្រមទាំងប្រាក់ឧបត្ថម្ភសម្រាប់ការធ្វើដំណើរជូនដល់អ្នកស្ម័គ្រចិត្តកម្ពុជាចំនួន ៣២ នាក់ ក្នុងខេត្តស្វាយរៀង។







*អ្នកស្ម័គ្រចិត្តកម្ពុជាខេត្តស្វាយរៀង កំពុងរៀបចំប្រអប់អនុស្សាវរីយ៍យកទៅចែកជូនចែកជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅតាមមូលដ្ឋានដែលខ្លួនកំពុងរស់នៅ។ (អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តស្វាយរៀង/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅចុងបញ្ចប់កម្មវិធីប្រជុំ សោម ប៊ុនថន ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា សម្តែងការអរគុណដល់ក្រុមអ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តស្វាយរៀង ដែលបានខិតខំប្រឹងប្រែងជួយដល់ចាស់ទុំនៅតាមមូលដ្ឋានដែលខ្លួនកំពុងរស់នៅ។













# ការិយាល័យ
# ព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន និស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្ងាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្តា អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៦៦៣ ៦១១ ឬ អ៊ីម៉ែល៖

truthchenda.s@dccam.org

សូមអរគុណ!















# សាលក្រមសំណុំរឿង០០២/០២

## ដកស្រង់ចេញពីឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈរបស់សាលាក្តីខ្មែរក្រហម

**ដារ៉ាវឌ្ឍ មេត្តា**

(តពីលេខមុន)

**៧១១.** ការប្រព្រឹត្តជាមូលដ្ឋាននៃការធ្វើទុក្ខបុកម្នេញដែលត្រូវបានចោទប្រកាន់ សំដៅដល់ការប្រព្រឹត្តជាច្រើនដូចបានកំណត់នៅក្នុងទីតាំងឧក្រិដ្ឋកម្មនានាដែលបានពិភាក្សានៅក្នុងសាលក្រមនេះពាក់ព័ន្ធនឹងការធ្វើទុក្ខបុកម្នេញ។ ក្នុងករណីដែលការប្រព្រឹត្តបែបនោះសំដៅទៅដល់ការប្រហារជីវិត ការសម្លាប់ ការដាក់ក្នុងមន្ទីរឃុំឃាំង ឬជម្លៀសប្រជាជនដោយបង្ខំនោះ អង្គជំនុំជម្រះនឹងពិចារណាទៅលើនិយមន័យនៃការធ្វើមនុស្សឃាត ការដាក់ក្នុងមន្ទីរឃុំឃាំង ការនិរទេស និងអំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការជម្លៀសដោយបង្ខំដែលបានកំណត់នៅក្នុងសាលក្រមនេះ។

**៧១២.** ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ និងសាសនា ត្រូវបានចាត់ទុកថាជាផ្នែកមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនាឆ្នាំ១៩៧៥។ នៅក្នុងសំណុំរឿង ០០១ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងនេះត្រូវបានគាំទ្រដោយអង្គជំនុំជម្រះតុលាការកំពូល ហើយរហូតមកដល់ពេលនេះមិនមានភាគីណាមួយជំទាស់ទៅលើការយល់ឃើញពាក់ព័ន្ធនិងសំអាងច្បាប់នោះទេ។ ចំពោះភាពប្រមើលឃើញជាមុនថាជាបទល្មើស និងភាពអាចដឹងថាមានច្បាប់ចែងថាការធ្វើទុក្ខបុកម្នេញ គឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អង្គជំនុំជម្រះពិចារណាទៅលើក្របខណ្ឌនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និងតួនាទីរបស់ជនជាប់ចោទក្នុងនាមជាសមាជិកនៃអាជ្ញាធរគ្រប់គ្រងប្រទេសកម្ពុជា។ បន្ទាប់ពីបានថ្លឹងថ្លែងលើកត្តាទាំងនេះដោយមិនលម្អៀង អង្គជំនុំជម្រះសន្និដ្ឋានថា ជនជាប់ចោទអាចប្រមើលឃើញ និងដឹងជាទូទៅថា ការធ្វើទុក្ខបុកម្នេញអាចត្រូវបានផ្តន្ទាទោសជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រឹមឆ្នាំ១៩៧៥។

**៧១៣. ការធ្វើទុក្ខបុកម្នេញត្រូវបានកំណត់និយមន័យដូចខាងក្រោម៖**

(១) អំពើសកម្មឬអសកម្មដែល[...] ពិតជារើសអើង ហើយដកហូតឬរំលោភទៅលើសិទ្ធិជាមូលដ្ឋានដែលមានចែងក្នុងសន្ធិសញ្ញាអន្តរជាតិ ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិ(ធាតុផ្សំសត្យានុម័ត) និង

(២) ការប្រព្រឹត្តអំពើដោយសកម្មឬដោយអកម្មដោយចេតនារើសអើង ដោយមូលហេតុនយោបាយ ពូជសាសន៍ឬសាសនា (ធាតុផ្សំអត្តនោម័តិ)។

អង្គជំនុំជម្រះតុលាការកំពូលក៏បានគាំទ្រនិយមន័យនេះ ចំណែកឯភាគីនានានៅក្នុងសំណុំរឿងនេះមិនបានជំទាស់ទៅនឹងនិយមន័យនេះ នោះឡើយ។

**៧១៤.** ពាក់ព័ន្ធធាតុផ្សំសត្យានុម័តនៃការរើសអើង អង្គជំនុំជម្រះយល់ឃើញថា « ការរើសអើងជាក់ស្តែង» កើតមានឡើងនៅពេលដែលជនរងគ្រោះត្រូវបានកំណត់ជាគោលដៅ ដោយសារតែពួកគេគឺជាសមាជិកនៅក្នុងក្រុមណាមួយដែលចារីបានកំណត់ដោយផ្អែកលើមូលហេតុជាក់លាក់នានា ដូចជា មូលហេតុនយោបាយ ពូជសាសន៍ឬសាសនា។ ជាក់ស្តែងជនរងគ្រោះត្រូវតែ



កងកុមារកំពុងជីកដីនៅវាលស្រែក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ស្ថិតក្នុងក្រុមនយោបាយ ពូជសាសន៍ឬ សាសនាណាមួយជាក់លាក់ ហើយក្រុមមនុស្សនោះត្រូវតែរងផលប៉ះពាល់ដែលបណ្តាលមកពីការធ្វើទុក្ខបុកម្នេញ។ ក្រុមគោលដៅនៃការធ្វើទុក្ខបុកម្នេញត្រូវតែស្តែងចេញឲ្យឃើញច្បាស់ទោះបីជាយ៉ាងណាចារីគឺជាអ្នកកំណត់ក្រុមគោលដៅ។ អង្គជំនុំជម្រះតុលាការកំពូលបានគាំទ្រចំពោះនិយមន័យនេះ ហើយមិនមានភាគីណាមួយនៅក្នុងរឿងក្តីនេះជំទាស់ទៅនឹងនិយមន័យនេះនោះឡើយ។

**៧១៥.** នាពេលនេះ អង្គជំនុំជម្រះងាកមកពិភាក្សាទាក់ទងនឹងធាតុផ្សំអត្តនោម័តិដែលជាធាតុផ្សំតម្រូវចាំបាច់។ ឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញតម្រូវឲ្យជនជាប់ចោទមានចេតនាជាក់លាក់នៅក្នុងការរើសអើងផ្អែកលើមូលហេតុនយោបាយ ពូជសាសន៍ឬសាសនា។ ដូចពិពណ៌នាលម្អិតខាងក្រោមនេះ លើកលែងតែករណីពាក់ព័ន្ធនិងការជួយ និងជំរុញ និងការទទួលខុសត្រូវរបស់ថ្នាក់លើប៉ុណ្ណោះ ដើម្បីកំណត់ការទទួលខុសត្រូវចំពោះការធ្វើទុក្ខមុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនិងមនុស្សជាតិវាមានសារសំខាន់ក្នុងការបង្ហាញថាជនជាប់ចោទមានចេតនាជាក់លាក់ៗ ជាទូទៅ បើទោះបីជាចេតនាជាក់លាក់មិនអាចទាញចេញដោយផ្ទាល់ពីលក្ខណៈនៃការរើសអើងជាទូទៅនៃការវាយប្រហារនោះក៏ដោយ ប៉ុន្តែវាអាចទាញចេញតាមរយៈបរិបទបាន ប្រសិនបើ ការពិចារណាទៅលើអង្គហេតុនៃរឿងក្តី កាលៈទេសៈជុំវិញការប្រព្រឹត្តបទល្មើសដែលអាចយកមកពិចារណា រួមមានលក្ខណៈជាប្រព័ន្ធនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តទៅលើក្រុមមួយ និងចរិតលក្ខណៈទូទៅនៃចារីដែលត្រូវបានចោទប្រកាន់ដែលស្តែងឡើងតាមរយៈអាកប្បកិរិយារបស់ចារីនោះ។ ដើម្បីបង្ហាញពីចេតនា

នៃការរើសអើង អាកប្បកិរិយារបស់ចារី នៅមុនពេល និងក្រោយពេលដែលអំពើនោះបានកើតឡើងភ្លាមៗ គប្បីត្រូវបានយកមកពិចារណា ដោយសារវាអាចបង្ហាញឲ្យឃើញពីស្ថានភាពផ្លូវចិត្តរបស់ចារី នៅក្នុងអំឡុងពេលនៃអង្គហេតុដែលបានកើតឡើង។

**៧១៦.** អំពើជាក់លាក់ដែលនាំឲ្យមានការធ្វើទុក្ខបុកម្នេញ ត្រូវតែធ្វើការចោទប្រកាន់ឲ្យបានច្បាស់លាស់។ អំពើនៃការធ្វើទុក្ខបុកម្នេញអាចមានរួមបញ្ចូល ទាំងបទល្មើសជាក់លាក់ដទៃទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ដូចជា ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង និងការធ្វើទារុណកម្ម) ក៏ដូចជាអំពើផ្សេងទៀតដែលមានកម្រិតស្ថានទម្ងន់ឬភាពធ្ងន់ធ្ងរស្មើគ្នារួមបញ្ចូល ទាំងអំពើនានាដែលមិនត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះផងដែរ។ ក្នុងការសម្រេចថាតើ លក្ខខណ្ឌតម្រូវនេះត្រូវបានបំពេញហើយឬយ៉ាងណានោះ អំពើទាំងនោះមិនគួរត្រូវបានពិចារណាដោយឯកឯងនោះឡើយ ពោលគឺវាគប្បីត្រូវបានពិនិត្យពិចារណានៅក្នុងបរិបទព្រមជាមួយនឹងផលប៉ះពាល់នានាដែលបានកើតឡើងដោយអំពើទាំងនោះ។ ជាញឹកញាប់ ទោះបីជាការធ្វើទុក្ខបុកម្នេញរួមមាន អំពើដែលបានប្រព្រឹត្តឡើងជាបន្តបន្ទាប់ ប៉ុន្តែអំពើសកម្មឬអំពើអសកម្មតែមួយដែលមានសភាពធ្ងន់ធ្ងរ ឬធ្ងន់ធ្ងរខ្លាំង ក៏អាចគ្រប់គ្រាន់ជាការធ្វើទុក្ខបុកម្នេញផងដែរ ប្រសិនបើអំពើនោះបណ្ដាលឲ្យមានការបំពានយ៉ាងធ្ងន់ធ្ងន់ដល់សិទ្ធិមនុស្សជាមូលដ្ឋានដែលមានចែងនៅក្នុងសន្ធិសញ្ញា ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

**៧១៧.** មេធាវីការពារក្តី ខៀវ សំផន លើកឡើងថា ប្រសិនបើ«ក្រុមគោលដៅ» មិនត្រូវបានកំណត់ច្បាស់លាស់ទេនោះ ឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញមិនមានអត្ថិភាពនោះទេ។ ទាក់ទិនបញ្ហានេះ មេធាវីការពារក្តីបានលើកឡើងថា ដីកាដំណោះស្រាយបានកំណត់យ៉ាងច្បាស់នូវក្រុមគោលដៅបីតែប៉ុណ្ណោះ រួមមាន៖ អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ «ប្រជាជនថ្មី» និងប្រជាជនខ្មែរដែលបានត្រឡប់មកពីបរទេស។ មេធាវីការពារក្តីអះអាងថា ការលើកឡើងនៅក្នុងដីកាដំណោះស្រាយដែលថា «ខ្លាំងប្រភេទនេះកាន់តែមានច្រើនឡើងៗ» មានភាពស្រពិចស្រពិលខ្លាំង។ មេធាវីការពារក្តីបានរិះគន់ទៀតថា នៅក្នុងដីកាដំណោះស្រាយក្នុងគោលដៅ ត្រូវបានកំណត់សំដៅលើបុគ្គលទាំងឡាយណាដែលមិនយល់ស្របនឹងមនោគមន៍វិជ្ជារបស់ ប.ក.ក. ដែលបង្កើតបានជាលក្ខខណ្ឌមួយដែលថា ជនរងគ្រោះនៃការធ្វើទុក្ខបុកម្នេញមិនមែនស្ថិតនៅក្នុងសមាជិកក្រុមណាមួយជាក់លាក់នោះទេ ហើយក្រុមនោះមិនត្រូវបានកំណត់ដោយអាជ្ញធររបស់ ប.ក.ក. នោះឡើយ។

**៧១៨.** អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយអាចត្រូវប្រព្រឹត្តឡើងប្រឆាំងនឹងក្រុមមនុស្ស ដែលរួមទាំងក្រុមដែលមិនមែនជាសមាជិកនៃក្រុមនយោបាយណាមួយ ឬក្រុមដែលមិនប្រកាន់ទស្សនៈនយោបាយផងដែរ។ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ អាចសំដៅទៅលើក្រុមបញ្ចូលក្រុមមនុស្សផ្សេងៗ រួមទាំងអ្នកដែលត្រូវបានសន្មតថាជាអ្នកប្រឆាំងនយោបាយ ឬខុបសគ្គរារាំងដល់ការអនុវត្តកម្មវិធីនយោបាយរបស់ចារី។ អាស្រ័យហេតុនេះ ការជំទាស់គោលការណ៍របស់មេធាវី ការពារក្តី ខៀវ សំផន ទៅលើ ការកំណត់និយមន័យក្រុមមនុស្សថា «ជាអ្នកប្រឆាំងនឹងមនោគមន៍វិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជានោះ» ត្រូវបានអង្គជំនុំជម្រះច្រានចោល។ ការលើកឡើងរបស់មេធាវី ការពារក្តី ខៀវ សំផនដែលថាក្រុមគោលដៅដែលត្រូវបានចោទប្រកាន់ថា បានកំណត់ដោយចារី នៅក្នុងដីកាដំណោះស្រាយ ត្រូវបានកម្រិតតែអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ «ប្រជាជនថ្មី» និងប្រជាជនខ្មែរដែលបានត្រឡប់មកពីបរទេសនោះ នឹងត្រូវយកទៅវិភាគនិងធ្វើការវាយតម្លៃនៅក្នុងសំអាងច្បាប់ ក្នុងផ្នែកដែលពាក់ព័ន្ធស្តីពីការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។

**៧១៩.** មេធាវីការពារក្តី នួន ជា លើកឡើងនូវការអះ

អាជមួយចំនួនពាក់ព័ន្ធនឹងការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា។ ទីមួយ មេធាវីការពារក្តីបានលើកឡើងថា នៅក្នុងក្របខណ្ឌច្បាប់សិទ្ធិមនុស្សអន្តរជាតិ សេរីភាព សាសនានិងសេរីភាពសម្តែងការគោរពសាសនាត្រូវបានបែងចែកដាច់ពីគ្នា។ ចាប់ពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ សេរីភាពសាសនាមិនត្រូវបានហាមឃាត់ឡើយយ៉ាងណាមិញ ការអនុវត្តរបស់រដ្ឋ ឬ ការបង្ហាញឆន្ទៈទទួលយកជាច្បាប់ (Opinio juris) មិនបានគាំទ្រថា សិទ្ធិរបស់បុគ្គលការស្តែងការគោរពសាសនា គឺជាសិទ្ធិដាច់ខាតនោះឡើយ។ មេធាវីការពារក្តី នួន ជា ក៏បានលើកឡើងផងដែរថា ពិធីបុណ្យបែបសាសនា អគារជាទីកន្លែងគោរពបូជាឬការដាក់តាំងនិមិត្តរូបរបស់សាសនា គឺជាផ្នែកមួយនៃសេរីភាពនៃការសម្តែងការគោរពសាសនាមួយចំនួនត្រូវបានអនុវត្តនៅក្នុងច្បាប់អន្តរជាតិ ផ្អែកលើមូលហេតុនៃបញ្ហាសណ្តាប់ធ្នាប់និងសន្តិសុខសាធារណៈ ហើយថាការធ្វើបដិប្បញ្ញត្តិនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានភាពសមស្រប ព្រោះកម្ពុជាប្រជាធិបតេយ្យកំពុងស្ថិតនៅក្នុងស្ថានភាពអាសន្ន។ មេធាវីការពារក្តីលើកឡើងថា ហេតុដូច្នេះជនជាប់ចោទ នួន ជា មិនអាចត្រូវបានសន្និដ្ឋានទោសចំពោះការកំហិតលើសេរីភាពសាសនាដែលអាចត្រូវបានអនុញ្ញាតនោះឡើយ។ ភាគីផ្សេងទៀតមិនបានដាក់សារណាពាក់ព័ន្ធនឹងបញ្ហានេះនោះទេ។

**៧២០.** អង្គជំនុំជម្រះយល់ឃើញថា សេរីភាពក្នុងការគិតសម្បជញ្ញៈ និងសាសនា ត្រូវបានទទួលស្គាល់ជាលក្ខណៈអន្តរជាតិ គឺជាសិទ្ធិជាមូលដ្ឋាន។ សិទ្ធិនេះត្រូវ «រាប់បញ្ចូលទាំងសេរីភាពក្នុងការកាន់ឬគោរពសាសនា ឬជំនឿណាមួយ តាមការជ្រើសរើសរបស់ខ្លួននិងសេរីភាពក្នុងការសម្តែងការគោរពសាសនា ឬជំនឿរបស់ខ្លួនដោយម្នាក់ឯង។ ឬដោយរួមជាមួយអ្នកដទៃនិងជាសាធារណៈ ឬជាឯកជនតាមការគោរពបូជា ការប្រតិបត្តិតាម ការអនុវត្ត និងការបង្ហាត់បង្រៀន។ អង្គជំនុំជម្រះយល់ស្របជាមួយមេធាវីការពារក្តី នួន ជា ដែលថា សេរីភាពសម្តែងពីការគោរពសាសនា ឬ ជំនឿរបស់ខ្លួនអាចត្រូវបានដាក់កំហិតមួយចំនួន។ ប៉ុន្តែការកំហិតទាំងនោះត្រូវតែកំណត់ដោយបញ្ញត្តិច្បាប់ និងមានសារសំខាន់ដល់ការការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុខភាព សីលធម៌ ឬសិទ្ធិនិងសេរីភាពជាមូលដ្ឋានរបស់បុគ្គលផ្សេងទៀត។

**៧២១.** អង្គជំនុំជម្រះកត់សម្គាល់ថា នៅក្នុងអំឡុងពេលនៃឧក្រិដ្ឋកម្មត្រូវបានចោទប្រកាន់រដ្ឋធម្មនុញ្ញនៃកម្ពុជាប្រជាធិបតេយ្យបានចែងថា ប្រជាជនកម្ពុជាគ្រប់រូបមានសិទ្ធិជឿជំនឿឬសាសនាណាក៏បាន ហើយក៏មានសិទ្ធិមិនមានជំនឿអ្វីឬក៏មិនជឿសាសនាណាក៏បាន។ រដ្ឋធម្មនុញ្ញបានចែងបន្ថែមទៀតថា « មិនអនុញ្ញាតឲ្យមានសាសនាប្រតិកិរិយាដែលបំផ្លិចបំផ្លាញកម្ពុជាប្រជាធិបតេយ្យនិងប្រជាជនកម្ពុជាដាច់ខាត»។ អង្គជំនុំជម្រះនឹងធ្វើការវាយតម្លៃទៅលើការដាក់កំហិតណាមួយលើសេរីភាពសាសនា ឬសេរីភាពក្នុងការសម្តែងការគោរពសាសនាផ្អែកលើអង្គហេតុ ក្នុងសំណុំរឿងនេះ ជាមួយនឹងការពិចារណាទៅលើបទប្បញ្ញត្តិទាំងនេះ និងច្បាប់អន្តរជាតិ ចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដើម្បីកំណត់ថាតើការដាក់កំហិតទាំងនេះត្រូវបានច្បាប់អនុញ្ញាត ឬជាការរំលោភបំពានលើសិទ្ធិជាមូលដ្ឋាននៃសេរីភាពសាសនា ដែលត្រូវបានចាត់ទុកថាជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនាដែរឬទេ។

### ៩.១.៨. អំពើអមនុស្សធម៌ផ្សេងៗទៀត

**៧២២.** ទាក់ទិនសំណុំរឿង ០០២/០២ ដីកាដំណោះស្រាយចោទប្រកាន់ជនជាប់ចោទពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ និងអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការរំលោភផ្លូវភេទ ការជម្លៀសដោយបង្ខំនិងការបាត់ខ្លួនដោយបង្ខំ។

**៧២៣.** «អំពើអមនុស្សធម៌ផ្សេងៗទៀត» ត្រូវបានទទួលស្គាល់ជាប្រភេទបទល្មើសមិនជាក់លាក់នៅក្នុងក្របខណ្ឌឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាម

ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រឹមឆ្នាំ១៩៧៥។ ពាក់ព័ន្ធនឹងភាពអាចប្រមើលមើលឃើញជាមុនថា ជាបទល្មើស និងភាពអាចបានដឹងថាមានច្បាប់ចែងអំពី «អំពើអមនុស្សធម៌ផ្សេងៗទៀត» ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អង្គជំនុំជម្រះពិចារណាទៅលើក្របខណ្ឌនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ និងតួនាទីរបស់ជនជាប់ចោទក្នុងនាមជាសមាជិកនៃអាជ្ញាធរគ្រប់គ្រងប្រទេសកម្ពុជា។ បន្ទាប់ពីបានថ្លឹងថ្លែងមើលទៅលើកត្តាទាំងនោះដោយសត្យានុម័តរួចមក អង្គជំនុំជម្រះសន្និដ្ឋានថា ជនជាប់ចោទអាចមើលឃើញនិងដឹងជាទូទៅថា«អំពើអមនុស្សធម៌ផ្សេងទៀត» អាចត្រូវបានផ្តន្ទាទោសជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិគិតត្រឹមឆ្នាំ១៩៧៥។

**៧២៤.** «អំពើអមនុស្សធម៌ផ្សេងទៀត» បំពេញមុខងារជាប្រភេទបទល្មើសនៅសេសសល់ដែលត្រូវផ្តន្ទាទោសព្រហ្មទណ្ឌចំពោះអំពើ ដែលបំពេញលក្ខខណ្ឌតម្រូវនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ប៉ុន្តែមិនបំពេញលក្ខខណ្ឌនៃបទល្មើសណាមួយក្នុងចំណោមបទល្មើសជាក់លាក់ផ្សេងទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះឡើយ។ ធាតុផ្សំសត្យានុម័តនៃ« អំពើអមនុស្សធម៌ផ្សេងទៀត» ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតម្រូវឲ្យមានអំពើសកម្មឬអសកម្មដែលបង្កឲ្យមានការឈឺចាប់ផ្លូវចិត្តឬផ្លូវកាយ របួសស្នាម ឬបណ្តាលឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស។ ធាតុផ្សំអត្តនោម័តនៃ« អំពើអមនុស្សធម៌ផ្សេងទៀត» ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតម្រូវថា អំពើសកម្ម ឬអសកម្មត្រូវបានប្រព្រឹត្តដោយចេតនា។

**៧២៥.** ការប្រព្រឹត្តជាមូលដ្ឋានជាក់លាក់នៃ «អំពើអមនុស្សធម៌ផ្សេងៗទៀត» មិនចាំបាច់ត្រូវបានកំណត់ថា ជាបទល្មើសជាក់លាក់ដែលត្រូវផ្តន្ទាទោសក្រោមច្បាប់អន្តរជាតិនោះឡើយ។ ដើម្បីក្លាយជា «អំពើអមនុស្សធម៌ផ្សេងទៀត» អំពើសកម្មឬអកម្មត្រូវមានលក្ខណៈ និងសភាពធ្ងន់ធ្ងរប្រហាក់ប្រហែលនឹងបទល្មើសជាក់លាក់ផ្សេងទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលច្បាប់បានចែង។ ចំណុចនេះតម្រូវឲ្យមានការវិភាគទៅតាមករណីជាក់ស្តែងនីមួយៗអំពីផលប៉ះពាល់នៃការប្រព្រឹត្តទៅលើជនរងគ្រោះ និងថាតើការប្រព្រឹត្តនេះអាចប្រហាក់ប្រហែលគ្នានឹងបទល្មើសជាក់លាក់ផ្សេងទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលច្បាប់បានចែងដែរឬយ៉ាងណា។ ការវាយតម្លៃបែបនេះអាចពិចារណាទៅលើលក្ខណៈនៃអំពើសកម្មឬអកម្មនោះក៏ដោយ។

**៧២៦.** អង្គជំនុំជម្រះកត់សម្គាល់ថា អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា ការវាយតម្លៃថា តើការប្រព្រឹត្តនោះរំលោភបំពានទៅលើ «សិទ្ធិជាសារវ័ន្តរបស់មនុស្សជាតិ ដូចបានបញ្ជាក់នៅក្នុងលិខិតតុបករណ៍ច្បាប់អន្តរជាតិនោះ» ឬយ៉ាងណា គឺជាវិធីមួយនៃការបង្ហាញ «លក្ខខណ្ឌត្រូវនៃអនិត្យាកូលភាពផ្លូវការជាអន្តរជាតិ»។ តាមការយល់ឃើញរបស់អង្គជំនុំជម្រះតុលាការកំពូល ចំណុចនេះជួយដល់ការវាយតម្លៃ ទាំងទៅលើលក្ខខណ្ឌនៃភាពអាចប្រមើលឃើញ និងថាតើការប្រព្រឹត្តនោះឈានដល់កម្រិតធ្ងន់ធ្ងរនៃបទល្មើសផ្សេងទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែរឬយ៉ាងណា។

**៧២៧.** អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ដីកាដំណោះស្រាយកំណត់ថាករណីនៃការរំលោភផ្លូវភេទការប៉ះពាល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ គឺជាការប្រព្រឹត្តជាមូលដ្ឋាននៃ« អំពើអមនុស្សធម៌ផ្សេងទៀត» ដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង០០២/០២។ ប្រភេទនៃការប្រព្រឹត្តទាំងនេះមិនត្រូវបានកំណត់ថា ជាបទល្មើសដោយឡែកនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេ គិតត្រឹមឆ្នាំ១៩៧៥ ហើយនៅក្នុងសំណុំរឿងនេះ ការប្រព្រឹត្តទាំងនេះក៏មិនត្រូវបានចោទប្រកាន់ថាជាបទល្មើសដាច់ដោយឡែកនោះដែរ។ ហេតុដូច្នេះ អង្គជំនុំជម្រះត្រូវវាយតម្លៃលើការប្រព្រឹត្តទាំងនេះជាមួយនឹងនិយមន័យនៃ «អំពើអមនុស្សធម៌ផ្សេងទៀត»។ នៅក្នុងការវាយតម្លៃបែបនេះ ភារកិច្ចរបស់អង្គជំនុំជម្រះត្រូវបានជួយសម្រួល

ដោយការកំណត់អំពីធាតុផ្សំសំខាន់ៗ នៃការប្រព្រឹត្ត ទាំងនេះ នៅក្នុងករណីចាំបាច់ ដើម្បីធានាដល់ការវិភាគសមស្រប។

## ៩.១.៨.១. ការរំលោភផ្លូវភេទ

**៧២៨.** *ជាបញ្ហាបឋម មេធាវីការពារក្តី ខៀវ សំផន លើកឡើងថា នៅក្នុងអំឡុងពេលពាក់ព័ន្ធការរំលោភផ្លូវភេទមិនស្ថិតក្នុងប្រភេទនៃ « អំពើអមនុស្សធម៌ផ្សេងៗទៀត» នោះទេ។ ភាគីផ្សេងទៀតមិនបានដាក់សារណាពាក់ព័ន្ធនឹងចំណុចនេះទេ។ អង្គជំនុំជម្រះយល់ឃើញថាអំណះអំណាងនោះមានការយល់ច្រឡំចំពោះលក្ខណៈនៃបទល្មើស។ អង្គជំនុំជម្រះសង្កត់ធ្ងន់ថា ពុំមានបញ្ជីកំហិតអំពីប្រភេទជាក់លាក់នៃការប្រព្រឹត្តជាមូលដ្ឋានដែលស្ថិតក្នុងប្រភេទនៃ«អំពើអមនុស្សធម៌ផ្សេងទៀត» នោះឡើយ។ ផ្ទុយទៅវិញ បទល្មើសនេះសំដៅដល់ការប្រព្រឹត្តជាច្រើនដែលមិនមែនជាបទល្មើសជាក់លាក់ផ្សេងទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលច្បាប់បានចែងដរាបណាធាតុផ្សំទូទៅសម្រាប់ឧក្រិដ្ឋនឹងប្រឆាំងមនុស្សជាតិត្រូវបានបំពេញ ហើយការប្រព្រឹត្តនោះមានកម្រិតធ្ងន់ធ្ងរស្មើនឹងបទល្មើសផ្សេងទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ វាជាបទល្មើសនៃ «អំពើអមនុស្សធម៌ផ្សេងទៀត» ដែលតម្រូវឲ្យមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងអំឡុងពេលពាក់ព័ន្ធ ដែលនេះជាការវាយតម្លៃដែលអង្គជំនុំជម្រះបានធ្វើខាងលើ។ មិនមានលក្ខខណ្ឌតម្រូវដែលថា ការរំលោភផ្លូវភេទ គឺជាប្រភេទជាក់លាក់នៃការប្រព្រឹត្តជាមូលដ្ឋានដែលត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថា ស្ថិតក្នុងបទឧក្រិដ្ឋប្រភេទនេះត្រឹមឆ្នាំ១៩៧៥ នោះទេ។ ហេតុនេះអង្គជំនុំជម្រះច្រានចោលសេចក្តីសន្និដ្ឋាននេះ។*

**៧២៩.** *ពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ ដីកាដំណោះស្រាយចោទប្រកាន់ជនជាប់ចោទពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការរំលោភភេទនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ជាពិសេសដីកានេះចោទប្រកាន់ថា «ដោយតម្រូវឲ្យរួមដំណេកក្រោយការរៀបអាពាហ៍*

**(តនៅលេខក្រោយ)**



*កងនារី កំពុងលើកភ្លឺស្រែនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៩៧)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

# ទស្សនកិច្ចសិក្សាអំពីសន្តិភាពនិងសិទ្ធិមនុស្ស របស់សិស្សានុសិស្សវិទ្យាល័យក្នុងខេត្តបាត់ដំបងទៅកាន់តំបន់អន្លង់វែង

***ហ៊ាន ពិសី និង មេក ទិន***



ទស្សនកិច្ចសិក្សាអំពីសន្តិភាពនិងសិទ្ធិមនុស្សរបស់សិស្សានុសិស្សវិទ្យាល័យក្នុងខេត្តបាត់ដំបងទៅកាន់តំបន់អន្លង់វែង កាលពីព្រឹកថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២១។ (សូត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

កាលពីព្រឹកថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២១ សិស្សានុសិស្សចំនួន៩ នាក់ លោកគ្រូនិងអ្នកគ្រូចំនួន៧ នាក់ នៃវិទ្យាល័យនេតយ៉ង់ និងវិទ្យាល័យសម្តេចឪ ព្រមទាំងមន្ត្រីចំនួន៣នាក់ នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង និងព្រះសង្ឃចំនួន២អង្គ បានធ្វើទស្សនកិច្ចសិក្សាស្តីអំពីសន្តិភាពនៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ដោយមានការសម្របសម្រួលរបស់អង្គការវេទិកាសេវាពលរដ្ឋ។

ក្នុងដំណើរទស្សនកិច្ចនេះ សិស្សានុសិស្សនិងលោកគ្រូអ្នកគ្រូ បានធ្វើដំណើរមកដល់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនៅលើខ្នងភ្នំដងរែក នៅវេលាម៉ោង៨ព្រឹក ដែលអាកាសធាតុមានភាពត្រជាក់បង្គួរនិងពោរពេញដោយភាពស្រស់ស្រាយ។ អ្នកចូលរួមខ្លះបានដើរតម្រង់ទៅមើលពើយតាម៉ុក ដែលបាននិងកំពុងក្លាយជាទីគយគន់ ឯអ្នកខ្លះទៀតក៏ដើរមកមើលពិព័រណ៍រូបថតស្តីអំពីជីវភាពរបស់ប្រជាជននៅក្នុងស្រុកអន្លង់វែង និងពិធីផ្លូវការនៃការធ្វើសមាហរណ៍-

កម្មនៃចលនាខ្មែរក្រហមនៅថ្ងៃទី២៨ ខែធ្នូឆ្នាំ១៩៩៨ មកក្នុងរាជរដ្ឋាភិបាលកម្ពុជាវិញ ព្រមទាំងផ្ទាំងរូបថតរបស់តាម៉ុក និងផ្ទាំងរូបថតក្នុងដំណើរទស្សនកិច្ចប្រតិភូចិនទៀតផង។

ក្រោយពីបានដើរមើលផ្ទាំងពិព័រណ៍និងទេសភាពដ៏ស្រស់ស្អាតនៅជុំវិញមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ហើយ សិស្សានុសិស្សរួមទាំងលោកគ្រូអ្នកគ្រូបានបន្តចូលទៅសាលប្រជុំ ដែលជាអតីតផ្ទះកណ្ដាលរបស់តាម៉ុក នៅលើភ្នំដងរែក។

ជាកិច្ចចាប់ផ្ដើម បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានណែនាំខ្លួន និងក្រុមការងារទៅដល់អ្នកចូលរួម ហើយបន្ទាប់មកបានធ្វើបទបង្ហាញទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ បណ្ឌិត លី សុខឃាង បានបង្ហាញតាមរយៈផ្ទាំងស្លាយឲ្យឃើញពីការធ្វើពលកម្មដោយបង្ខំរបស់ខ្មែរក្រហមទៅលើប្រជាជនខ្មែរ មានដូចជា លើកទំនប់ និងជីកប្រឡាយ។ ចំណែកផ្ទាំងស្លាយខ្លះទៀតរំលេចអំពីប្រវត្តិរូបមេដឹកនាំកំពូលៗរបស់ខ្មែរក្រហម មានដូចជា សា ឡុត ស (ហៅ ប៉ុល ពត), ឈិត ជឿន(ហៅ តាម៉ុក) នួន ជា, ខៀវ សំផន និង សុន សេន។ បន្ទាប់មក បណ្ឌិត លី សុខឃាង បានចាក់បញ្ចាំងភាពយន្តឯកសារមួយ ស្ដីពីស្ថានភាពគុកទួលស្លែងនៅក្នុងឆ្នាំ១៩៧៩ ដែលជាគុកដ៏អាថ៌កំបាំងបំផុតក្នុងសម័យខ្មែរក្រហម។ ភាពយន្តឯកសារនេះ បានបង្ហាញទិដ្ឋភាពដ៏គួរឲ្យរន្ធត់និងព្រៃផ្សៃបំផុតដែលខ្មែរក្រហមបានធ្វើទារុណកម្មលើប្រជាជនខ្មែរ។

ផ្ទាំងស្លាយបន្ទាប់បានបង្ហាញប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង ព្រមទាំងរូបភាពស្ដីពីជីវភាពរស់នៅរបស់អតីតសមាជិកខ្មែរក្រហមលើទឹកដីអន្លង់វែង រហូតដល់មានការធ្វើសមាហរណកម្មក្នុងឆ្នាំ១៩៩៨។ ក្នុងពេលជាមួយគ្នានេះដែរ វាគ្មិនបានបង្ហាញផ្ទាំងស្លាយអំពីគម្រោងសាងសង់ដំបូលគ្របពីលើទីតាំងបូជាសព ប៉ុល ពត និងរបងនៅលើប្រាក់ភ្នំដងរែកស្ថិតនៅក្បែរមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ របងដែកនៅលើប្រាកភ្នំដងរែកដែលនឹងសាងសង់នៅក្នុងឆ្នាំ២០២២









នេះ នឹងបង្កើតផ្លូវដើរ និងអាចជិះកង់បានដើម្បីភ្ជាប់ទៅកាន់តំបន់ប្រវត្តិសាស្ត្រមួយកន្លែងទៅមួយកន្លែងទៀត ដូចដែលមាននៅក្នុងប្លង់គោលសម្រាប់អភិវឌ្ឍន៍ស្រុកអន្លង់វែង។

នៅក្នុងឱកាសនោះ អ្នកចូលរួមបានសួរសំណួរផ្សេងៗទាក់ទងនឹងកម្មវិធីនេះ។ ព្រះតេជគុណ ពន់ មានសង្ឃដីកាថា «តើគម្រោងដ៏ធំក្នុងការសាងសង់ដំបូលគ្របលើផ្នូរ ប៉ុល ពត និង ការធ្វើរបងនៅជួរភ្នំដងរែកអាចនឹងត្រូវប្រើរយៈពេលយូរដល់កម្រិតណាទើបអាចទទួលបានជោគជ័យ?» ចំណែក ស៊ីណា ដែលជាគ្រូបង្រៀននៅវិទ្យាល័យសម្តេចឪ ខេត្តបាត់ដំបង បានសួរសំណួរថា «ប្រសិនបើមានភ្ញៀវទេសចរណ៍ ឬក្រុមនិស្សិតធ្វើដំណើរមកដល់ទីនេះ ហើយចង់ដាំកូនឈើ តើមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង មានដីទំនេរសម្រាប់ដាំកូនឈើដែរឬទេ?

ទស្សនកិច្ចសិក្សាអំពីសន្តិភាពនិងសិទ្ធិមនុស្សរបស់សិស្សានុសិស្សវិទ្យាល័យក្នុងខេត្តបាត់ដំបងទៅកាន់តំបន់អន្លង់វែង កាលពីព្រឹកថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២១។ (សូត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)



បន្ទាប់ពីឆ្លើយសំណួរនិងពិភាក្សាអំពីប្រវត្តិសាស្ត្ររួចមក អ្នកចូលរួមបានបង្ហាញពីការចាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការដាំដើមឈើ ដើម្បីបង្កើតបាននូវធម្មជាតិពណ៌បៃតង និងបង្ហាញនូវក្តីស្រឡាញ់ធម្មជាតិដ៏ស្រស់បំព្រងនៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង លើខ្នងភ្នំដងរែកនារដូវរំហើយ។ យើងបានថតរូបជុំគ្នាទុកជាអនុស្សាវរីយ៍ មុននឹងបន្តដំណើរទៅកាន់តំបន់ប្រវត្តិសាស្ត្រភ្នំ២០០។

ដើម្បីអាចឡើងទៅដល់ខ្នងភ្នំ២០០បាន អ្នកចូលរួមកម្មវិធីទាំងអស់ត្រូវជិះរថយន្តធ្វើដំណើរឆ្លងកាត់អូរដែលមានស្ពានឈើមួយ។ បន្ទាប់មក រថយន្តទាំងអស់បើកបរសន្សឹមៗលើផ្លូវលំនៃជម្រាលភ្នំដងរែក។ នៅពាក់កណ្តាលផ្លូវ ក្រុមការងារ, សិស្សានុសិស្ស, លោកគ្រូអ្នកគ្រូរួមទាំងព្រះសង្ឃ ត្រូវចុះដើរ ដោយសារតែផ្លូវចំណោទ និងមានដុំថ្មនៅរាយប៉ាយ

សារតែភ្លៀងព្រោះកាលពីរដូវវស្សាដែលទើបតែកន្លងផុតកាលពីខែវិច្ឆិកា។ ខណៈពេលដែលធ្វើដំណើរតាមផ្លូវ កងកម្លាំងនៃយោធាភូមិភាគ៤ របស់កងទ័ពជើងគោក ទទួលស្វាគមន៍ពីមួយដំណាក់ទៅមួយដំណាក់។ អស់រយៈពេលប្រមាណជា១៥នាទីក្រោយមក ក្រុមការងារ, សិស្ស និងលោកគ្រូអ្នកគ្រូព្រមទាំងព្រះសង្ឃ បានធ្វើដំណើរទៅដល់ខ្នងភ្នំ២០០។ នៅទីនោះយើងឃើញថាមានទេសភាពយ៉ាងស្រស់ស្អាត ខ្យល់បក់ត្រសៀកៗ និងឮសំឡេងសត្វស្លាបស្រែកខ្សៀវខ្សាបន្តគ្នាមិនដាច់។ ជាពិសេសយើងអាចគយគន់ទេសភាពវាលស្រែចម្ការ ផ្លូវ និងភូមិឋានរបស់ប្រជាជនដែលរស់នៅស្រុកអន្លង់វែងបានយ៉ាងច្បាស់ថែមទៀត។

នៅក្នុងឱកាសនោះដែរក៏មានការចាំទទួលស្វាគមន៍ និងការធ្វើបទបង្ហាញ ដោយវរសេនីយ៍ឯក ឯម វាសនា មេបញ្ជាការរងនៃកងពលតូចថ្មើរជើងលេខ៤១ និងជាសមាជិកក្រុមការងារប្រវត្តិសាស្ត្រយោធាភូមិភាគ៤។ វរសេនីយ៍ឯក ឯម វាសនា បានចាប់ផ្តើមធ្វើការណែនាំខ្លួនដល់ព្រះតេជគុណ សិស្សានុសិស្ស និងលោកគ្រូអ្នកគ្រូ។ បន្ទាប់មក លោកវរសេនីយ៍ឯក ក៏បានបញ្ជាក់ឈ្មោះថ្មីរបស់ភ្នំ២០០ថា «ទីស្នាក់ការ



កណ្តាលប្រវត្តិសាស្ត្រយោធាតេជោភ្នំ២០០ អន្លង់វែង»។

លោកវរសេនីយ៍ឯក បានធ្វើការអត្ថាធិប្បាយយ៉ាងក្បោះក្បាយ ទាក់ទងនឹងប្រវត្តិសាស្ត្រយោធា និងដំណើរការវិវត្តសង្គ្រាមនៅក្នុងប្រទេសកម្ពុជាពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៩។ លោកវរសេនីយ៍ឯក បានបន្តថា អន្លង់វែងជាតំបន់ធ្វើសមាហរណកម្មចុងក្រោយបង្អស់ ក្នុងឆ្នាំ១៩៩៨។ សង្គ្រាមរ៉ាំរ៉ៃនៅអន្លង់វែងត្រូវបានផ្សះផ្សាតាមរយៈយុទ្ធសាស្ត្រនយោបាយ ឈ្នះ ឈ្នះ ក្រោមការដឹកនាំរបស់សម្តេចតេជោ នាយករដ្ឋមន្ត្រី ហ៊ុន សែន។

ជាកិច្ចបញ្ចប់នៃការសំណេះសំណាល លោកវរសេនីយ៍ឯក បានធ្វើការថ្លែងអំណរគុណដល់ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដែលបានសម្របសម្រួលដំណើរទស្សនកិច្ចសិក្សាមកកាន់តំបន់ប្រវត្តិសាស្ត្រភ្នំ២០០នេះ។ ក្រោយមកយើងបានថតរូបជុំគ្នានៅលើផ្ទាំងថ្មដ៏ស្រស់ស្អាតនៅលើភ្នំ២០០ ទុកជាអនុស្សាវរីយ៍ មុនពេលក្រុមទស្សនកិច្ចសិក្សាបន្តធ្វើដំណើរទៅកាន់សារមន្ទីរផ្ទះ តាម៉ុក។






ទស្សនកិច្ចសិក្សាអំពីសន្តិភាពនិងសិទ្ធិមនុស្សរបស់សិស្សានុសិស្សវិទ្យាល័យក្នុងខេត្តបាត់ដំបងទៅកាន់តំបន់អន្លង់វែង កាលពីព្រឹកថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២១។ (ស្ហួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សិក្ខាសាលាអប់រំ

## «ស្តីអំពីការទប់ស្កាត់អំពើឧក្រិដ្ឋកម្មឃោរឃៅ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ »

*ផេង ពង្សរ៉ាស៊ី*



*សិក្ខាសាលាអប់រំ«ស្តីអំពីការទប់ស្កាត់អំពើឧក្រិដ្ឋកម្មឃោរឃៅ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ » នៅសណ្ឋាគារឡឺរ៉ូយ៉ាល់ កាលពីថ្ងៃទី១៣ដល់ទី១៥ ខែធ្នូ ឆ្នាំ២០២១។ ( សុភ័ក្រ្ត ភាណា/មជ្ឈមណ្ឌលឯកសារកម្ពុជា )*

សិក្ខាសាលាអប់រំស្តីអំពីការទប់ស្កាត់អំពើឧក្រិដ្ឋកម្មឃោរឃៅនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ រៀបចំឡើងជាបីវគ្គផ្សេងគ្នាសម្រាប់ចុងឆ្នាំ២០២១ និងដើមឆ្នាំ២០២២ ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងការិយាល័យទីប្រឹក្សា ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍ក្រោមការគាំទ្រផ្នែកបច្ចេកទេសពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ(USAID) និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ(UNDP)។ សិក្ខាសាលាលើកទី១ ប្រព្រឹត្តទៅនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១គឺជាសិក្ខាសាលាតាមប្រព័ន្ធអនឡាញ និងមានការចូលរួមពីសិក្ខាកាមដែលជាគ្រូបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យាមកពីប្រទេសកម្ពុជា វៀតណាម និងថៃ។ សិក្ខាសាលាលើកទី២ ប្រព្រឹត្តទៅនៅក្នុងប្រទេសកម្ពុជាចាប់ពីថ្ងៃទី៦ដល់៨ ខែធ្នូ ឆ្នាំ២០២១ គឺជាសិក្ខាសាលារយៈពេល៣ថ្ងៃ ដែលមានសិក្ខាកាមចូលរួមដោយផ្ទាល់គឺជាគ្រូបង្រៀនកម្ពុជាមកពីខេត្តត្បូងឃ្មុំ កណ្តាល និងព្រៃវែង ហើយសិក្ខាសាលាលើកទី៣ ប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៣ដល់ទី១៥ ខែធ្នូ ឆ្នាំ២០២១ នៅក្នុងប្រទេសកម្ពុជា ដែលមានសិក្ខាកាមចូលរួមជាគ្រូបង្រៀនមកពីប្រទេសកម្ពុជា វៀតណាម និងថៃ។

សិក្ខាសាលានេះមានគោលបំណងបណ្តុះបណ្តាល

គ្រូបង្រៀនក្នុងតំបន់អាស៊ីអាគ្នេយ៍ឲ្យយល់ច្បាស់អំពីនិយមន័យនៃឧក្រិដ្ឋកម្មឃោរឃៅ កត្តាគ្រោះថ្នាក់នានាដែលនាំដល់ការកកើតឧក្រិដ្ឋកម្មឃោរឃៅ និងសារសំខាន់នៃការទប់ស្កាត់ឧក្រិដ្ឋកម្ម។ លោក គ្រីស្តូហ្វ័រ ឌៀរីង គឺជាគ្រូឧទ្ទេសអន្តរជាតិ ដែលជាអ្នកធ្វើបទបង្ហាញនិងពន្យល់អំពីនិយមន័យ កត្តាគ្រោះថ្នាក់ និងវិធីទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ ដូចជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមមិនឲ្យកើតឡើង។ នៅវគ្គសិក្សានេះគ្រូឧទ្ទេសជាតិនិងអន្តរជាតិ បានបែងចែកជា៣ក្រុមឲ្យមានការពិភាក្សាគ្នា ហើយក្រុមនីមួយៗបានលើកឡើងរៀងៗខ្លួនអំពីកត្តាមួយក្នុងចំណោមកត្តា ទាំង៨ រួមមាន៖ ១) ស្ថានភាពជម្លោះប្រដាប់អាវុធឬទម្រង់អស្ថិរភាពផ្សេងៗ ២) កំណត់ត្រានៃការរំលោភធ្ងន់ធ្ងរនៃសិទ្ធិមនុស្សអន្តរជាតិ និងច្បាប់ ៣) ចំណុចខ្សោយនៃរចនាសម្ព័ន្ធរដ្ឋ ៤) កត្តាជំរុញឬការលើកទឹកចិត្តដែលសមហេតុផលអាចប្រើប្រាស់អំពើហិង្សាលើក្រុមប្រជាជនឬ បុគ្គលដែលត្រូវបានការពារ ៥) សមត្ថភាពក្នុងការប្រព្រឹត្តអំពើឃោរឃៅ ៦) នត្ថិភាពនៃស្ថានសម្រាល ទី៧) កាលៈទេសៈជួយសម្រួលឬវិធានការត្រៀម ៨) កត្តាជំរុញគ្រោះថ្នាក់ជាក់លាក់ ដែលទាំងអស់នេះជាសញ្ញាឬអាចនាំឲ្យកើតមានអំពើឧក្រិដ្ឋកម្ម។




សិក្ខាសាលាអប់រំ«ស្តីអំពីការទប់ស្កាត់អំពើឧក្រិដ្ឋកម្មឃោរឃៅ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍» នៅសណ្ឋាគារឡឺរ៉ូយ៉ាល់ កាលពីថ្ងៃទី១៣ដល់ទី១៥ ខែធ្នូ ឆ្នាំ២០២១។ (សុភ័ក្រ្ត ភាណា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងសិក្ខាសាលានេះ ហឹម ហ៊ុយ គឺជាអតីតកង ពល៧០៣ ដែលធ្លាប់ធ្វើការនៅក្នុងមន្ទីរស-២១ ត្រូវបានអញ្ជើញឲ្យមកចែករំលែករឿងរ៉ាវរបស់ខ្លួនចាប់តាំងពីការជ្រើសរើសឲ្យចូលធ្វើទាហានខ្មែរក្រហមក្នុងតំបន់រំដោះ រហូតដល់របបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។

គ្រូបង្រៀនប្រវត្តិសាស្ត្រ មកពីប្រទេសថៃបានលើកសំណួរទៅកាន់ ហឹម ហ៊ុយ ថា « ហេតុអ្វីបានជាអ្នកអាចស៊ូទ្រាំរស់មកដល់សព្វថ្ងៃនេះ? តើយុវជនបច្ចុប្បន្នត្រូវធ្វើខ្លួនយ៉ាងដូចម្តេចដែលប្រវត្តិសាស្ត្ររបស់ខ្លួនធ្លាប់កើតមានអំពើប្រល័យពូជសាសន៍?» ហ៊ឹម ហ៊ុយ បានឆ្លើយតបថា៖ «ខ្ញុំអាចរស់ជីវិតបានដោយសារខ្ញុំស៊ូទ្រាំ ខ្ញុំគ្រាន់តែចង់រស់មិនចង់មានបុណ្យសក្តិទេហើយមានតែការអប់រំប៉ុណ្ណោះដែលយុវជនអាចទទួលបានចូលរួមចង់ចាំ និងទប់ស្កាត់» ។

ចំណែកអ្នកស្រី សេក សាយ គឺជាកូនស្រីរបស់ចាន់ គីមស្រ៊ុន អតីតជនរងគ្រោះនៅមន្ទីរស-២១ ដែលត្រូវបានសម្លាប់ជាមួយកូនស្រីមានអាយុ៥ខែ





បានរៀបរាប់អំពីរឿងរ៉ាវរបស់ខ្លួនបានចងចាំទាក់ទងនឹងម្តាយរបស់ខ្លួន។ សេក សាយ៉ បានបន្តថា នៅពេលរបបខ្មែរក្រហមដួលរលំ ខ្ញុំអាចរស់នៅបានដោយសារមានស្រ្តីម្នាក់យកទៅចិញ្ចឹម។ សម វិចិត្រ គ្រូខុទ្ទេសថ្នាក់ជាតិរបស់កម្ពុជា បានលើកសំណួរថា «តើលោកស្រីមានអារម្មណ៍ធូរស្បើយទេនៅពេលបានចែករំលែករឿងរ៉ាវអំពើឃោរឃៅដែលខ្មែរក្រហមបានប្រព្រឹត្តមកលើគ្រួសាររបស់អ្នកស្រី និងប្រជាជនកម្ពុជា?»។ សេក សាយ៉ បានតបថា «ខ្ញុំនៅតែចងចាំអំពីម្តាយរបស់ខ្ញុំបើទោះជាខ្ញុំមានកូនប្រុសស្រីដែលអាចធ្វើឲ្យខ្ញុំរីករាយក៏ដោយ។ ខ្ញុំសូមកុំឲ្យរបបឃោរឃៅនេះកើតឡើងម្តងទៀត ហើយសូមឲ្យប្រជាជនកម្ពុជារស់នៅដោយសន្តិភាព»។

នៅក្នុងសិក្ខាសាលាលើកទី៣ គ្រូខុទ្ទេសថ្នាក់ជាតិរបស់កម្ពុជា និងគ្រូប្រវត្តិសាស្រ្តមកពីប្រទេសថៃបានធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលឧក្រិដ្ឋកម្ម និងប្រល័យពូជសាសន៍បឹងជើងឯក, មជ្ឈមណ្ឌលឧក្រិដ្ឋកម្ម និងប្រល័យពូជសាសន៍ទួលស្លែង, សារមន្ទីរជាតិ និងបណ្ណាល័យសម្តេចម៉ែរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ សិក្ខាសាលានេះ មានការចាប់អារម្មណ៍ពីគ្រូប្រវត្តិសាស្រ្តមកពីប្រទេសថៃ វៀតណាម និងគ្រូបង្រៀនកម្ពុជាដែលភាគច្រើនលើសលុបបានយល់ដឹងពីនិយមន័យនៃអំពើឧក្រិដ្ឋឃោរឃៅ និងភាពច្បាស់លាស់ក្នុងការកំណត់ពីកត្តាគ្រោះថ្នាក់នានាដែលនាំដល់ការកកើតអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជានាសម័យខ្មែរក្រហម។ សិក្ខាសាលានេះ បានផ្តល់ចំណេះដឹងដល់សិក្ខាកាមពីកត្តាគ្រោះថ្នាក់នានាដែលនាំឲ្យកកើតអំពើឧក្រិដ្ឋនៅប្រទេសកម្ពុជា អាឡឺម៉ង់ និងប្រទេសរ៉្វាន់ដាទៀតផង។ លើសពីនេះទៀត គ្រូបង្រៀនកម្ពុជា ទាំងអស់ បានទទួលចំណេះដឹងថ្មីៗ ទាក់ទងនឹងវិធីសាស្រ្តបង្រៀនថ្មីទំនើបៗ ក្នុងការពាំនាំយកទៅបង្រៀនសិស្សរបស់ខ្លួនដោយដើរតាមគោលវិធីសិស្សមជ្ឈមណ្ឌល ដើម្បីបង្កើនចំណេះដឹង និងបង្កើនការគិតគូរយ៉ាងស៊ីជម្រៅរបស់សិស្ស។



សិក្ខាសាលាអប់រំ«ស្តីអំពីការទប់ស្កាត់អំពើឧក្រិដ្ឋកម្មឃោរឃៅ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍» នៅសណ្ឋាគារ ឡឺរ៉ូយ៉ាល់កាលពីថ្ងៃទី១៣ដល់ទី១៥ ខែធ្នូ ឆ្នាំ២០២១។ (សុភ័ក្រ្ត ភាណា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)





# «ទួលពិយាដ»

## ៣. វិញ្ញាណព្រលឹងក្រមាប៉ាក់ជាយ (ត)

## ក្រមាប៉ាក់ជាយទម្លាយអាថ៌កំបាំង ( ត )

### *សមមិត្តយុវនារីបដិវត្តន៍ (ត)*

...នេះកំពុងធ្វើអ្វី? ដឹងទេថាកូនៗនឹកអ្នកទាំងអស់គ្នាណាស់។

ប៉ុន្តែ គ្រប់យ៉ាងបានត្រឹមតែស្រមៃ បានត្រឹមតែគិតប៉ុណ្ណោះ គ្មានអ្វីឆ្លើយតបទេ គឺមានតែសំឡេងចម្រៀងបដិវត្តន៍បន្លឺតាមខ្សែគ្រាសនសព្ទចេញពីទួលស្វាំងយ៉ាងរំពង ដែលមានអត្ថន័យ និងសូរសៀងថា "យើងជាយុវជនយុវនារី ត្រូវហ៊ានពលីបង្ហូរឈាម ចូលវាយកម្ទេចខ្មាំងអន្តរធានដែលហ៊ានប្រឆាំងនឹងបដិវត្តន៍យើង" ដូចជាប្រជាជនប្រឆាំងនឹងបដិវត្តន៍ គឺជាខ្មាំងឬក៏មានបទខ្លះដូចជា "យើងប្រយុទ្ធលើកទំនប់ជីកប្រឡាយ តាមមាគ៌ាបដិវត្តន៍ដ៏មហិមា" "ចូរកូនៗ កុំភ្លេចឈាមស្រស់របស់យុទ្ធមិត្តយើងឲ្យសោះ..." និងបទគោរពទង់ជាតិក្នុងសម័យនោះដូចជា" ឈាមក្រហមច្រាលក្រាលស្រោចក្រុងវាលកម្ពុជាមាតុភូមិ ឈាមយុទ្ធជនយុទ្ធនារីបដិវត្តន៍" ជាដើម!។

បានស្តាប់បទចម្រៀងទាំងនេះហើយ មានអារម្មណ៍ថា បទចម្រៀងខ្លោចផ្សាប្រហារគ្រួសារឲ្យបែកបាក់ និងធ្វើឲ្យបេះដូងខ្ញុំឡើងក្តៅគគុកពុះកញ្ជ្រោលទៅតាមកម្ស៊ួលបដិវត្តន៍។

បងស្រីគាត់ដើរទៅមុនបន្តិច ពួកខ្ញុំដើរតាមក្រោយ ពេលនោះក៏ស្រាប់តែបានជួបនឹងនារីកម្មាភិបាលបដិវត្តន៍ពីររូប ស្លៀកពាក់ខោអាវខ្មៅក្រិបបង់កក្រមាថ្មីៗ បងស្រីខ្ញុំ គាត់ស្គាល់កមកខ្សឹបថា "ពួកគេជានារីបដិវត្តន៍ដែលមានផ្ទះនៅខាងក្រោយផ្ទះយើងដែរ" នៅក្នុងរោងយាមមួយជាប់នឹងចុងភូមិ ជិតចម្ការតាម៉ុក។

ដោយសារតែធ្លាប់ស្គាល់គ្នា មិត្តនារីនោះក៏ស្រែកសួរថា "មិត្តនារីចិន្តាទៅធ្វើការមែនទេ?" បងស្រីញញឹមតប "ចា៎ះ ! មិត្តនារី ពួកខ្ញុំទៅធ្វើការ។" ពួកគាត់និយាយគ្នាបានបួនដប់ម៉ាត់។ ពេលនោះ ស្រាប់តែបងស្រីគាត់ក៏ទុចង៉ក់ រលីងរលោងទឹកភ្នែកហើយស្ទុះមកទាញដៃខ្ញុំពីរនាក់ប្អូនវ៉ាដោយវាចាថា តស់ប្អូន! យើងទៅផ្ទះយើងវិញ ទាំងទឹកភ្នែកហូររហាមមកមិនដឹងខ្លួន។ ពួកខ្ញុំងឹងើមិនយល់រឿង តែមិនហ៊ានសួរនាំ ហើយដើរតាមបងស្រីមកផ្ទះវិញ។

តាមផ្លូវ បងស្រីខ្ញុំយំរហូតធ្វើឲ្យពួកខ្ញុំឆ្ងល់ខ្លាំងណាស់។ គ្រាន់តែមកដល់ផ្ទះភ្លាម បងស្រីខ្ញុំយំឱបយាយតាហើយ និយាយថា "លោកពុកអ្នកម្តាយ និងប្អូនៗរបស់ខ្ញុំត្រូវគេសម្លាប់អស់ហើយ ខ្ញុំគ្មានអ្វីនៅសេសសល់ទៀតទេ អស់រលីងក្នុងជីវិត"។

គ្រប់គ្នាភ្ញាក់ស្រឡាំងកាំង។ ខ្ញុំសួរទៅបងស្រីថា "ម៉េចបានបងដឹង? បងស្រីយំផងនិយាយផងថា "បងបានឃើញក្រមាដែលមានប៉ាក់ជាយឈ្មោះចិន្តា ដែលបងជូនទៅពុកពីថ្ងៃមុននៅនឹងមិត្តនារីសុខាបង់ក ដូច្នេះមានន័យថា ពួកគាត់ត្រូវគេសម្លាប់អស់ហើយ!"។

ស្តាប់ចប់ ខ្ញុំស្លុតចិត្តចង់ទន់ជង្គង់ដួល។ ខ្ញុំយំ ហើយនឹកឃើញទៅដល់រូបភាពកាលពីបួនដប់ថ្ងៃមុនពេលឪពុកម្តាយខ្ញុំទៅទួលស្វាំង។ ខ្ញុំតែងតែឃើញបងស្រីខ្ញុំអង្គុយប៉ាក់ឈ្មោះគាត់លើក្រមា រឿងនេះគឺពិតមែនហើយ មិនមានអ្វីបិទបាំងទៀតទេ។

ក្រមាប៉ាក់ជាយ ពិតជាដិតដាមដោយវិញ្ញាណព្រលឹងទឹកភ្នែកឪពុក ស្ថិតនៅ ដែលនាំក្រមាឲ្យជួបកូនស្រីឲ្យបានឃើញ ឲ្យបានយល់ថា ឪពុកម្តាយ និងប្អូនភ្លោះត្រូវគេសម្លាប់លើទួលស្វាំងអស់ហើយ កុំទន្ទឹងរង់ចាំមើលផ្លូវឪពុកម្តាយទៀតអី។

យាយ និងតាឱបចៅ ទាំងបីនាក់យំដោយក្តីអាណិតជាពន់ពេក។ ខ្ញុំយំ

ហើយយំទៀតរួចគិតថា ឱ! ព្រះអើយ ហេតុអ្វីបងប្អូនខ្ញុំក្លាយជាក្មេងកំព្រាតែមួយប៉ប្រិចភ្នែកយ៉ាងនេះ?

ព្រះព្រហ្មលិខិតបង្កើតឲ្យជួបជុំគ្រួសារហើយ ម្តេចពួកបិសាចចាំបំបែកឲ្យខ្ទេចខ្ទាំទៀត។ ខ្លួនខ្ញុំស្ទើរឆ្កួតវង្វេង ដាច់ទងផ្ទើមប្រមាត់រស់នៅជួបតែសេចក្តីទុក្ខនិងសោកស្តាយ។ ឱ! ជីវិតគ្រួសារខ្ញុំ ពិតជាងងឹត ងងឹតខ្លាំងណាស់! ហេតុអ្វី បានជាប្តូរផ្លាស់ប្រែប្រួលខុសឆ្ងាយ។

ភ្លៀងដូចគេហែកមេឃ ខ្យល់ និងរន្ទះកាលពីយប់នោះពិតជាប្រផ្នូលចង់ប្រាប់ខ្ញុំថា ឪពុកម្តាយ និងប្អូនភ្លោះទាំងពីរត្រូវគេសម្លាប់ចោលហើយ។ "ឱ! ជំនោរនិរតីអើយ ហេតុអ្វីអ្នកគ្មានប្រណីដល់គ្រួសារខ្ញុំសោះ!"។



ទិដ្ឋភាព៖ បងស្រីរ៉ាយរ៉ាប់ប្រាប់តាយាយពេលឃើញក្រមាប៉ាក់ជាយឈ្មោះ "ចិន្តា" ។ (ឡុង វង្សសមិទ្ធ/ សៀវភៅ ទួលពិឃាដ)

## ទួលស្លាំងខាបព្រលឹង

### រូបគ្មានវិញ្ញាណ សល់តែការឈឺចាប់

ពេលវេលាកន្លងផុតទៅបានប៉ុន្មានថ្ងៃ។ ពេលព្រឹកថ្ងៃមួយ បងប្អូនបីនាក់អង្គុយជុំគ្នាជាមួយតាយាយ ម្នាក់ៗធ្វើមុខស្រពោនដូចជាសញ្ជឹងគិតនូវរឿងខ្មៅងងឹតដែលកើតមានឡើងកន្លងមក។

ពេលនោះស្រាប់តែឃើញមីងសនដែលខ្ញុំស្គាល់គាត់គឺជាអ្នកមូលដ្ឋានហើយគាត់រាប់អានឪពុកម្តាយខ្ញុំបានដើរចូលមកកាន់ជីដូនជីតាហើយពោលពាក្យថា "នែ... អ៊ំអាន អ៊ំហ៊ាង ប៉ុន្មានថ្ងៃមុនខ្ញុំឃើញលោកបង និងអ្នកបង (គាត់និយាយខ្សឹបៗផាកផ្អេងផាកស្តាំ ព្រោះពាក្យ លោកបង អ្នកបងនេះគឺជាពាក្យសក្តិភូមិដែលអង្គការបដិវត្តន៍មិនឱ្យប្រើ ជាដាច់ខាត ម្យ៉ាងទៀតឪពុកខ្ញុំជាអ្នកបួស និងជាគ្រូបង្រៀនដែលកើតចេញពីកូនកសិករសុទ្ធសាធ មិនក្លែងបន្លំ ដែលបានសាបព្រោះនូវចំណេះដឹងដល់កូនអ្នកស្រុកអ្នកភូមិ មិនតិចទេ ហើយមានសេចក្តីស្រឡាញ់រាប់អានពីអ្នកភូមិច្រើនណាស់)"។

ដើរតាមទំនប់ស្ពាយខោអាវវេចនឹងក្រមា អ្នកបងឆេងទូលកញ្ជើនៅលើក្បាល និងដឹកដៃអាភ្លោះពៅពីរនាក់ផង។ ខ្ញុំសួរគាត់ថា លោកបង ឡុង អ្នកបងឆេង ធ្វើដំណើរទៅណានឹង? គាត់តបមកវិញទាំងទឹកមុខស្រងូតស្រងាត់ថា "គ្រួសារបងត្រូវមេកងអង្គការចាត់តាំងឱ្យទៅរស់នៅលើទួលស្លាំង ខ្ញុំក៏ស្រែកភ្ញាក់សំឡេង មិនកើតទេលោកបង ឡុងៗលោកបងកុំចូលទួលនេះអីគេនឹងសម្លាប់គ្រួសារលោកបងនៅទីនេះហើយ។ លោកបង អ្នកបងអញ្ជើញធ្វើដំណើរបង្ហួសទៅភូមិយោគ ដែលជាភូមិកំណើតរបស់លោកបងទៅ គ្មានអ្នកណាដឹងទេ"។



ទិដ្ឋភាពតំណាងៈ ពេលឪពុកម្ដាយ និងប្អូនភ្លោះជួបអ្នកភូមិដែលជាអតីតកូនសិស្សគាត់ ហើយបានប្រាប់ឪពុកឱ្យដើរបង្អួសទៅភូមិយោគ កុំចូលទួលស្លាំង។
(ឡុង វង្សសមិទ្ធ/ សៀវភៅទួលពិឃាដ)

សូមបញ្ជាក់ថាភូមិកំណើតរបស់ឪពុកខ្ញុំស្ថិតនៅខាងជើងទួលស្លាំងនេះ គឺភូមិយោគ។

លោកបង អ្នកបងបានតបមកវិញទាំងទឹកភ្នែករលីងរលោងថា "មិនបានទេៗប្អូនសន បើអង្គការរកមិនឃើញគ្រួសារបងមកនៅទីនេះទេ គេនឹងទៅរកដល់ផ្ទះ ពេលនោះគេឃើញកូនៗខ្ញុំនៅផ្ទះ ប្រាកដជាគេសម្លាប់កូនៗនិងឪពុកម្ដាយខ្ញុំចោលជាមិនខានៗ ដូច្នេះខ្ញុំសុខចិត្តស្លាប់ដើម្បីកូនរស់ មិនអីទេប្អូនសនបងលាហើយ ខ្លាចអង្គការចាំយើងយូរ។" ក៏លោកបងឡុង អ្នកបងឆេង ដើរចូលទួលស្លាំង ហើយងាកមកស្រែកផ្ដាំខ្ញុំថា "ប្អូនសនៗបើមានពេលទៅសួរសុខទុក្ខឪពុកម្ដាយ និងជួយលាក់កូនៗខ្ញុំផង ហើយប្រាប់គាត់ថា ពួកខ្ញុំសុខសប្បាយធម្មតាទេ។" ខ្ញុំមើលទៅគាត់ទាំងពីរនាក់ទឹកមុខស្រពោន បង្កប់ដោយភាពទុក្ខសោកនៃរូបកាយគ្មានវិញ្ញាណ។

ជីដូនជីតា និងបងប្អូនបីនាក់ គ្រាន់តែឮពាក្យសម្ដី"រាយ"រាប់ដូចខាងលើ មើលមុខគ្នាដោយទឹកមុខក្រៀមក្រំម្នាក់ៗដើរចេញរៀងៗខ្លួន។ ខ្ញុំខំដកដង្ហើមវែងៗលេបទឹកមាត់ទប់ទឹកភ្នែកដែលកំពុងហូរ នឹកស្រណោះពាក្យបណ្ដាំពេជ្រ រាប់ពាន់អត្ថន័យ ដែលចេញពីបេះដូងនិងទឹកចិត្តលោកឪពុកអ្នកម្ដាយ ប្រកបដោយកត្តញ្ញូកត្តវេទី រវាងឪពុកម្ដាយ កូន និង ចៅ ឱ្យដើរតាមគន្លងព្រហ្មវិហារធម៌ និងឱ្យធ្វើតែអំពើល្អ សុចរិត ទៀងត្រង់ និងជាមនុស្សប្រាកដនិយម។

គិតហួសនិស្ស័យដែលសម្ដីឪពុកប្រាប់មីងសនថា បងលាសិនហើយ ខ្លាចអង្គការចាំយើងយូរៗ ពុទ្ធោ! ភាពតក់ស្លុត ខូប ខ្លាចរអាបាក់ស្បាត សូម្បីផ្ដោះទៅឱ្យគេសម្លាប់ក៏ខ្លាចយឺតពេលដែរ។ ពិតជាសាហាវយង់ឃ្នងណាស់សម្រាប់មនុស្សជាតិដូចគ្នា តែមានកម្មពៀរ ខុសគ្នាដាច់ស្រឡះ។

ចាប់ពីពេលនេះទៅពួកខ្ញុំលែងបានឃើញមុខ លែងបានស្ដាប់ និងលែងបានឮសម្ដីពួកគាត់ទៀតហើយ! ខ្ញុំបងស្រី និងប្អូន យំរាល់យប់ រាល់ថ្ងៃ ព្រោះតែនឹកដល់លោកពុកនិងអ្នកម្ដាយ ព្រមទាំងប្អូនៗទាំងពីរ។ បងស្រីខ្ញុំនឹកក្ដុកក្ដួលក្នុងចិត្ត និងស្រក់ទឹកភ្នែកពេលដែលគាត់មកពីវាលវិញ ឈរនៅមាត់ពាងស្រែកប្រាប់ម្ដាយថា "ម៉ែអើយ ម៉ែបោះក្រមានិងដ្ដិលឱ្យកូនបន្តិចមក កូនងូតទឹក"។ តែពេលនេះគាត់មកដល់ពាងហើយមើលទៅលើស្វាត់ជ្រង មិនឃើញរូបម្ដាយ មើលទៅក្នុងពាងឃើញតែស្រមោលខ្លួនឯងនិងតំណក់ទឹកភ្នែកស្រក់ចូលពាងធ្វើឱ្យរលកបាត់ស្រមោលខ្លួនឯងមួយរំពេច ដូចជាការបាត់បង់ម្ដាយដូច្នោះដែរ មានតែពាងទឹកទេជាសាក្សីក្នុងក្ដីកម្សត់នេះ។

ពាក្យសម្ដីមីងសនដែលបាននិយាយជាមួយពុកម៉ែ ពិតជាធ្វើឱ្យខ្ញុំចំបែងវែងទុក្ខកង្វល់បន្សល់តែក្ដីសោកស្ដាយរយលានអាល័យនៃជីវិតស្ថិតក្នុងអន្ទង់កម្មដែលគ្មានរស្មីអាប់សូន្យឈឹងថាឥតរំពឹងបានជួបទៀតក្នុងខួមជីវិតអភ័ព្វនេះ៕

# ព្រលឹងទឹកភ្នែកពូឌឿន និងកូនស្រីដែន លើទួលស្លាំង

## វិប្បដិសារីគ្រួសារពូឌឿន

គ្រួសារពូឌឿន ត្រូវមេកងកម្មាភិបាលបដិវត្តន៍ចោទថាជាខ្មាំង ដែលពួកអាវខ្មៅត្រៀមយកទៅសម្លាប់នៅទួលស្លាំង គឺជាអ្នកទោស១៧មេសា ដូចគ្រួសារខ្ញុំដែរ។

បន្ទាប់ពីដដែកគ្នាជាមួយឪពុកខ្ញុំមក ហើយឃើញម្តាយខ្ញុំរុញក្បាលប្អូនរ៉ាឱ្យចាកចេញពីទួល។ ពូឌឿងដឹងកាន់តែច្បាស់ថា គេមានផែនការសម្លាប់នៅទីនេះ។ គាត់ក៏ប្រញាប់ប្រញាល់ប្រាប់កូនស្រីច្បងរបស់គាត់ឈ្មោះដែនអាយុស្របាលប្អូនប្រុសខ្ញុំ ដោយប្រាប់កូនថា"កូនទៅផ្ទះចុះ បើកងឈ្លបអាវខ្មៅសួរឆ្លើយប្រាប់គេថា ពុកភ្លេចយកថ្នាំដក់ ឥឡូវគាត់ឱ្យមកយក"។ ពេលកូនស្រីចាកចេញទៅ ពូឌឿនមានអារម្មណ៍ធូរស្បើយ ដោយដឹងថា កូនស្រីគាត់រួចពីសេចក្តីស្លាប់នេះ។

កូនស្រីដែនបានមកដល់ផ្ទះជួបតា ហើយរ៉ាយរ៉ាប់ថា ពុកឱ្យមកយកថ្នាំដក់។ ដោយសេចក្តីអាណិតកូន តាក៏រូតរះលូកយកថ្នាំចេញពីក្រឡដាក់ចូលក្នុងស្មុកហុចឱ្យចៅដោយយកដៃអង្អែលក្បាល ហើយពោលថាចៅប្រញាប់ទៅវិញ ក្រែងពុកចៅរង់ចាំថ្នាំដក់។ ចៅស្រីក៏ចាកចេញសំដៅទៅទួលស្លាំងវិញ។

ក្រោយពីដឹងថាគេសម្លាប់ចោលអស់អ្នកដែលគេយកទៅរស់នៅទួលស្លាំង ទើបឪពុកម្តាយបងប្អូនពូឌឿនមានការសោកស្តាយយ៉ាងខ្លាំង។ មិនគួរណាឱ្យចៅ និងក្មួយត្រឡប់ទៅទួលស្លាំងវិញសោះ ព្រោះនេះជាគំនិតដ៏ឆ្លាតវៃរបស់ពូឌឿន ដើម្បីរំដោះឱ្យកូនបានរស់។ ភាពស្មោះត្រង់របស់ឪពុកម្តាយពូឌឿន មិនបានគិតវែងឆ្ងាយ ទើបឱ្យចៅត្រឡប់មកវិញ។

ក្រុមគ្រួសារពូឌឿនពិតជាមានការសោកស្តាយយ៉ាងខ្លាំងគក់ទ្រូងហួសចិត្តដោយនឹកក្នុងចិត្តថាកូនស្រីបានទៅជួបពូឌឿនវិញ ឬក៏ត្រូវគេសម្លាប់មុនកូនស្រីទៅដល់។ តែបើពូឌឿនមិនបានជួបមុខកូនស្រី នោះព្រលឹងគាត់នឹងគិតថា កូននៅរស់រានមានជីវិតបន្តពូជពង្សដល់សព្វថ្ងៃនេះ។ តែបើគាត់បានជួបកូនស្រីវិញ គាត់ពិតជាហួសនិស្ស័យមិនយល់ហេតុអ្វីបានជាកូនស្រីត្រលប់មកវិញ ដែលគាត់ខំបញ្ចៀសពីដីរំស្លាប់នេះ។

ក្រុមគ្រួសារពូឌឿនដែលនៅរស់ដល់សព្វថ្ងៃនេះពិតជាមានវិប្បដិសារីជេរស្តីឈឺចាប់ខ្លោចផ្សាធ្ងន់ធ្ងរមិនអាចបំភ្លេចបានរហូតដល់ថ្ងៃរលត់ ដែលមិនបានយល់នូវល្បិចពូឌឿនខំបញ្ចៀសកូនចេញពីទួលពិឃាដ។ ពួកគាត់មានតែលើកដៃសុំទោសដល់ព្រលឹងទឹកភ្នែកកូនបងប្អូនចៅ និងក្មួយ ហើយក៏គ្មានអ្វីក្រៅពីឧទ្ទិសដល់វិញ្ញាក្ខន្ធកូនប្អូនបងចៅ និងក្មួយឱ្យសោយសុខក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

(ដកស្រង់សម្តីពីជ័យ ជាតិ ហៅញិល ប្អូនប្រុសពូឌឿន ដែលបានរ៉ាយរ៉ាប់យ៉ាងក្តុកក្តួលរំជួលអារម្មណ៍នឹកអាណិតដល់បងនិងក្មួយស្រី ទាំងទឹកភ្នែក)



រូបភាពបច្ចុប្បន្នឆ្នាំ២០១៩៖ ផ្លូវចូល និងទួលស្លាំងមើលពីចម្ងាយ (ឡុង វណ្ណសមិទ្ធ/សៀវភៅទួលពិឃាដ)

# ៤. ព្យុះជីវិតក្រោយមេឃបាត់ដួងចន្ទ្រ

អ្នកទោសកុមារបដិវត្តន៍

## នារីមេកងកុមារបដិវត្តន៍

យប់ថ្ងៃ ថ្ងៃយប់ ចេះតែកន្លងទៅៗ ខ្សែជីវិតរុះរោយ លម្អងអស់ក្លិនឥតខ្លឹមសារ ក្នុងពិភពខ្មៅងងឹតបានបិទបាំងអ្វីៗគ្រប់យ៉ាង មិនឱ្យបានយល់ដឹងទាំងអស់ៗ រស់នៅមួយថ្ងៃ គឺបានរស់មួយថ្ងៃ ពេលយប់មកដល់គឺដេកកំដររង់ចាំសេចក្តីស្លាប់ បើកភ្នែកឡើងពេលណាយល់តែទុក្ខអំពល់ក្នុងចិត្ត ព្រោះថាក្នុងសម័យនោះនៅពេលយប់តែងតែមានអ្នកស្លាប់មិនដែលខានឡើយ ដោយចោទជាថា ខ្មាំងប្រតិកិរិយាជាដើម។

ខ្ញុំនិងប្អូនប្រុសត្រូវប្រធានក្រុមកុមារឱ្យទៅចាំគោ ដូចសព្វមួយដង ចំណែកបងស្រីខ្ញុំជាកងនារី គេឱ្យទៅធ្វើស្រែនៅទីងមូលដ្ឋានមិនដែលបានជួបគ្នាទេ ជួបតែពេលរាត្រី ពេលថ្ងៃមកដល់បែកគ្នា ដូចដែនដី និងចន្ទ្រា។

ថ្ងៃមួយមេកងកុមារឱ្យខ្ញុំទៅចាំគោនៅខាងលិចភូមិក្បែរត្រពាំងតាទិត។ មានកូនអ្នកមូលដ្ឋានម្នាក់ឈ្មោះអាប៉ោង ដែលវាស្រលាញ់អាណិតខ្ញុំមិនរើសអើងដូចកុមារមូលដ្ឋានដទៃ គេហៅខ្ញុំថា "ម៉ោះមិត្តវង្សមកលេងជាមួយអញ" រួចក៏នាំគ្នាឡើងបេះផ្កាចារនិងច្រៀងលេង។

មួយស្របក់ក្រោយមក ឃើញមេកងកុមារសមមិត្តនារីអឿន មកស្រែកដូចជាមានកំហឹងដាក់ខ្ញុំថា "នែសមមិត្តកុមារថ្មីវង្ស ទីនេះមិនមែនជាកន្លែងច្រៀងសប្បាយនូវបទចម្រៀងពីសង្គមចាស់ទេ ប្រញាប់ចុះមកភ្លាម ហើយកុំឱ្យមានជាលើកទីពីរ។ ខ្ញុំក៏ចុះមកតាមបញ្ជា។ គេសម្លក់មើលមកខ្ញុំតាំងពីក្បាលដល់ចុងជើងស្ទើរជ្រុះគ្រាប់ភ្នែក ដូចជាស្អប់ខ្ពើមរអើមនឹងជីវិតខ្ញុំជាអ្នក១៧មេសាណាស់។

ពេលថ្ងៃជ្រេបាក់រសៀលគេប្រាប់ឱ្យកុមារ កៀងគោត្រឡប់ទៅភូមិវិញ។ ខ្ញុំបានបញ្ចូលគោក្នុងក្រោលរួមរួចរាល់ហើយក៏ដើរសំដៅទៅហូបបាយនៅរោងបាយសហករណ៍កណ្តាលភូមិ។ ពេលនោះ មិនទាន់ដល់ពេលវេលា ឆ្អៀតឱកាសនោះខ្ញុំឃើញកុមារមូលដ្ឋានមួយក្រុមមានគ្នាប្រមាណប្អូនប្រាប់នាក់អង្គុយលើគំនរធុងសាំងម៉ូតូចាស់ៗ យកឈើវាយលេងធ្វើជាចង្វាក់ភ្លេង។

ខ្ញុំឈរមើលពួកគេដូចជាសប្បាយណាស់។ ឃើញខ្ញុំមើល ពួកគេក៏ស្រែកព្រមគ្នាមកកាន់ខ្ញុំថា "នែពួក! អា១៧មេសាចូលមកលេងជាមួយយើងមក"។ ក្នុងចំណោមក្រុមកុមារទាំងនោះក៏មានអាប៉ោ វាបានស្ទុះមកទាញដៃខ្ញុំហើយនិយាយថា "មកៗ លេងជាមួយយើង!" ព្រមទាំងហុចឈើមកឱ្យខ្ញុំទាំងនិយាយថា "នែវាយលើធុងសាំងម៉ូតូនេះទៅ ពីរោះណាស់ៗ"

ខ្ញុំក្រាញតបដោយបដិសេធ ព្រោះខ្ញុំមិនចង់មានកំហុសជាលើកទីពីរ ហើយប្រាប់ទៅពួកគេថា ខ្ញុំមិនចេះលេងទេ សុំទោសមិត្តកុមារទាំងអស់គ្នា តែពួកគេមិនព្រមរហូតទាញខ្ញុំឱ្យអង្គុយជាមួយ ហើយវាយលេងបន្តទៅ។

មិនយូរប៉ុន្មានខ្ញុំឃើញមិត្តនារីមេកងដែលជាប្រធានកងកុមារមកប្រាប់ថា មិត្តកុមារទាំងអស់គ្នាមកហូបបាយក្រុមកុមារនាំគ្នាចូលទៅក្នុងរោងបាយរួម។

នារីមេកងចេះតែលួចសម្លឹងមកខ្ញុំដោយទឹកមុខមាំមិនហ៊ានស្តីបន្ទោសទេ ព្រោះខ្ញុំនៅជិតកុមារកូនមូលដ្ឋាន។ ខ្ញុំអង្គុយលើតុបាយតែម្នាក់ឯងរង់ចាំម្ហូបក្រោយគេ ទម្រាំគេដាក់ឱ្យកូនអ្នកមូលដ្ឋានមុន។

ខ្ញុំសង្កេតឃើញ មេកងនារីកុមារនោះដើរក្រឡឹងសម្លក់ខ្ញុំចុះឡើងៗ ចិញ្ចឹមចិត្តចងកំហឹងនឹងខ្ញុំ។ ខ្ញុំមិនហ៊ានមើលមុខគាត់ទេ ចេះតែងាកចេញធ្វើមុខធម្មតាដូចជាគ្មានរឿងអ្វីកើតឡើង។

(តនៅលេខក្រោយ)

រូបក្របមុខ៖

កងកំពុងធាក់រហាត់ទឹកបញ្ចូលស្រែនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៩៧)។

(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖

កងកុមារដើរជាជួរចេញទៅធ្វើការនៅតាមការដ្ឋានការងារ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៩៧)។

(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 264, December 2021 ◆ Funded by USAID

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.